ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Dec-2015, 12:54
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៣៤៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក និកូឡូ ប៉ុងស៍*(Mr. Niccolo PONS)*

លោក ឯម ហ៊ុយ

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវិន្ត

លោក ស្រ៊ា រតនៈ

លោក វាំងសង់ វ៉ាយដ៏ ដេស្មាឯល

*(Mr. Vincent de Wilde d'Estmael)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉ែន ពៅ

លោកស្រី ទី ស្រ៊ីនណា

កញ្ញា លីម៉ា ង្វៀន *(Ms.Lyma NGUYEN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ព្រុំ សារុន (2-TCW-945) | ខ្មែរ |
| លោក អ៊ុំ ស៊ិន (2-TCW-949) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ព្រុំ សារុន** ((2-TCW-945)

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........ ទំព័រ ៣
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី........ ទំព័រ ៩
សួរដោយលោកស្រី អង់តា ហ្គីសសេ ផ្ដើមពី........ ទំព័រ ២៣

**ការសួរសំណួរសាក្សី៖ លោក អ៊ុំ ស៊ន់** (2-TCW-949)

សួរដោយលោកប្រធាន ផ្ដើមពី ........ ទំព័រ ២៦
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្ទាឯល ផ្ដើមពី........ ទំព័រ ៣០
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្ដើមពី ........ ទំព័រ ៦១
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី........ ទំព័រ ៦៤
សួរដោយលោកស្រី អង់តា ហ្គីសសេ ផ្ដើមពី........ ទំព័រ ៦៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:២៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយសវនាការនៅថ្ងៃនេះ គឺធ្វើសវ-នាការបញ្ចប់ការស្ដាប់សក្ខីកម្មសាក្សី ព្រុំ សារុន ហើយនិងចាប់ផ្ដើមស្ដាប់សាក្សីដែលមានរហស្សនាម 2-TCW-949។ ក្រឡាបញ្ជីសវនាការលោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះមានវត្តមាន ដោយលើកលែងតែលោក គង់ សំអុន និងមេធាវី ខលវីន សោនដឺស៍ មកយឺតបន្តិចដោយមូលហេតុស្ទះចរាចរណ៍។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនា-ការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះគឺលោក ព្រុំ សារុន លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។

[០៩:០៣:១៥]

នៅថ្ងៃនេះផងដែរមានក្រឡាបញ្ជីបម្រុង -- សូមទោស មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-949។ សាក្សីបានបញ្ជាក់ថាតាមសមត្ថភាពដែលអាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីរូបនេះនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនាព្រឹកនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ឯម ហ៊ាយ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥។

[០៩:០៤:២៩]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅអ.វ.ត.ក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថាមានអាការៈឈឺចង្កេះជាប្រចាំ និងវិលមុខ មិនអាចអង្គុយយូរបាន និងបានផ្ដល់អនុសាសន៍ថាសុំអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោយសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។ ហើយមុននឹងផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដី ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ ដោយមានចៅក្រមមានបំណងសួរ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងគឺលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[០៩:០៥:៥៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំចង់សួរសំណួរមួយចំនួនពាក់ព័ន្ធនឹងអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញ។ ហើយឥឡូវនេះ ខ្ញុំចង់ត្រឡប់មកសួរអំពីទីតាំងផ្សេងៗដែលមានការសម្លាប់មនុស្ស។ កាលពីម្សិលមិញ លោកនិយាយអំពីកន្លែងមួយនៅទួលតាត្រង់ លោកឆ្លើយថានៅកន្លែងនោះ លោកបានឃើញសាកសពរបស់ជនជាតិវៀតណាម។ លោកក៏និយាយអំពីកន្លែងមួយដែលមានដំបូក--

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំសូមអធ្យាស្រ័យ--

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

លោកមេធាវី កូប៉េ ប្រសិនបើលោកមានចង់សួរសូមចាំដល់វេនលោកទៅ កុំរំខានខ្ញុំ!

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែលោកប្រធាន គាត់ថាគាត់មិនដែលឃើញសាកសពជនជាតិវៀតណាមទេ។ ដូច្នេះហើយសេចក្តីសង្ខេបនេះគឺថាមិនត្រឹមត្រូវទេ។

[០៩:០៧:០៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

ខ្ញុំនឹងសួរថាយ៉ាងម៉េច លោកមិនបាច់ប្រាប់ទេ!

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

**ស៖** លោកសាក្សី លោកនៅចាំទេ លោកបាននិយាយអ្វីខ្លះពាក់ព័ន្ធនឹងទីតាំងមួយដែលមានឈ្មោះថា ទួលតាត្រង់ កាលពីម្សិលមិញនោះ។ លោកមានបានឃើញសាកសពទេ? ហើយបើឃើញនោះ សាកសពហ្នឹងសាកសពរបស់ជនជាតិអ្វី?

**លោក ព្រុំ សារុន៖**

**ឆ៖** សាកសពកូនក្មេង ខ្ញុំដើរទៅរកក្របីឃើញសាកសពកូនក្មេង ក៏ខ្ញុំដើរហួសទៅ ប៉ុណ្ណឹងឯង។

**ស៖** កូនក្មេងហ្នឹងជាកូនក្មេងខ្មែរ ឬក៏វៀតណាម?

**ឆ៖** មិនដឹងកូនក្មេងស្អី មើលមិនស្គាល់ផង ហើមហើយ មិនដឹងជនជាតិវៀតណាម ឬខ្មែរ។

**ស៖** លោកក៏បាននិយាយអំពីកន្លែងមួយដែលមានដំបូក ហើយកន្លែងដែលមានដំបូកហ្នឹង ជាកន្លែងដែលមានឈ្មោះទួលតាត្រង់ហ្នឹង ឬក៏ជាកន្លែងផ្សេង?

[០៩:០៨:៥០]

**ឆ៖** កន្លែងទួលតាត្រង់ហ្នឹងឯងមានដំបូកនោះ។ ខ្ញុំដើរទៅរកក្របីឃើញហើមប៉ោងអស់ហើយ រលួយអស់ហើយ មិនដឹងជាសាកសពអី។

**ស៖** កាលពីម្សិលមិញ -- តើខ្ញុំចង់សួរអ៊ីចេះ -- លោកបានឃើញគេសម្លាប់ជនជាតិវៀតណាមទេ? សូមទោស គឺលោកបានឃើញគេចាប់ខ្លួនជនជាតិវៀតណាមទេ? ហើយបើឃើញ តើគេចាប់ហើយ គេនាំយកទៅណា?

**ឆ៖** អត់ដែលបានឃើញគេចាប់ទេ។ គេនាំទៅឯណាក៏ខ្ញុំមិនដឹងដែរ។ នរណាទៅហ៊ានសួរគេ យកតែអាយុខ្លួនឯង ធ្វើការឲ្យគេដែរ បម្រើគេ។ តែជៀសវាងពលកម្ម កេងពលកម្មគេ គេថាមើលជណ្ដើរសនោះ។ តែខ្ជិលអីមិនបានទេ គេមើលជណ្ដើរស ភ្នំសំពៅ។

**ប្រធានអង្គជំនុំ៖**

លោកសាក្សីចាំស្ដាប់សំណួរ មែនយកមកអត្ថាធិប្បាយអ្វីដែលវាឥតប្រយោជន៍ មិនពាក់ព័ន្ធនឹងការសួរទេ គឺលោកផ្ដល់ចម្លើយទៅតបទៅនឹងសំណួរដែលភាគី ឬចៅក្រមសួរចំពោះលោក។ ឆ្លើយតបកម្រិតចាំបាច់ ន័យឲ្យពេញលេញនិងសមស្របទៅនឹងសំណួរបានហើយ ជៀសវាងការធ្វើអត្ថាធិប្បាយអ្វីផ្សេងទៀតក្រៅពីភាពចាំបាច់នៃការឆ្លើយតបនឹងសំណួរ។

[០៩:១០:៥០]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សី ខ្ញុំនឹងអាននូវចម្លើយរបស់លោកដែលលោកបានផ្ដល់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេតគឺឯកសារលេខ E3/5187។ គឺនៅទំព័រទី២ជាភាសាបារាំង ទំព័រទី២ជាភាសាអង់គ្លេស និងទំព័រទី២ជាភាសាខ្មែរ។ "នៅឆ្នាំ៧៦ ពួកខ្មែរក្រហមបានសួររកជនជាតិយួន ក្រច ដែលជាប្រធានវរលេខ១បានសួរមកខ្ញុំថា តើក្នុងកងរបស់មិត្តមានពួកយួនដែរឬទេ? បើមានសូមរាយការណ៍ទៅថ្នាក់លើដើម្បីចាត់ការ។ ក្នុងកងវរខ្ញុំគ្មានយួនទេ ប៉ុន្តែនៅក្នុងវរៈលេខ២មានយួនប្រហែល២០នាក់ ខ្ញុំបានឃើញគេចាប់ពួកយួនចងស្លាបសេក រួចបណ្ដើរយកទៅសម្លាប់ចោលនៅទួលតាត្រង់នៅជិតភ្នំកុយ។

ពួកយោធាក្មេងៗដែលបណ្តើរអ្នកទាំងនោះទៅសម្លាប់នោះគឺមានប្រហែលប្រាំនាក់សុទ្ធតែជាកូនកម្មាភិ-បាលខ្មែរក្រហម។ សៈ តើហេតុអ្វីបានជាលោកដឹងថាពួកគេយកអ្នកទាំងនោះទៅសម្លាប់? ឆៈ ខ្ញុំបានលួចទៅមើលកន្លែងដែលគេបណ្តើរយួនទាំងនោះទៅសម្លាប់ ហើយក៏បានឃើញសាកសពមនុស្សស្រី និងកុមារដែលមានស្នាមវាយត្រង់ក្បាលដោយចុងផ្គាន ហើយមានឈាមពាសពេញកន្លែងនោះ។ រីឯសពកុមារដែលមានបែកក្បាលដូចជាគេបោកក្បាលទៅនឹងគល់ឈើ។ ក្រោយពីការសម្លាប់យួនមួយខ្សែនេះ ខ្ញុំមិនដែលប្រទះឃើញមានជនជាតិយួននៅសេសសល់ទៀតទេ។” លោកសាក្សី ចម្លើយរបស់លោកនៅក្នុងឯកសារហ្នឹងមិនដូចទៅនឹងចម្លើយដែលលោកបានឆ្លើយឥឡូវនេះទេ។ ដូច្នេះខ្ញុំចង់សួរថាតើចម្លើយពិតប្រាកដមួយណាជាចម្លើយដែលលោកឆ្លើយនៅពេលនេះ ឬក៏ជាចម្លើយដែលលោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត?

[០៩:១៣:១៥]

**លោក ព្រុំ សារុន៖**

**ឆ៖** សួរច្រើនរង្វេងអស់ហើយ វាចាស់ហើយ និយាយម្តងអ៊ីចេះ ម្តងអ៊ីចុះ។ យកចម្លើយមុនទៅ។

**ស៖** អ៊ីចឹងមានន័យថា លោកយកចម្លើយកាលពីលោកបានផ្តល់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេតដែលគេបានសម្ភាសលោកកាលពីឆ្នាំ២០០៨ ខ្ញុំដឹងថាវាយូរណាស់មកហើយ។ អ៊ីចឹងមានន័យថាលោកយកចម្លើយកាលពីឆ្នាំ២០០៨ ហ្នឹងមែនទេ?

**ឆ៖** បាទ វាភ្លេចអស់ហើយ យូរឆ្នាំហើយកាលនោះ។

**ស៖** លោកនិយាយអំពីក្មេងៗ លោកអាចរៀបរាប់បានទេ តើក្មេងៗហ្នឹងមានអាយុប៉ុន្មាន? ក្មេងខ្មែរក្រហមដែលទៅចាប់ជនជាតិវៀតណាមទាំងអស់ហ្នឹង?

**ឆ៖** ក្មេងៗដូចជាចាំអាយុវាប្រាំបី ប្រាំបួនឆ្នាំ ហ្នឹងឯងដែលទៅចាប់ ស្ពាយកាំភ្លើងអូសដីនៅឡើយ។ កូនកម្មាភិបាល អ្នកណាទៅហ៊ានតាមមើលគេ ថាគេចាប់បណ្តើរទៅ ដឹងគេទៅសម្លាប់ហើយសម័យនោះ តឹងរ៉ឹងដែរ ហ៊ានលួចគ្នាគេអី មិនបានទេ។ ដោះស្រាយតែខ្លួនឯងមិនចង់រួចផង។

**ស៖** ម៉េចបានជាលោកដឹងថា ក្មេងៗខ្មែរក្រហមហ្នឹងសម្លាប់អ្នកដែលពួកវាចាប់យកទៅហ្នឹង?

**ឆ៖** តែវាចាប់ទៅ គឺអ្នកទៅសម្លាប់ហើយ។ តែមិនឃើញមកវិញហ្នឹង សម្លាប់បាត់ហើយ។ តែចាប់យកទៅចងឃុំព័ទ្ធស្លាបសេកហើយ មិនដែលរួចខ្លួនទេ មិនមកវិញទេ។

**សៈ** កាលពីម្សិលមិញ គឺលោកបាននិយាយអំពីកន្លែងមួយទៀត គឺជាកន្លែងដែលគេនាំអតីតទាហាន លន់ នល់ ទៅ ខ្ញុំប្រហែលជាអានឈ្មោះកន្លែងនុំងមិនត្រូវ គឺអូរពងមាន់។ សូមអភ័យទោស បើខ្ញុំអានឈ្មោះនេះមិនត្រឹមត្រូវ។ លោកអាចបញ្ជាក់បានទេថា នៅអូរពងមាន់ហ្នឹងមានសាកសពទេ? ហើយអូរពងមាន់ហ្នឹងស្ថិតនៅទីណាដែរ?

**ឆៈ** អូរពងមាន់ហ្នឹងនៅពីលិចភូមិខ្ញុំ គេបញ្ជូនទាហានទៅហ្នឹងឯង មកឈប់នឹងភូមិខ្ញុំមួយខ្សែ។ ដល់មើលទៅគេមានបណ្តាស័ក្តិអី ទាញដៃទៅបាញ់ចោលនឹងច្រមុះភ្នំក្រពើហ្នឹងឯង។ ប្រពន្ធយំអោបទៅ បាញ់ទាំងពីរហ្នឹង ស្លាប់ទៅ នៅក្នុងភូមិក្រពើ មុខភ្នំក្រពើ ភូមិខ្ញុំហ្នឹងឯង។ ខ្ញុំទៅមើល ដើរទៅស្លាប់បាត់ហើយ យកទៅកប់ចោលហ្នឹងឯង។ គេបាញ់ហើយ គេមិនដែលកប់ទេ បើមិនកប់ស្អុយ។

[០៩:១៨:០១]

**សៈ** កាលពីម្សិលមិញ លោកមេធាវី ពេជ អង្គ សួរអំពីកន្លែងមួយទៀត ដែលស្ថិតនៅខាងត្បូងភ្នំកុយ ដែលកន្លែងនោះមានកូនអូរមួយឈ្មោះថា "អូរតូច"។ អ៊ីចឹងកន្លែងហ្នឹង ជាកន្លែងផ្សេងមួយទៀតឬក៏យ៉ាងម៉េច? ហើយលោកទៅអូរតូចហ្នឹង ដែរឬទេ? ហើយទៅមានឃើញសាកសពទេ?

**ឆៈ** ទេ មានឃើញតែអត់បាយស្លាប់។ គេជម្លៀសពួកបរប៉ៃលិនអីមកនៅហ្នឹងឯង។ ឃើញថាអត់បាយស្លាប់។ ចុះមានធ្វើស្រែឯណាប៉ៃលិន។ បញ្ជូនមកទាំងខ្សែៗ គេកាក់នឹងស្នឹងទៅជូនទៅហ្នឹងឯងទៅអូរតូចហ្នឹងឯង។

**សៈ** កាលពីព្រឹកមិញ ក៏ដូចជាកាលពីម្សិលមិញ លោកបាននិយាយអំពីវត្តគិរីរម្យ ហើយខ្ញុំចង់ដឹងថា វត្តគិរីរម្យហ្នឹងជាកន្លែងសម្លាប់មនុស្សទេ? ហើយលោកធ្លាប់ទៅវត្តគិរីរម្យហ្នឹងទេ?

**ឆៈ** បាទ ជណ្តើរសហ្នឹងហើយ គិរីរម្យ។ ខ្ញុំទៅមើល សន្តិភាពហើយបានខ្ញុំទៅមើល។ គេទម្លាក់នៅល្អាងគិរីរម្យហ្នឹងឯង កន្លះល្អាង។

**សៈ** ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ លោកធ្លាប់ឃើញអ្នកណាត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅវត្តគិរីរម្យដែរឬទេ?

**ឆៈ** អត់ធ្លាប់ឃើញទេ ឃើញតែសាកសព តាអឿម មេបញ្ជាការខ្ញុំមុនគេវៃចោលខាងជើងភ្នំសំពៅហ្នឹងឯងចន្លោះក្តោងហ្នឹងឯង។ ខ្ញុំទាហានដែរហ្នឹង។

**សៈ** ឥឡូវនេះ ខ្ញុំនិយាយអំពីប្រធានបទមួយផ្សេងទៀត គឺខ្ញុំនិយាយអំពីកន្លែងឃុំឃាំង គឺមន្ទីរឃុំឃាំង។ កាលពីម្សិលមិញ លោកនិយាយអំពីកន្លែងមួយឈ្មោះថា ចន្លោះក្តោង ជាកន្លែងដែលគេឃុំ

មនុស្ស ហើយក៏មានមន្ទីរឃុំឃាំងមួយទៀតដែលជិតភូមិសំណាញ់។ ដូច្នេះ ខ្ញុំចង់ដឹងថាតើចន្លោះក្តោង ហើយនិងកន្លែងឃុំមួយទៀតនៅភូមិសំណាញ់ ហ្នឹងជាកន្លែងតែមួយហ្នឹងមែនទេ ឬក៏ជាកន្លែងឃុំពីរផ្សេងគ្នា?

**ផ៖** ឃុំក្តោងអីចេះ! ភូមិក្តោងមិនដឹង ចន្លោះភ្នំ ហើយកន្លែងឃុំខ្លួនហ្នឹង ជណ្តើរសហ្នឹង គិរីរម្យ។

**ស៖** ចុះមានកន្លែងដែលគេឃុំមនុស្សទេនៅក្នុងឃុំក្តោងហ្នឹង? ឬក៏នៅភូមិសំណាន -- ភូមិសំណាញ់ លោកធ្លាប់ឮគេនិយាយអំពីការឃុំមនុស្សនៅភូមិសំណាញ់ ហ្នឹងទេ?

**ផ៖** មានភូមិសំណាញ់ មាន ប៉ុន្តែមិនមែនឃុំទេ មិនមានឃុំខ្លួនទេ នៅតែជណ្តើរសហ្នឹង វិហារហ្នឹងឯង គេឃុំខ្លួនមនុស្សនោះ មានខ្នោះមានអីនៅហ្នឹងឯង ហើយទម្លាក់នៅល្អាងគិរីរម្យហ្នឹងឯង។ សម្លាប់ហើយទម្លាក់នៅល្អាងគិរីរម្យហ្នឹង ជិតគ្នាហ្នឹង។

**ស៖** តើលោកធ្លាប់ឮកន្លែងមួយដែលឃុំមនុស្ស ដែលស្ថិតនៅក្នុងភូមិល្ងួយ?

**ផ៖** មិនដឹងភូមិល្ងួយនៅឯណាទេ។ មិនមានភូមិល្ងួយផង។

**ស៖** កាលពីម្សិលមិញ គឺលោក អ៊ឹម អាន់ ដែលជាសាក្សីមួយរូបដែរ ជាព្រះសង្ឃបាននិយាយអំពីឈ្មោះស្ត្រីម្នាក់ឈ្មោះ យាយណៃ គឺកំណត់ហេតុស្តាប់ចម្លើយ អ៊ឹម អាន់ ឯកសារ E3/7737, ERN ជាភាសាអង់គ្លេសគឺ 00274160, ERN ជាភាសាបារាំង 00226156 និង ERN ជាភាសាខ្មែរគឺ 00197883។ តើលោកធ្លាប់ឮគេនិយាយពីស្ត្រីម្នាក់ឈ្មោះ យាយណៃ ទេ?

**ផ៖** អត់ដែលស្គាល់ទេ យាយណៃ។

[០៩:២៥:០២]

**ស៖** ខ្ញុំមានប្រធានបទពីរទៀតដែលត្រូវពិភាក្សាជាមួយលោក ដំបូងគឺការមកដល់របស់កម្មាភិបាលនិរតី។ តើលោកចាំថាលោកបានឃើញកម្មាភិបាលមកពីនិរតីទេ? គឺមកក្នុងតំបន់របស់លោក លោកចាំថាមានរឿងអ្វីកើតឡើងទេពេលហ្នឹង?

**ផ៖** អត់ដែលស្គាល់កម្មាភិបាលនិរតីទេ មានតែកងធំ កងតូចខ្ញុំប៉ុណ្ណឹងឯង វរៈខ្ញុំហ្នឹងឯង ស្គាល់តែប៉ុណ្ណឹងឯង។

**ស៖** នៅឆ្នាំ១៩៧៧ តើមានការចាប់ខ្លួនកម្មាភិបាលនៅក្នុងឃុំនៃ -- ក្នុងឃុំ ក្នុងស្រុក ក្នុងតំបន់ដែរឬទេ? ហើយក្រោយមក មានអ្នកណាផ្សេងមកជំនួសកម្មាភិបាលទាំងអស់ហ្នឹងទេ?

**ឆ៖** មានកម្មាភិបាលឃោធាអី? បើកម្មាភិបាលឃោធា គណៈឃុំ មានតាឆេង មកជំនួស តាឆាំ អស់ពី តាឆាំ ទៅ តាឆេង មកជំនួស។

[០៩:២៦:៤២]

**ស៖** គេមានប្រាប់លោកទេថា ហេតុអ្វីបានជា តាឆេង មកជំនួស តាឆាំ?

**ឆ៖** គេថាផ្លាស់ តាឆាំ ហើយ មកតាឆេង ម្តង។

**ស៖** ខ្ញុំយល់អំពីចំណុចនេះ ក៏ប៉ុន្តែលោកមានបានចូលក្នុងការប្រជុំណាមួយដែលគេបានចោទ តាឆាំ ឬកម្មាភិបាលណាផ្សេងទៀតថាជាជនក្បត់ទេ?

**ឆ៖** មានគេហៅប្រជុំថា តា១ -- អី ភ្លេចឈ្មោះ -- ថាក្បត់ គេប្រជុំថា វាយចោលហ្នឹងចុងផ្លាន ពីរនាក់គេមកប្រជុំ គេកោះប្រជុំហៅទាំងអស់ ប៉ុន្មានវរៈហ្នឹងមកទាំងអស់។ ឃើញវាយហ្នឹងចុងផ្លាន ពីរនាក់។ តាដោក –ឈ្មោះ តាដោក– និងកូន។ គេថាមកប្រជុំកម្ទេចមនុស្សបះបោរ ប៉ុណ្ណឹង។ គេហៅ "កម្ទេច" ពាក្យគេ។

**ស៖** ប្រហែលជាខ្ញុំច្រឡំលោកសាក្សី ក៏ប៉ុន្តែកាលពីម្សិលមិញនេះ លោកនិយាយថា តាដោក នេះ ត្រូវបានគេចាត់ទុកថាជាខ្មាំង ដោយសារតែគាត់ជាអតីតទាហាននៃរបបលន់ នល់?

**ឆ៖** ខ្ញុំឆ្លើយថាម្សិលមិញ គាត់លាក់អាវុធទុកតើ បានគេកម្ទេចហ្នឹង ឆ្លើយម្សិលមិញអីចឹងឯង។

**ស៖** បាទ សូមអរគុណ។ ចុះអាវុធហ្នឹងជាអាវុធដែលគាត់មានមកតាំងពីពេលដែលគាត់ធ្វើជា ទាហានលន់ នល់ មែនទេ?

**ឆ៖** មិនដឹងគេលាក់ទុកពីថ្មើរម៉ាន បើខ្ញុំមិនដឹង ផ្ទះឆ្ងាយគ្នាដែរ។ គេថាគេលាក់អាវុធទុកហ្នឹង បានគេកម្ទេចហ្នឹង។ គេរកអាវុធឃើញដឹង! បានគេកម្ទេចទាំងឪ ទាំងកូន។

[០៩:២៨:៥៩]

**ស៖** បាទ សូមអរគុណ។ តើលោកចាំទេ ថានៅក្នុងភូមិ ឬឃុំរបស់លោក មានជនជាតិចាមដែរ ឬទេ ដែលរស់នៅក្បែរៗនឹងជនជាតិខ្មែរដែរនោះ?

**ឆ៖** អត់មានទេ មានតែចិន វរៈខ្ញុំមានតែចិន។ គេបញ្ជូនជនជាតិចិនឲ្យនៅនឹងឯង វរៈ១ មិនមាន ចាមទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណដល់លោកសាក្សីដែលបានឆ្លើយបញ្ជាក់នូវសំណួររបស់ខ្ញុំ។

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដែលដំបូងនេះ ផ្តល់វេទិកាទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរសួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[០៩:៣១:១៩]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំនឹងចាប់ផ្តើមសួរសំណួរបន្តមួយចំនួនទាក់ទងទៅនឹងជនជាតិចាម។ តើលោកស្គាល់ខ្លះ អំពីអ្វីខ្លះអំពីមនុស្សឈ្មោះ ឆាំ ដែលថាវាមានទំនាក់ទំនងអ្វីខ្លះ គាត់នៅភូមិភាគពាយ័ព្យកាលនោះ?

**លោក ព្រុំ សារុន៖**

**ឆ៖** កាលនោះ គាត់ប្រើឲ្យទៅលើទំនប់កំពីងកំពួយហ្នឹង គាត់នៅផ្ទះហ្នឹងឯង អែបសំណង់ហ្នឹងឯង។ គាត់ធ្វើផ្ទះនៅហ្នឹងឯង តាឆាំ។ ក្រោយមកបាត់ខ្លួន មិនដឹងទៅណាបាត់។ បានឡើង តាឆេងមក។ ខ្ញុំដឹងតែប៉ុណ្ណឹងឯង។

**ស៖** តើលោកដឹងថា តើមានកម្មាភិបាលដឹកនាំផ្សេងទៀតទេនៅទំនប់កំពីងកំពួយឈ្មោះ ឆាំ ដែរឬទេ? ឬក៏មានតែ -- ឬក៏ថាមានមេដឹកនាំម្នាក់ដែរ នៅកំពីងកំពួយ ឈ្មោះ តាឆាំ នោះ?

**ឆ៖** តាឆាំ វត់បាត់ទៅ ឡើង តាឆេង មកតែប៉ុណ្ណឹង។ ខ្ញុំដឹងតែប៉ុណ្ណឹងឯង។

**ស៖** តើលោកដឹងដែរឬទេ តាឆាំ ក៏ជាអនុទទួលបន្ទុកខាងសេដ្ឋកិច្ចនៅក្នុងភូមិភាគពាយ័ព្យ។ តើលោកបានដឹងទេ?

**ឆ៖** អត់ដឹងគាត់ទៅណាទេ មិនសួរ -- ម៉ានសួរគេផង។ គេបាត់ ដឹងតែបាត់ទៅ មិនម៉ានសួរគេទេ ដេញដោលអីសម័យហ្នឹង សម័យផ្តាច់ការ ខ្ញុំមិនម៉ានដេញដោលគេទេ គេប្រើឲ្យធ្វើអីធ្វើហ្នឹងលើកទំនប់ លើកទំនប់ហើយ។

[០៩:៣៣:៥៣]

**ស៖** ប្រហែលជាសំណួររបស់ខ្ញុំមិនច្បាស់។ មុនពេលដែលគាត់ទៅការដ្ឋានទំនប់ តើគាត់ជាប្រធាន ឬក៏អនុប្រធានខាងសេដ្ឋកិច្ចនៅក្នុងភូមិភាគពាយ័ព្យដែរឬទេ ខ្ញុំនិយាយពីឈ្មោះ តាឆាំ?

**ឆ៖** តាឆាំ គាត់គណៈស្រុកដែរ មិនដឹងគាត់ទៅឯណាបាត់ទៅ បានឡើង តាឆេង ហ្នឹង។ ខ្ញុំមិនដឹងដែរហ្នឹង។ ស្រាប់តែបាត់ខ្លួនគាត់ទៅ ណាហ៊ានសួរគេ។

**ស៖** ខ្ញុំយល់។ តើលោកស្គាល់ឈ្មោះ នាមត្រកូល ហើយនិងនាមខ្លួនគាត់ទេ? តើឈ្មោះគាត់ ទិន ឆាំ ឬក៏ឈ្មោះអ្វី ឈ្មោះពេញរបស់គាត់?

**ឆ៖** អត់ ខ្ញុំស្គាល់តែ តាឆាំៗ គេហៅតែ តាឆាំ។ មិនដែលស្គាល់ត្រកូលគាត់ទេ ហៅតែ តាឆាំៗ តែម្តងបាទ។

**ស៖** ហើយលោកនិយាយអំពីប្រធានរបស់គាត់ ហើយពេលដែលបាត់គាត់ទៅ ឆេង មកជំនួសគាត់។ តើលោកដឹងថានៅក្នុងឆ្នាំណាទេដែលៗ តាឆេង មកជំនួស តាឆាំ ហ្នឹង? តើលោកចាំខែ ឬចាំឆ្នាំទេ?

**ឆ៖** ទេ ឆ្នាំវង្វេង ភ្លេចអស់ហើយ។

**ស៖** តើអាចខែមករា ឆ្នាំ១៩៧៨ ឬទេ?

**ឆ៖** បាទ ប៉ុណ្ណឹងឯង ខ្ញុំភ្លេចអស់ហើយឆ្នាំនោះ។

**ស៖** តើលោកធ្លាប់ឮតំបន់៥ ហើយប្រធានតំបន់៥ ឈ្មោះ តាហ៊ីង្ស។ ធ្លាប់ឮទេ?

**ឆ៖** អត់ៗស្គាល់ទេ តាហ៊ីង្ស ហ្នឹងឯង។ មិនដែលស្គាល់ តាហ៊ីង្ស ហ្នឹងទេ។

[០៩:៣៦:៣៥]

**ស៖** មិនអ្វីទេលោកសាក្សី។ ខ្ញុំត្រឡប់ទៅរកសំណួរមួយចំនួនអំពីរូបលោក ខ្ញុំយល់ថានៅពេលមួយមុនឆ្នាំ១៩៧៥ លោកបានធ្វើជាទាហាននៅក្នុងរបបសាធារណរដ្ឋខ្មែរ។ ហើយនៅក្នុងវរសេនាតូច ១៦៤។ តើត្រឹមត្រូវអីចឹងទេ?

**ឆ៖** ត្រឹមត្រូវ ១៦៤។

**ស៖** តើលោកនៅចាំថាឆ្នាំណាទេ ដែលលោកបានធ្វើជាទាហាននៅក្នុងសាធារណរដ្ឋខ្មែរនោះ?

**ឆ៖** ធ្វើបានមួយឆ្នាំគេបញ្ជូនទៅថៃបាត់ទៅ។ ទៅរៀននៅថៃណោះមួយឆ្នាំហ្នឹង បីខែគេបញ្ជូនមកបាតាយ៉ុងនេះវិញ បាតាយ៉ុង១៦៤វិញ។

**សះ** នៅពេលដែលគេបញ្ជូនឲ្យទៅរៀននៅថៃ។ តើពេលហ្នឹងលោកនៅជាទាហាន គឺកងទ័ពដែលបញ្ជូនលោកទៅរៀននៅក្នុងប្រទេសថៃ។ តើអ៊ីចឹងឬ?

**ឆះ** បាទ មកវិញក៏មកនៅ១៦៤វិញ ទៅរៀនបីខែ។

[០៩:៣៨:៣៤]

**សះ** តាមដែលខ្ញុំយល់ បើខ្ញុំយល់មិនខុសទេលោកធ្វើទាហានប្រាំបីឆ្នាំ ហើយទៅរៀននៅថៃមួយឆ្នាំ ហើយត្រឡប់មកវរសេនាតូច១៦៤ ហើយ -- អ៊ីចឹងបើនិយាយទៅយើងសរុបថា លោកបានធ្វើទាហានហ្នឹង គឺពីរឆ្នាំបីខែអ៊ីចឹងឬ?

**ឆះ** បាទ។

**សះ** ហើយបន្ទាប់ពីបីខែចុងក្រោយនោះមក។ តើភូមិភាគហ្នឹងត្រូវបានរំដោះរួចហើយ ឬក៏គេរំដោះភូមិភាគនៅឆ្នាំ១៩៧៥? ឬក៏គេរំដោះបាននៅក្នុងរយៈពេលបីខែដែលលោកនៅជាទាហាននៅឡើយនោះ?

**ឆះ** នៅទាហាន បញ្ជូនមកព្រៃស្វាយបានមួយឆ្នាំ បានសន្តិភាព អង្គុលតែរួចខ្លួនផង ដើរសុំខោអាវស៊ីវិលគេស្លៀកពាក់ដើរមកភូមិ។ សន្តិភាពបានខ្ញុំ គេចត្រឡប់មកវិញ។

**សះ** ដូច្នេះ សរុបទាំងអស់មក គឺលោកបានធ្វើជាទាហានបីឆ្នាំកន្លះ។ តើអ៊ីចឹងត្រឹមត្រូវទេលោកសាក្សី?

**ឆះ** បាទ ត្រឹមត្រូវហើយ។

**សះ** នៅពេលដែលលោកចូលធ្វើជាកងទ័ព ហើយលោកក៏បានរស់នៅភូមិត្រពាំងជើង។ អ៊ីចឹងដែរឬទេ?

**ឆះ** ក្រពើជើងទាន មិនមែនត្រពាំងជើងទេ – ក្រពើខាងជើង។

**សះ** បាទ សូមអភ័យទោស ខ្ញុំអានវាមិនសូវចំ ភូមិក្រពើខាងជើង។ តើនេះជាកន្លែង ដែលលោករស់នៅ ពេលដែលដំបូងលោកធ្វើជាទាហានហ្នឹង គឺចូលធ្វើពេលដែលលោករស់នៅភូមិក្រពើជើងនេះឯង?

**ឆះ** បាទ ខ្ញុំស្រុកកំណើតខ្ញុំនៅហ្នឹងឯង ក្រពើជើងហ្នឹងឯង។

**សះ** តើត្រឹមត្រូវទេ នៅថ្ងៃ -- នៅខែមេសា ឆ្នាំ១៩៧៥ គឺមនុស្សភាគច្រើននៅភូមិក្រពើខាងជើង ហើយនៅពេលនោះដែរក៏លោកបានធ្វើជាទាហានសម័យនោះប្រហែលជាពីរឆ្នាំរួចមកហើយដែរ?

**ឆ៖** បាទ ត្រឹមត្រូវហើយ ពីរឆ្នាំ។

**ស៖** អ៊ីចឹងកម្មាភិបាលដែលមកពីៗខាងខ្មែរក្រហមក៏ដឹងថា នៅឆ្នាំ១៩៧៥ លោកក៏ជាទាហានរបស់សាធារណរដ្ឋខ្មែរ?

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** នៅក្នុងចម្លើយរបស់លោកទៅអ្នកស៊ើបអង្កេត លោកនិយាយថា បន្ទាប់ពីឆ្នាំ១៩៧៥ កម្មា-ភិបាលតាមដានលើរូបលោក។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ គេតាមដានទាហាន ប៉ុន្តែគេទាហានគេទុកថា ខ្ញុំនាំគេធ្វើការល្អ ខំធ្វើការល្អ ទាំងយប់ទាំងថ្ងៃ មិនដែលថ្ងូរ មិនដែលត្អូញត្អែរអីទេ បានគេទុក។

[០៩:៤៣:២៥]

**ស៖** ហើយលោកក៏បានបញ្ជាក់នៅក្នុង -- នៅកំណត់ហេតុស្តាប់ចម្លើយ E3/5187 នៅទំព័រអង់គ្លេស 00274179, ខ្មែរ 00197918, បារាំង 00274186 "គេឲ្យខ្ញុំធ្វើប្រវត្តិរូបមួយឆ្នាំម្តងឲ្យវរសេនាតូច ដើម្បីផ្ញើទៅថ្នាក់លើ"។ តើលោកបានឆ្លើយអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ គេឲ្យធ្វើប្រវត្តិរូបមែន មួយឆ្នាំម្តងៗ ពិតប្រាកដមែន។

**ស៖** តើលោកស្គាល់សមាជិកណាផ្សេងទៀតនៅក្នុងវរសេនាតូច១៦៤ ដែរឬទេ ដែលថានៅឆ្នាំ១៩៧៥ បានឈប់ធ្វើជាកងទ័ព ឈប់ធ្វើទាហាន ហើយបានធ្វើប្រវត្តិរូប ហើយត្រូវបានគេតាមដានដូចរូបលោកដែរឬទេ?

**ឆ៖** គេតាមដានតែខ្ញុំឯង ប៉ុន្តែគេទុក។ គេថាគេទុក ធ្វើការល្អ គេទុកសិន។ ប្រឹងធ្វើការណាស់បានបានរួចខ្លួន។

**ស៖** ប៉ុន្តែ តើលោកស្គាល់ទាហាន លន់ នល់ ផ្សេងទៀតដែរឬទេ ដែលក្រោយពេលដែលគេឈប់ធ្វើជាទាហានហ្នឹងត្រូវបានគេឲ្យធ្វើប្រវត្តិរូបនៅក្នុងស្រុក ឬក៏ក្នុងតំបន់ដែលលោករស់នៅកាលនោះដែរឬទេ?

**ឆ៖** ធ្វើឲ្យតែទាហាន គេធ្វើប្រវត្តិរូបទាំងអស់គ្នាហ្នឹង ប៉ុន្តែមេកងខ្ញុំគេវៃចោល មានចន្លោះក្តោងហ្នឹងឯង មេកង អឿន – ឈ្មោះអឿន– គេវៃចោលមេកង។ ខ្ញុំភ័យដែរហ្នឹង ប៉ុន្តែថាគេទុកប្រើមួយរយៈសិន។

[០៩:៤៥:២៦]

**ស៖** តើលោកដឹងដែរឬទេនៅខែមេសា ឆ្នាំ១៩៧៥ ទាហាន លន់ នល់ ត្រូវបានគេតម្រូវឲ្យប្រមូលផ្តុំគ្នានៅវត្តសំពៅ?

**ឆ៖** អត់ដឹងទេ ខ្ញុំនៅឆ្ងាយពីក្រុងដែរហ្នឹង។

**ស៖** ខ្ញុំសូមអានសេចក្តីដកស្រង់ខ្លីចេញពីចម្លើយរបស់មនុស្សម្នាក់ដែលបានផ្តល់ចម្លើយ ហើយសហព្រះរាជអាជ្ញាបានអានម្សិលមិញ ឯកសារ E3/5211, ខ្មែរ ERN 00221544 ទៅដល់ 45, បារាំង 00485979, អង់គ្លេស 00275399។ សំណួរអ្នកស៊ើបអង្កេតសួរគាត់ថា៖ “តើលោកអាចបំភ្លឺតើមានរឿងអ្វីកើតឡើងទៅទាហាន លន់ នល់ ក្រោយពីតានាំ បានប្រកាសតាមមីក្រូ? សាក្សីរូបនោះឆ្លើយថា៖ នៅពេលព្រឹក បន្ទាប់ពីការប្រកាសតាមមីក្រូរបស់ តានាំ ហើយខ្ញុំបានឃើញទាហានរបស់តានាំ រាប់រយបានដកអាវុធ និងសម្ភារៈយោធាពីទាហាន លន់ នល់ ប្រហែលជាទាហាន ៤០០ ទៅ ប្រាំនាក់បានប្រមូលគ្នានៅវត្តសំពៅ។ ពីរឬបីថ្ងៃក្រោយមកគឺគេយកឡានដឹកទាហានលន់ នល់ទាំងអស់នោះទៅអូរពងមាន់ នៅក្នុងឃុំបាណន់ ស្រុកបាណន់ ដើម្បីឲ្យពួកគេធ្វើការនៅវាលស្រែ។” បញ្ចប់សេចក្តីដកស្រង់។

តើលោកស្តាប់ទៅ លោកអាចដឹងព័ត៌មានបែបនេះទេ គឺការប្រមូលទាហាន ៣០០ ទៅ៤០០ នាក់ អតីតទាហានលន់ នល់ ហើយគេដឹកឲ្យទៅធ្វើការងារនៅការដ្ឋានធ្វើស្រែនោះ?

**ឆ៖** អត់ដឹងដល់ទេ ខ្ញុំមិនដឹង។ មិនដឹកតាមណាអីតាមណា ខ្ញុំមិនដឹង ខ្ញុំអាល័យការងារបាត់ហើយ។

**ស៖** ខ្ញុំសូមសួរសំណួរផ្សេងពីនេះ។ តើលោកបានឮរឿងរ៉ាវនៅពេលនោះទេ ឬក៏លោកដឹងដែរទេថាទាហានលន់ នល់បន្ទាប់ពីគេដោះដកអាវុធហើយ គេបញ្ជូនទៅឲ្យធ្វើការដ្ឋានតាមការដ្ឋានវាលស្រែ ឬក៏ឲ្យធ្វើនៅចម្ការកប្បាស ឬក៏កសិដ្ឋានចម្ការណាមួយដែរឬទេ?

[០៩:៤៩:៥៩]

**ឆ៖** អត់ដឹងទេ ថាពេលហ្នឹងហើយខ្ញុំមិនដឹងទេ ដោះស្រាយតែខ្លួនឯងមិនចង់រួចផង។

**ស៖** បាទ មិនអ្វីទេលោកសាក្សី ខ្ញុំមិននឹងបន្តទៅប្រធានបទមួយទៀត។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកដែលយោង -- លោកយោងទៅរកសុន្ទរកថារបស់លេខាគណៈភូមិភាគពាយ័ព្យឈ្មោះ មូល សម្បត្តិ ហៅថា រស់ ញឹម ឬក៏ហៅថាតាញឹម។ តើលោកនៅចាំថាលោកបាននិយាយទៅប្រាប់អ្នកស៊ើបអង្កេតថាលោកបានស្តាប់ឮសុន្ទរកថារបស់គាត់ដែរឬទេ?

**ឆ៖** គេហៅមកប្រជុំដែរនៅភ្នំសំពៅ គេថាឲ្យបង្កបង្កើនផលឲ្យបានហូបគ្រប់គ្រាន់ សុន្ទរកថា គេថាប៉ុណ្ណឹងឯង រស់ ញឹម។

**ស៖** តើលោកចាំព័ត៌មានសេចក្ដីលម្អិតអ្វីផ្សេងទៀតទេ នៅក្នុងសុន្ទរកថានោះ ចំណុចជាក់លាក់ ឬក៏លោកអាចនៅចាំភិនភាគរបស់ តាញឹម ទេ គាត់រូបរាងយ៉ាងម៉េច?

**ឆ៖** អត់ដែលស្គាល់ផងហ្នឹង មកតែប្រជុំម្ដង មិនបានមើលមុខគេផងហ្នឹង ឡើងឆ្ងាយនោះ ប្រជុំ គេហៅគ្រប់វរៈទាំងអស់ទៅប្រជុំ អង្គុយឆ្ងាយ សាលាភ្នំសំពៅគេធ្វើឡើងធំនៅពីក្រោយគេមើល មិនឃើញផង ឮតែមាត់។

**ស៖** តើលោកស្គាល់មនុស្សណាផ្សេងទៀតនៅពេលដែលនៅក្នុងគណៈភូមិភាគ បាទជាគណៈ ភូមិភាគពាយ័ព្យ។ អ្នកណាខ្លះដែលមានតំណែងក្រៅពី មូល សម្បត្តិ ហៅ តាញឹមហ្នឹង តើលោកស្គាល់ អ្នកផ្សេងទៀតទេនៅក្នុងគណៈភូមិភាគហ្នឹង?

**ឆ៖** អត់ស្គាល់ទេ គេស្លៀកពាក់ៗខ្មៅ មិនស្គាល់គេទេ មិនដែលឃើញមើលគេផង ទៅៗតែ វាលស្រែ ស្ទូងតែស្រូវ ដកសំណាបទៅ។

**ស៖** តើលោកធ្លាប់ឮឈ្មោះមនុស្សម្នាក់ហៅឈ្មោះ តាប៉ែត?

**ឆ៖** អត់ឮ អត់ដែលស្គាល់ទេ តាប៉ែត ហ្នឹង។

[០៩:៥៣:៥០]

**ស៖** ខ្ញុំអានសេចក្ដីដកស្រង់ចេញពីកំណត់ហេតុស្ដាប់ចម្លើយសាក្សីម្នាក់ទៀត។-- លោកប្រធាន គឺថាឯកសារ E3/5185, ខ្មែរ ERN 00197889, បារាំង 00226162, ភាសាអង់គ្លេស 00274166។ គេសួរសាក្សីរូបនេះនូវសំណួរថា៖ [តើលោកធ្លាប់ជួប ប៉ែត ដែរឬទេ? តើគាត់នៅរស់ ឬស្លាប់? គាត់ ឆ្លើយថា៖ ប៉ែត ធ្លាប់ធ្វើជាៗលេខាតំបន់ពីឆ្នាំ១៩៧៥-៧៩ ហើយគាត់បានស្លាប់ប្រហែលជានៅក្នុងឆ្នាំ ១៩៨៥-៨៦។ ខ្ញុំបានឃើញ តាប៉ែត នៅទំនប់កំពីងពួយ គាត់បានទៅមើលការដ្ឋាន ពិនិត្យការដ្ឋានម្ដង ក្នុងមួយអាទិត្យ។ កំពីងពួយគឺជាការដ្ឋានដែលគេប្រមូលមនុស្សជាច្រើនស្រុកមកខេត្តបាត់ដំបង ហើយ រួមទាំងអស់ជម្លៀសដែលមកក្នុងតំបន់៣ផង នៅពេល តាប៉ែត មកពិនិត្យការដ្ឋាន គាត់បានជួបមនុស្ស នៅការ-ដ្ឋានកំពីងពួយ ហើយគាត់បានប្រកាសតាមមីក្រូ សូមដកស្រង់ថា៖ “យើងត្រូវតែប្រកាន់គោល ជំហរបដិវត្តន៍ ដើម្បីវាយប្រយុទ្ធធ្វើការងារទាំងថ្ងៃទាំងយប់។” បញ្ចប់សេចក្ដីដកស្រង់។ គាត់និយាយ ប្រហែលជាមួយម៉ោងនៅក្នុងការប្រជុំនោះ។ ប៉ុន្តែខ្ញុំមិនចាំអ្វីៗទាំងអស់ដែលគាត់និយាយទេ។ ប៉ុន្តែគាត់

បាននិយាយពាក្យឃ្លាដដែលម្តងហើយម្តងទៀត។] តើលោកស្តាប់ទៅ តើអាចនឹងធ្វើឱ្យលោកនឹកឃើញ ឬក៏ចងចាំអំពីកម្មាភិបាលម្នាក់ដែលថាឈ្មោះ តាប៉ែត ជាលេខាហ្នឹង បានប្រកាសនៅការដ្ឋានទំនប់ហ្នឹង? តើលោកអាចនឹកឃើញ ឬក៏ចងចាំអ្វីទេ ក្រោយពីស្តាប់នេះ?

**ឆ៖** អត់នឹកឃើញទេ ទាន។ អត់នឹកឃើញ អត់ស្គាល់ តាប៉ែត ហ្នឹងផង។

**ស៖** ហើយក៏គេហៅគាត់ម្យ៉ាងទៀតថាឈ្មោះ តាកន្ទុល។ តើ តាកន្ទុល ហ្នឹងលោកធ្លាប់ឮឈ្មោះទេ ឬក៏ធ្លាប់ឃើញទេ?

**ឆ៖** អត់ដែលឃើញ តាកន្ទុល តាអីហ្នឹង។

**ស៖** ឈ្មោះពិតរបស់គាត់គឺ ហេង ទាវ។ គាត់ធ្វើជាកម្មាភិបាលថ្នាក់ខ្ពស់ សមាជិកថ្នាក់ខ្ពស់នៅក្នុងសាធារណរដ្ឋប្រជាមានិតកម្ពុជារវាងឆ្នាំ១៩៧០ -- ៧៩ ដល់ ១៩៨៥, ៨៦ ហើយគាត់ធ្វើជាក្រុមប្រឹក្សារដ្ឋក្រោមលោក ហេង សំរិន។ តើលោក ហេង ទាវ ធ្លាប់ធ្វើជាប្រធានសហជីពពាណិជ្ជកម្ម។ តើឈ្មោះនេះលោកធ្លាប់ឮ ឬក៏ធ្លាប់ដឹងដែរឬទេ?

**ឆ៖** បាទ អត់ធ្លាប់ដឹងទេ ហើយមិនធ្លាប់ឮផង។

**ស៖** បាទ ខ្ញុំនឹងបន្តទៅមុខទៀតលោកសាក្សី។ ខ្ញុំចូលទៅដល់ហេតុការណ៍ដែលលោកបានរៀបរាប់ពីម្សិលមិញ និងព្រឹកនេះ។ ដំបូងខ្ញុំនឹងទៅដល់ផ្នែកមួយដែលលោកនិយាយថា លោកបានឃើញយួនពីរនាក់ត្រូវបានគេចាប់ ហើយយកចេញទៅនៅពេលដែលលោកកំពុងធ្វើការ។ តើលោកអាចពន្យល់ប្រាប់ខ្ញុំថា តើលោកដឹងដោយរបៀបណា? ឬក៏លោកសន្និដ្ឋានថា ពួកគេ អ្នកទាំងពីរនាក់ដែលលោកបានឃើញនោះ គឺតាមពិតគឺជាជនជាតិវៀតណាមនោះ?

[០៩:៥៨:៤២]

**ឆ៖** ឃើញតែចងបណ្តើរទៅពីចម្ងាយ មិនដឹងជនជាតិស្អី។ មើលឃើញតែពីចម្ងាយ នរណាហ៊ានសួរគេ។

**ស៖** ដើម្បីឱ្យប្រាកដ តើលោកធ្លាប់ស្គាល់អ្នកទាំងពីរនាក់នោះទេ ដែលលោកបានឃើញដែលថា គេយកអ្នកពីរនាក់ចេញទៅហ្នឹង ធ្លាប់ស្គាល់ពីមុនទេ?

**ឆ៖** ទំនងសម្រាប់ខ្ញុំមិនស្គាល់ទេ បញ្ជូន។ គេបញ្ជូនមកដាក់ទាំងភូមិខ្ញុំហ្នឹង មិនដឹងថា អ្នកណាអ្នកណី ខ្ញុំមិនស្គាល់ទេ រវល់សកម្មការងារដែរ មិនមែនដើរលេងផ្តេសផ្តាសណាបាន ការងារ។ ឆ្លងទៅពីភូមិមួយទៅវរៈមួយអី ម៉េចក៏មិនបានដែរ វរៈដទៃនោះ ទៅមិនបានទេ គេតឹងតែងដែរហ្នឹង។ រវល់តែ

ដកស្ងួងៗ រាល់ថ្ងៃហ្នឹង។

[១០:០០:០០]

**ស៖** ម្សិលមិញ ហើយនិងព្រឹកនេះ ខ្ញុំជឿថា លោកនិយាយអំពីសមាជិកក្រុមគ្រួសារវៀតណាម មិននៅក្នុងកងវរៈរបស់លោកទេនៅក្នុងកងវរៈផ្សេង។ តើលោកស្គាល់អ្នកណាម្នាក់ជាបុគ្គល ដូចថា ស្គាល់ឈ្មោះឲ្យពិតប្រាកដដែរឬទេ?

**ឆ៖** អត់ដែលស្គាល់ឈ្មោះទេ មិនដែលសួរឈ្មោះគេទេ។

**ស៖** លោកដែលនិយាយលេងជាមួយពួកគេទេ?

**ឆ៖** ខ្ញុំមិនដែលនិយាយលេងទេ ព្រោះជួបគ្នានិយាយលេងអីក៏មិនបានដែរ ខំធ្វើការទេ សម័យនោះ។

**ស៖** តើត្រឹមត្រូវទេ បើខ្ញុំនិយាយថា លោកមិនដឹងថា ពួកគាត់ទាំងនោះជាជនជាតិវៀតណាម ឬក៏ជាខ្មែរទេ អ៊ីចឹងឬក៏អត់ទេ?

**ឆ៖** មិនដឹងទេ ទាន មិនដឹងគាត់ជនជាតិវៀតណាម ឬជនជាតិអីទេ ខ្ញុំមិនដែលដឹង។ មិនសួរគេផង មិនប៊ានសួរគេផង រកតែអាយុខ្លួនឯងរួចខ្លួនបានហើយ។ គ្មានអ្នកណាជួយអ្នកណាបានទេ ពេលនោះ តែគេថាវ៉ៃចោលៗហើយ។

**ស៖** តើត្រឹមត្រូវដែរទេ បើខ្ញុំនិយាយថា ចម្លើយរបស់លោកដែលថា អាច អ្នកទាំងនោះអាចជាជនជាតិវៀតណាម។ តើនេះជាសេចក្តីសន្និដ្ឋានដោយយោងទៅលើសំណួរមុនដែល តាក្រច សួរទៅលោក ថាតើនៅក្នុងកងតូចរបស់លោកហ្នឹង មានជនជាតិវៀតណាមដែរឬក៏អត់?

[១០:០២:៣៩]

**ឆ៖** ខ្ញុំប្រាប់ហើយថាមានតែចិនទេ អត់មានជនជាតិវៀតណាមទេ។ តាក្រច សួរហ្នឹង ថាខ្ញុំមានតែចិនទេ នៅកងខ្ញុំនោះ។

**ស៖** ខ្ញុំយល់ហើយលោកសាក្សី ប៉ុន្តែម្សិលមិញនិងព្រឹកមិញនេះ លោកនិយាយអំពីអ្នកដែលគេចាប់ខ្លួន គឺថាអាចត្រូវបានគេសម្លាប់ចោល ហើយលោកហាក់បីដូច -- លោកបញ្ជាក់ថា ហាក់បីដូចជាលោកបញ្ជាក់ថាគឺជាជនជាតិវៀតណាម។ ខ្ញុំដឹងថានេះគឺជាសេចក្តីសន្និដ្ឋានមួយដោយយោងទៅលើសំណួរដែល តាក្រច នេះ បានសួរមកលោក អ៊ីចឹងដែរឬក៏អត់ទេ?

**ឆ៖** តាក្រច សួរមករកតែវៀតណាម ខ្ញុំឆ្លើយថាមានតែចិនទេនៅកងខ្ញុំនោះ កងតូចខ្ញុំនោះ អត់

មានវៀតណាមទេ។

**ស៖** បាទ មិនថ្វីទេលោកសាក្សី។ ឥឡូវ ខ្ញុំសូមត្រឡប់ទៅសំណួរដែលខ្ញុំសួរលោកពីខាងដើម អំពី តាឆាំ។ តាឆាំ គឺថា ត្រូវបានដាក់ជំនួសដោយ តាឆេង ខ្ញុំគិតថានោះគឺនៅខែមករា ១៩៧៨។ សំណួររបស់ខ្ញុំ ថាតើលោកអាចនឹកឃើញឡើងវិញទេថា វាមានរយៈពេលប៉ុន្មានខែដែរ នៅពេលដែល តាក្រូច នេះសួរសំណួរនេះមកកាន់លោក ហើយមុនពេលដែលជនជាតិចាមបាត់ខ្លួនទៅ។ តើ តាក្រូច សួរមកលោកនេះ សួរមុនពេលចាមបាត់ខ្លួន -- មុនពេល តាឆាំ បាត់ខ្លួន ឬក៏សួរយូរមកហើយ?

**ឆ៖** យូរមកហើយហ្នឹង។ តាក្រូច ក្តាប់កងខ្ញុំមុនគេហើយ វរៈខ្ញុំ តាក្រូច។

[១០:០៩:៥៨]

**ប្រធានអង្គជំនុំ៖**

លោកអ្នកបកប្រែភាសា ដូចជាស្តាប់ឲ្យបានច្បាស់លាស់ ហើយអត់មានចាមទេនៅអង្គហេតុនេះ។ អង្គហេតុនេះមានតែឈ្មោះ ឆាំ ហើយច្រឡំ ឆាំ ទៅបកចាមហ្នឹង វាអង្គហេតុចាម វានៅក្នុងអង្គហេតុសួរពាក់ព័ន្ធជាមួយនឹងរឿងគោលដៅវៀតណាម វាច្របូកច្របល់។ តាមពិត ឈ្មោះឆាំ ទេ ដល់ពេលទៅបកប្រែថាចាមហ្នឹង វាទៅជាអង្គហេតុហ្នឹងពិបាកយល់ហើយ។ ប្រយ័ត្នបន្តិចបាទ ប្រយ័ត្នក្នុងការបកប្រែ ព្រោះចាម ហើយនិង ឆាំ ហ្នឹង វាស្រដៀងគ្នាណាស់!

**លោក វ៉ិចទ័រ កូប៉េ៖**

មេធាវីក៏សូមអធ្យាស្រ័យដែរ ដោយអានមិនច្បាស់ គឺមិននិយាយពីចាមទេ គឺនិយាយពីតាឆាំ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមសួរសំណួរឡើងវិញ។ លោកសាក្សី យើងមានបញ្ហាអំពីការបាត់ខ្លួន តាឆាំ ហើយក៏មានសំណួរពាក់ព័ន្ធទៅនឹង តាក្រូច។ តើវាមានរយៈពេលប៉ុន្មានដែរ ចន្លោះពេលដែល តាក្រូច សួរទៅលោក និងពេលដែលបាត់ខ្លួនតាឆាំ?

[១០:០៦:៣៦]

**លោក ព្រុំ សារុន៖**

**ឆ៖** រយៈពេលមួយឆ្នាំ បានតាក្រូច សួរខ្ញុំ។ បាត់ខ្លួនមួយឆ្នាំ បានតាក្រូច សួរថាមានជនជាតិយួនអីៗហ្នឹង។ តែប៉ុណ្ណឹងឯង។

**ស៖** ប្រហែលជាខ្ញុំស្តាប់មិនទាន់ អ៊ីចឹងខ្ញុំសូមសួរបញ្ជាក់បន្តិច។ មួយណាមុន សំណួររបស់

តាក្រូច ដែលសួរ តើមានជនជាតិវៀតណាមនៅកន្លែងលោកទេ និងការបាត់ខ្លួនតាឆាំ។ ពីរហ្នឹងអ្នកមួយណាមុន?

**ឆ៖** បាត់ខ្លួនតាឆាំ មុន បានតាក្រូច សួរខ្ញុំក្រោយ។

**ស៖** បើដូច្នេះ តើខ្ញុំអាចនិយាយថាសំណួររបស់ តាក្រូច អាចសួរទៅលោកក្នុងឆ្នាំ១៩៧៨ ហើយគិតថា តាឆាំ ហ្នឹងត្រូវបានចាប់ខ្លួននៅខែមករា ១៩៧៨ ទៅចុះ?

**ឆ៖** ហ៏! ចម្លើយហើយអាហ្នឹង។

**ស៖** ខ្ញុំសូមរៀបសំណួរឡើងវិញលោកសាក្សី លោកសាក្សី លោកនឹកឃើញទេថាក្នុងខែតុលា -- កញ្ញា តុលា ១៩៧៧ មានការឈ្លានពានទ្រង់ទ្រាយធំពីសំណាក់កងទ័ពវៀតណាមមកចូលមកក្នុងដែនដីរបស់កម្ពុជាប្រជាធិបតេយ្យ លោកនឹកឃើញទេ?

**ឆ៖** ចូលឆ្នាំប៉ុន្មានទេ ខ្ញុំមិនចាំឆ្នាំផង។ មិនចាំឆ្នាំទេ វៀតណាមមកចូលរំដោះ។ ភ្លេចឆ្នាំអស់ហើយ។

[១០:០៩:៤៤]

**ស៖** ខ្ញុំសូមសួរសំណួរមួយចុងក្រោយលោកប្រធាន។ កងទ័ពវៀតណាម បានឈ្លានពានមកលើអធិបតេយ្យភាពរបស់កម្ពុជាប្រជាធិបតេយ្យ យ៉ាងហោចណាស់ក៏ពីរលើកដែរ។ ម្តងក្នុងឆ្នាំ១៩៧៨ គឺ -- សូមដកស្រង់ "គឺនៅពេលប្រទេសរំដោះ ហើយម្តងទៀត នៅក្នុងខែកញ្ញា តុលា ១៩៧៧"។ លោកធ្លាប់ដែរឮសួរការវាយលុកចូលរបស់កងទ័ពវៀតណាមនេះទេ?

**ឆ៖** ធ្លាប់។ ឃើញតែគេមករំដោះនឹងភូមិហ្នឹង រត់ចូលមក វៀតណាមរត់មករំដោះហ្នឹង។ ខ្ញុំមិនចាំឆ្នាំ ភ្លេចឆ្នាំអស់ហើយ។

**ស៖** បាទសំណួរមួយចុងក្រោយបំផុត។ តើលោកអាចនិយាយបានទេ អំពីទំនាក់ទំនង តើ តាក្រូច មានទំនាក់ទំនងអីជាមួយនឹងវៀតណាមដែរទេ?

**ឆ៖** អត់ទេ តាក្រូច គាត់ស្លាប់បាត់ទៅហើយ ពេលវៀតណាម -- ចុងវៀតណាមហ្នឹង តាក្រូច គេបាញ់ស្លាប់។ ខ្ញុំកប់នឹងពោធិ៍។ តាក្រូច ហើយតាឆេងហ្នឹង ត្រូវដែរបួស រត់ទៅបាត់។ កាលនោះ ខ្មែរយើងបះបោរ។ គេលាក់កាំភ្លើង បានកាំភ្លើងហ្នឹងឯងមកតស៊ូ។ វៀតណាមចូលមកហ្នឹងឯង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេល

នេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១២ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៣៦]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ប្រសិនជានៅមានសំណួរ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

អរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ មុនពេលសម្រាកយើងបាននិយាយអំពីការៗវាយលុករបស់កងទ័ពវៀតណាមពីរលើក។ លោកបានធ្វើជាទាហានដោយខ្លួនឯង។ ខ្ញុំគិតថាលោកបានដឹងថា តើសមរភូមិ ឬក៏ជម្លោះនោះវាមានន័យដូចម្តេច? តើលោកធ្លាប់ឮនៅក្នុងឆ្នាំចុងក្រោយនៃកម្ពុជាប្រជាធិបតេយ្យ គឺឆ្នាំ១៩៧៨ អំពីការវាយប្រហារទ្រង់ទ្រាយធំនៅក្នុងខេត្តស្វាយរៀងរវាងកងទ័ពវៀតណាម ហើយនិងកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**លោក ព្រុំ សារុន៖**

**ឆ៖** ខ្ញុំអត់ដែលឮទេ ខ្ញុំនៅឯណោះដែរ។ នៅតែភ្នំសំពៅហ្នឹងដែរ មិនដែលឮគេវាយអីណាៗ មិនដឹងទេ។

**ស៖** មិនបញ្ហាទេលោកសាក្សី។ ដើម្បីឲ្យប្រាកដ តើត្រឹមត្រូវដែរឬទេ កាលណាខ្ញុំនិយាយថា សំណួរ តាក្រច ដែល តាក្រច សួរទៅលោកថា តើមានវៀតណាមដែរឬទេនៅកងវរសេនាតូចនោះ។ គឺជាការសន្និដ្ឋានរបស់ តាក្រច ទេ បន្ទាប់ពី តាឆាំ បាត់ខ្លួនទៅ?

**ឆ៖** តាក្រច សួរ ខ្ញុំថាមិនមានវៀតណាមទេ មានតែចិន។ ខ្ញុំអាចឆ្លើយបានតែប៉ុណ្ណឹងឯង មានតែចិន មិនមានវៀតណាមទេ។

[១០:៣៤:៤៩]

**ស៖** ខ្ញុំយល់លោកសាក្សី ប៉ុន្តែខ្ញុំសួរខុសពីនេះបន្តិច។ នៅពេល តាក្រច សួរលោកសំណួរនេះ តើ តាឆាំ បានបាត់ខ្លួនហើយឬនៅ?

**ឆ៖** តាឆាំ បាត់ខ្លួនហើយ ផ្លាក់ តាឆេង មកវិញ គណៈស្រុក។

**ស៖** សំណួរខ្ញុំ ខ្ញុំចង់សួរថាតើលោកអាចនឹកឃើញទេថា ប៉ុន្មានខែ ឬក៏ប៉ុន្មានអាទិត្យបន្ទាប់ពី តាឆាំ បាត់ខ្លួនដែល តាក្រច មកសួរលោកអំពីសំណួរនេះ?

**ឆ៖** តាំងពី តាឆាំ បាត់ខ្លួន តាក្រច សួរក្នុងឆ្នាំលើកទី២។ សួរមុន តាឆាំ បាត់ខ្លួន។ ខ្ញុំមិនចាំឆ្នាំ មិនចាំអីទេ ភ្លេចឆ្នាំអស់ហើយ។

**ស៖** ខ្ញុំយល់លោកសាក្សី នេះជាសំណួរពិបាកឲ្យលោកនឹក។ ឥឡូវនេះ យើងចូលទៅប្រធានបទមួយផ្សេងទៀត ពាក្យដែលលោកប្រើមុនពេលឈប់សម្រាកនោះគឺថា ពាក្យដែលថាការបះបោរ។ នៅក្នុងកំណត់ហេតុដែលស្ដាប់ចម្លើយលោក លោកក៏បានប្រើពាក្យបីដង ពាក្យដែលថាមានមនុស្សមួយចំនួនបានបះបោរប្រឆាំងនឹងបដិវត្តន៍ ហើយក្រុមបះបោរត្រូវបានគេបង្កើត ហើយមានចលនាបះបោរនៅក្នុងស្រុករបស់លោកផងដែរ។ នៅពេលដែលលោកនិយាយអំពីរឿងនេះ តើមានន័យដូចម្ដេច? ហើយអ្នកណាជាអ្នកបះបោរ? តើគេបះបោរហ្នឹងដោយសារមូលហេតុអ្វី?

**ឆ៖** គេបះបោរហ្នឹងដោយសារថាខ្មែរក្រហមហ្នឹងរឹបជាន់គេ បានគេបះបោរហ្នឹង ហើយបះបោរហ្នឹងគេដឹង ដល់នេះគេហៅមកប្រជុំគ្រប់កង គ្រប់វរៈហ្នឹងឯង ដែលថាប្រជុំកម្ទេចមនុស្សបះបោរ។ ប៉ុណ្ណឹង។

[១០:៣៨:១៤]

**ស៖** តើលោកនៅចងចាំអ្វីខ្លះអំពីកងកម្លាំងភូមិភាគពាយ័ព្យ ឬក៏កម្មាភិបាលភូមិភាគពាយ័ព្យ ដែលប្រមូលអាវុធ ឬក៏យកអាវុធដើម្បីប្រើក្នុងការបះបោរ។ តើលោកដឹងពីរឿងនេះដែរទេ?

**ឆ៖** អត់ដឹងទេ ភ្លេចអស់ហើយ យូរឆ្នាំហើយ ភ្លេចហើយ ដែលខ្ញុំមិនសូវចងចាំផង។

**ស៖** បាទ ខ្ញុំយល់។ តើលោកធ្លាប់ឮដែរទេ តានាំ ឬក៏ តាញ៉ឹម ដែលមានឈ្មោះថា មូល សម្បត្តិ ក៏បានចូលរួមក្នុងការបះបោរប្រឆាំងនឹងខ្មែរក្រហមកាលនោះដែរឬទេ?

**ឆ៖** អត់ដឹងទេ។

**ស៖** ខ្ញុំមានសំណួរខ្លីៗពីរនៅសល់លោកសាក្សី។ មួយគឺដូចខាងក្រោមនេះ គឺសាក្សីផ្សេងទៀតនិយាយប្រាប់អ្នកស៊ើបអង្កេត។ លោកប្រធាននៅក្នុងឯកសារ E3/7737 -- បាទ ខ្ញុំរកឃើញហើយនៅក្នុងឯកសារ ERN ជាភាសាអង់គ្លេស 00274160, ខ្មែរ 00197883, បារាំង 00226156។ សាក្សីនេះគេសួរគាត់អំពីជនជាតិវៀតណាម គាត់និយាយអំពីបុគ្គលម្នាក់ឈ្មោះ យាយណៃ គាត់និយាយថាស្ត្រីនេះគឺជាជនជាតិយួនដែលបានចូលសញ្ជាតិជាខ្មែរ ហើយដកស្រង់ថា "បន្ទាប់មកគេក៏បានដោះលែងគាត់" បញ្ចប់ការដកស្រង់។ តើលោកបានដឹងអ្វីខ្លះអំពីថាជាជនជាតិវៀតណាម ហើយគាត់បានចូលសញ្ជាតិជាខ្មែរហើយ ហើយគេដោះលែងអ្នកទាំងអស់នោះក្រោយពីគេចាប់ហើយ។ តើលោកធ្លាប់ឮរឿងហេតុបែបនេះទេ?

**ឆ៖** អត់ធ្លាប់ទេ។

**លោក ពេជ អង្គ៖**

សូមៗអនុញ្ញាតលោកប្រធាន សូមបញ្ជាក់បន្តិច។ នៅក្នុងអត្ថបទដែលសរសេរជាភាសាខ្មែរដែលលោកមានការបកប្រែ ឬក៏និយាយអំមិញហៅថាយាយណៃ នោះគឺមិនមែនយាយណៃទេ គឺយាយណើ សរសេរ ណ និង ើ។ នេះក៏ជាឈ្មោះដែលលោកចៅក្រមឡាវែន៍ បានប្រកបពីលើក -- បានលើកពីលើកមុនដែរ គឺឈ្មោះយាយណើ មិនមែនយាយណៃទេ សូមបញ្ជាក់ប៉ុណ្ណឹង។ សូមអរគុណលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរសួរទាក់ទងទៅនឹងឈ្មោះ ថាតើសាក្សីនេះឈ្មោះ -- តើមានការប្រព្រឹត្តខុសគ្នារវាងប្រជាជនដែលជាជនជាតិវៀតណាមដែលៗបានចូលសញ្ជាតិ ហើយអ្នកមិនចូលសញ្ជាតិ តើលោកសាក្សីដឹងដែរឬទេពីរឿងហ្នឹង?

**លោក ព្រុំ សារុន៖**

**ឆ៖** បាទ អត់ដឹងទេ មិនដឹង យាយណើ យាយណែ ណាទេ។

[១០:៤៣:០៩]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំលោកសាក្សី។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះលោកនិយាយអំពីបុគ្គលម្នាក់ គឺជាអ្នកចម្រៀងដែលជម្លៀសទៅពីភ្នំពេញដែលឈ្មោះថា ទិត សម្បត្តិ តើលោកបាននិយាយ -- នៅចាំថាលោកបានបញ្ជាក់ឈ្មោះនេះដែរឬទេ?

**ឆ៖** បាទ ហ្នឹងខ្ញុំ -- ថេត សម្បត្តិ ហ្នឹង ខ្ញុំស្គាល់។ លើកទំនប់អាងដង្កោនេះ គេចងបណ្តើរយកទៅ ហើយក៏បាត់តាំងពីហ្នឹងមក។ ថេត សម្បត្តិ ហ្នឹងធ្លាប់ធ្វើការជាមួយគ្នា លើកអាងកំពីងកំពួយ -- អ៎ន៎! ដង្កោ។ គេចងបណ្តើរយកទៅបាត់ដំណឹងមកសូន្យទៅ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** បាទ សំណួរចុងក្រោយរបស់ខ្ញុំ ថាតើ ដែលថាកូនរបស់គាត់នៅរស់ ប៉ុន្តែគាត់ធ្វើជាអ្នកកាសែតនៅភ្នំពេញ តើលោកស្គាល់ទេ?

**ឆ៖** បាទ អត់ស្គាល់ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោកខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

[១០:៤៥:០៥]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួលោក ព្រុំ សារុន។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរខ្លីៗមួយចំនួនទៅកាន់លោក។ សំណួរទី១របស់ខ្ញុំពាក់ព័ន្ធនឹងវរៈចំនួនពីរដែលលោកបានឆ្លើយ។ លោកថាលោកជាសមាជិកវរៈទី១ ហើយក៏មានវរៈទី -- លេខ២ផងដែរ។ ខ្ញុំយល់ថាលោកមិនដែលបានជជែកគ្នាជាមួយអ្នកនៅក្នុងវរៈលេខ២ទេ។ ប៉ុន្តែលោកដឹងទេថា អ្នកណាជាប្រធានវរៈលេខ២ហ្នឹង? លោកស្គាល់ឈ្មោះទេ?

**លោក ព្រុំ សារុន៖**

**ឆ៖** ឈ្មោះ តាឃី ប្រធានវរៈលេខ២។

**ស៖** ឥឡូវនេះខ្ញុំចូលទៅនិយាយអំពី តាក្រច។ លោកថាគាត់ជាប្រធានវរៈរបស់លោក។ លោកដឹងថាគាត់មានស្រុកកំណើតនៅឯណាទេ?

**ឆ៖** តាក្រច នៅស្រុកកំណើតនៅឃុំស្ទឹម។ តាក្រច ហ្នឹងគេបាញ់ស្លាប់បាត់ហើយ។ ហើយ តាឆេង ហ្នឹងក៏ត្រូវគ្រាប់ដែលកាលនុ៎ង។

[១០:៤៦:៥៩]

**ស៖** ខ្ញុំនិយាយតែពី តាក្រច ទេ។ លោកដឹងទេ អ្នកណាស្ថិតនៅក្រោមបង្គាប់ផ្ទាល់តែម្តងរបស់តាក្រច?

**ឆ៖** តាក្រច មាន តាហឿន – តាក្រច, តាហឿន ប៉ុនថាស្លាប់អស់ហើយ។ កាលដែលបាញ់ហ្នឹងគេស្លាប់អស់ហើយ។

**ស៖** តាហឿន ហ្នឹងលោកធ្លាប់ធ្វើការផ្ទាល់ជាមួយគាត់ទេ?

**ឆ៖** គេនៅវរៈផ្សេង ខ្ញុំធ្វើការតែស្នងដកឯណោះ មានទៅដឹង។

**ស៖** លោកថា ហឿន នៅក្នុងវរៈផ្សេង។ អ៊ីចឹងមានន័យថា តាក្រច ហ្នឹងគាត់កាន់វរៈច្រើនមែនទេក្រៅពីវរៈលេខ១ហ្នឹង?

**ឆ៖** តាក្រច នៅកាន់វរៈ១។ តាហឿន នៅផ្សេងខុសគ្នា។ តាក្រចក្តាប់វរៈ១។

**ស៖** អម្បាញ់មិញនេះខ្ញុំសួរថា អ្នកណាជាអនុ ឬក៏ជាកូនចៅផ្ទាល់របស់ តាក្រច ហ្នឹង? លោក

ថា ហឿន។ អ៊ីចឹងឥឡូវលោកថា ហឿន ហ្នឹងនៅវរៈផ្សេង។ អ៊ីចឹងមានន័យថា ហឿន ហ្នឹងមានឋានៈស្មើ នឹង តាក្រច ដែរ មែនទេ?

**ឆ៖** បាទ។

**ស៖** ប្រសិនបើលោកចាំ លោកថាចាំ បើមិនចាំ មិនអីទេ។ ខ្ញុំចង់ដឹងថា អ្នកណាដែលឋិតនៅក្រោម ធ្វើការនៅក្រោមបញ្ជាផ្ទាល់របស់ តាក្រច នេះក្រៅពីលោកនោះ?

**ឆ៖** តាហុង អនុប្រធាន។ ចុះពី តាក្រច មក តាហុង ប៉ុនស្លាប់អស់ហើយ។

**ស៖** តាហុងហ្នឹងជាមេផ្ទាល់របស់លោកតែម្តងមែនទេ?

**ឆ៖** បាទ។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីតាឆាំ។ មុនពេលគាត់បាត់ខ្លួន លោកជួបគាត់ញឹកញាប់ទេ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ឃើញតែមុខទេ មិនដែលបានទៅជិតទេ។ តាឆាំ ស្លាប់នោះសាហាវណាស់ មិនដែលបានទៅជិតទេ ប្រើមនុស្សលើកទំនប់ លើកតែទំនប់ទៅ។ មិនដែលបានទៅជិតគេទេសម័យនោះ។

**ស៖** ពាក់ព័ន្ធនឹងអត្តចរិតរបស់ តាឆាំ នេះ មានបុគ្គលផ្សេងទៀត ក៏បាននិយាយអំពីគាត់ផងដែរ ដូច្នេះ ខ្ញុំចង់ដឹងថាលោកស្គាល់ឈ្មោះ អ៊ុំ ស៊ន់ លោកស្គាល់គាត់ទេ? តាស៊ុំនេះ ក៏ធ្លាប់ធ្វើជាប្រធានកងឃ្លាលគោដែរ។ គាត់មកពីភ្នំ មកពីឃុំភ្នំសំពៅ។

**ឆ៖** អ៊ុំ ស៊ន់ មិនដែលស្គាល់ទេ បាទ ជម្រាបប្រសាសន៍មិនដែលស្គាល់ទេ។

[១០:៥២:២៨]

**ស៖** លោកធ្លាប់ស្តាប់ឮគេនិយាយអំពីចលនាខ្មែរឥស្សរៈទេ?

**ឆ៖** ភ្លេចអស់ហើយ ខ្មែរឥស្សរៈ ព្រោះយូរឆ្នាំហើយភ្លេចហើយ រៀបរាប់មិនបានទេ។

**ស៖** មិនជាបញ្ហាអ្វីទេ។ លោកធ្លាប់ឮឈ្មោះ តាយ៉ាត ទេ?

**ឆ៖** តាយ៉ាតៗ អត់ដែលឮឈ្មោះទេ។

**ស៖** ខ្ញុំចង់រំឮកការចងចាំរបស់លោកតាមរយៈសក្ខីកម្មរបស់សាក្សីមួយរូប ពាក់ព័ន្ធនឹងចលនាខ្មែរឥស្សរៈ និងតាយ៉ាត គឺឯកសារ E3/5182។ សាក្សីរូបនេះនិយាយអំពីការចាប់ខ្លួន តាយ៉ាត។ នេះជាសម្តីរបស់គាត់ នៅ ERN ជាភាសាបារាំងគឺ 00223092, ERN ជាភាសាខ្មែរ គឺ 00197932, ERN ជាភាសាអង់គ្លេស 00274149។ នេះជាចម្លើយរបស់សាក្សីរូបនោះ គាត់បានឆ្លើយដូចតទៅ៖ "ខ្ញុំដឹង

តាមរយ: តាយ៉ាត ថានៅសម័យនោះមានចលនាឥស្សរៈ ហើយមានការឈ្លោះគ្នាជាមួយនឹងតានាំ។ បើតាមខ្ញុំដឹងគឺ រឿងនេះ គឺដោយសារការគុំកួនផ្ទាល់គ្នាទេ គុំកួននឹងគ្នារឿងផ្ទាល់ខ្លួនទេ មិនមែនដោយសារតែខ្មែរក្រហមទេ"។ នៅក្នុងសម្រង់នេះ គឺសាក្សីគាត់និយាយអំពីការចាប់ខ្លួន តាយ៉ាត។ តើលោកមាននឹកឃើញឡើងវិញទេ លោកមានធ្លាប់ស្ដាប់ឮការនិយាយអំពីការចាប់ខ្លួន តាយ៉ាត ដូចដែលសាក្សី អ៊ុំ ស៊ិន ហ្នឹងគាត់ បាននិយាយទេ? លោកមាននឹកឃើញអ្វីខ្លះឡើងវិញទេ?

**ផ៖** អត់នឹកឃើញទេ។ មិនដឹង តាយ៉ាត ណាមួយផង។

**ស៖** ខ្ញុំមិនសួរជជីកទៀតទេ មិនអីទេ។ លោកបាននិយាយអំពីអត្តចរិតរបស់ តានាំ ហើយនិងភាពកាចសាហាវរបស់គាត់។ តើលោកដឹងថា គាត់ធ្លាប់ចេញសេចក្ដីសម្រេចដោយសារតែហេតុផលផ្ទាល់ខ្លួនទេ ពេលដែលលោកធ្វើការជាមួយគាត់នោះ? ឬក៏លោកធ្លាប់ស្ដាប់ឮថ្នាក់លើរបស់លោកមានបាននិយាយអីថាគាត់ធ្លាប់ធ្វើសេចក្ដីសម្រេចណាមួយដោយសារតែហេតុផលផ្ទាល់ខ្លួនទេ?

**ផ៖** អត់ដែលជិតគាត់ទេ មិនដឹងរឿងគាត់ មិនដែលមើលមុខគាត់ផង។

[១០:៥៦:៤៦]

**ស៖** ខ្ញុំយល់ថាលោកខ្លាច តានាំ ក៏ប៉ុន្តែខ្ញុំសួរលោកចង់ដឹងថាតើ ការភ័យខ្លាចហ្នឹងគឺដោយសារតែលោកធ្លាប់ឮគេនិយាយអំពីគាត់ អំពីរបៀបដែលគាត់ធ្វើការ ឬក៏យ៉ាងម៉េច? លោកមានមូលហេតុអ្វីជាក់លាក់ទេ ហេតុអ្វីបានជាលោកខ្លាចគាត់នោះ?

**ផ៖** ឮតែគាត់សម្លាប់ច្រើនណាស់ ខ្លាច មិនហ៊ានមើលមុខផង មិនទាំងហ៊ានដើរជិតផ្ទះគាត់ផងនៅមុខសំណាង់ហ្នឹងឯង។ មិនដែលនិយាយរកគាត់ផង។

**ស៖** អ្នកណាជាអ្នកនិយាយប្រាប់លោកថាការស្លាប់របស់គាត់ហ្នឹងគឺដោយសារតែការសម្រេចពី តានាំ នោះ?

**ផ៖** ទេ ល្បីតៗគ្នាមក ខ្ញុំមិនហ៊ានមើលមុខគាត់ផង មិនទៅជិតផង លើកតែទំនប់ៗទៅ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះ អរគុណលោក ព្រុំ សារុន។ សវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីដល់ពេលនេះ ដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែង

រកការពិតក្នុងរឿងក្តីនេះ។ ហើយវត្តមានរបស់លោកនៅអ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ព្រុំ សារុន ត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយនិងបង្គាប់ឲ្យអញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-949 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការចំពោះមុខអង្គជំនុំជម្រះ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១១:០២:២១]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី! តើលោកឈ្មោះអ្វី?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** កុំអាលទាន់ឆ្លើយតប! រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការដោយឲ្យភ្លើងសញ្ញាក្រហម នៅពីមុខលោកជាមុនសិនណ៎ះ! ឆ្លៀតឱកាស ឃ្លាតពេលនេះ លោកអាចគិតដើម្បីឆ្លើយតបទៅនឹងសំណួរឲ្យចំនឹងសំណួរដែលសួរ។ ម្តងទៀត តើលោកឈ្មោះអ្វី?

**ឆ៖** បាទ កាលជាដំបូង ខ្ញុំរស់នៅក្នុងឃុំសង្វើយ--

**ស៖** លោកស្តាប់បាន យើងសួរសំណួរ លោកចាំស្តាប់សំណួរ ហើយឆ្លើយតបនឹងសំណួរណ៎ះ! ម្តងទៀត តើលោកឈ្មោះអ្វី? លោកកុំអាលឆ្លើយ ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការឲ្យភ្លើងសញ្ញាក្រហមសិនណ៎ះ! អំមិញមន្ត្រីច្បាប់ -- មន្ត្រីរដ្ឋបាលតុលាការប្រាប់លោកហើយ ដើម្បីឲ្យសំឡេងរបស់លោកចូលទៅប្រព័ន្ធចែកចាយសំឡេងនេះ ដែលភាគីពាក់ព័ន្ធស្តាប់ ហើយជាពិសេសដល់ទៅសាធារណជន ហើយពិសេសហ្នឹងគឺអង្គភាពបកប្រែភាសា ដែលត្រូវបកប្រែភាសាដំបូង លោកឆ្លើយហ្នឹងជាពីរភាសាផ្សេងទៀត មានភាសាអង់គ្លេស និងភាសាបារាំង។ ម្តងទៀត តើលោកឈ្មោះអ្វី?

**ឆ៖** ខ្ញុំបាទឈ្មោះ អ៊ុំ ស៊ន់។

[១១:០៤:១៣]

**ស៖** បាទ អរគុណលោក អ៊ុំ ស៊ន់ តើលោកកើតថ្ងៃខែឆ្នាំណា លោកចាំទេ?

**ឆ៖** មិនបានចាំទេ។

**ស៖** តើលោកអាយុប៉ុន្មានឆ្នាំហើយ។

**ឆ៖** ហា -- ហុកៗ ៦៤ហើយ។

**ស៖** បាទ អរគុណ ហើយលោក អ៊ុំ ស៊ន់ តើលោកមានទីលំនៅសព្វថ្ងៃនៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទរស់នៅភូមិសក្កា-ត្រពាំងឫស្សី ឃុំបឹងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប។

**ស៖** អរគុណ ហើយលោកប្រកបមុខរបររកស៊ីធ្វើអ្វីសព្វថ្ងៃនេះ?

**ឆ៖** មុខរបរខ្ញុំ សព្វថ្ងៃរកស៊ី ធ្វើស្រែចម្ការ។

**ស៖** បាទ អរគុណ ហើយចុះឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំឈ្មោះ អ៊ុំ – លឹម អ៊ុំ។ ម្ដាយខ្ញុំឈ្មោះ ប៉ែន។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** កូន១០នាក់។ ប្រពន្ធឈ្មោះ សាន់ ស៊ន់។ កូនមានចំនួន១០នាក់។

[១១:០៥:៥៥]

**ស៖** អរគុណលោក អ៊ុំ ស៊ន់ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹក ថាតាមសមត្ថភាពដែលលោកអាចដឹង គឺថាលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទ គឺលោក នួន ជា និងលោក ខៀវ សំផន ទេ។ ហើយក៏មិនជាប់ញាតិលោហិត ឬញាតិពន្ធជាមួយនឹងពួកបុគ្គលទាំងឡាយ ដែលអង្គជំនុំជម្រះទទួលយកជាភាគីជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ តើពិតមែនដែរទេ?

**ឆ៖** អត់មានជាប់ទេ។ ខ្ញុំអត់មានជាប់ជំពាក់អីទេ។

**ស៖** អរគុណ ហើយមុនដែលចូលមកដល់ចំពោះអង្គជំនុំជម្រះនៅពេលនេះ តើលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែក ដែលនៅពីកើតសាលសវនាការនេះហើយឬនៅ?

**ឆ៖** បាទ ខ្ញុំបាទបានស្បថសច្ចាប្រណិធាននៅលោកតាដំបងដែករួចទៅហើយ ព្រោះខ្ញុំវាស្មោះត្រង់ ហើយវាឃើញពិតមែន ឮពិតមែន បាទ។

**ស៖** បាទ អរគុណ។ ហើយលោក អ៊ុំ ស៊ន់ ជាបន្តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ច ដល់លោក ក្នុងឋានៈលោកជាសាក្សី ដែលត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិក្នុងឋានៈលោកជាសាក្សី នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការដែលឲ្យលោកធ្វើអត្ថាធិប្បាយដែលនាំឲ្យចម្លើយរបស់លោកហ្នឹងដាក់បន្ទុកលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច លោក អ៊ុំ ស៊ន់ ក្នុងឋានៈលោកជាសាក្សី នៅចំពោះមុខអង្គជំនុំជម្រះត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកដែលនាំឲ្យដាក់ពិរុទ្ធ-ភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិចំពោះលោកក្នុងនាម ក្នុងឋានៈជាសាក្សីអម្បាញ់មិញនេះ។ ហើយក្នុងឋានៈក្នុងជាសាក្សីត្រូវតែឆ្លើយឲ្យការណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏ធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុ-ការណ៍ទាំងឡាយពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោក អ៊ុំ ស៊ន់ តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេរយៈក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ? ហើយប្រសិនបើធ្វើ ធ្វើប៉ុន្មានដង ធ្វើនៅទីកន្លែងណា នៅពេលណា លោកចាំដែរទេ?

**ឆ៖** អត់ទេ ខ្ញុំមិនដែលទេ។ មិនដែលមានជួបប្រទះបានមកសម្ភាសទេ បាទ។

[១១:០៨:៤៥]

**ស៖** នៅក្នុងឯកសារនេះ គឺបានធ្វើសម្ភាស បានបង្ហាញថាមានពាក់ព័ន្ធការធ្វើសម្ភាសលោកហ្នឹង គឺឆ្នាំ២០០៨ ខែតុលា នៅភូមិត្រពាំងឫស្សី ឃុំបឹងមាលា ស្រុកស្វាយលើ ដែល លោកចងចាំទេ?

**ឆ៖** អត់ទោស ពីព្រោះខ្ញុំបានភ្លេចភ្លាំងហើយ បាននឹកឃើញកាលឆ្នាំនោះឯង។ ខ្ញុំបានសម្ភាសមែនហ្នឹងឯង បាទ។ បានសម្ភាសម្តង។

**ស៖** ហើយមុនពេលចូលមកដល់ចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬក៏បានអាន ឬក៏បានស្តាប់ការអានឲ្យស្តាប់នូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មជាមួយអ្នកស៊ើបអង្កេតកាលពីមុននៅទីលំនៅដ្ឋានរបស់លោក ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** ខ្ញុំបាទបានចងចាំខ្លះ។ ភ្លេចភ្លាំងខ្លះ ក៏ប៉ុន្តែដែលចាំ វាច្រើន ភ្លេចវាតិច។

**ស៖** យើងសួរអំមិញថា តើលោកបានអាន ឬក៏បានស្ដាប់ការអាន ដែលសក្ខីកម្មដែលលោកផ្ដល់កាលពីពេលមុននេះ ប៉ុន្មានថ្ងៃមុននេះ ប៉ុន្មានថ្ងៃមុនកន្លងមកនេះពីម្សិលមិញ ឬក៏មុនព្រឹកមិញនេះ។ តើលោកបានអាន ឬក៏ស្ដាប់ការអានដើម្បីរំឭកការចងចាំរបស់លោកដែរឬទេលើកំណត់ហេតុដែលលោកផ្ដល់សក្ខីកម្មកាលពីពេលមុននោះ?

**ឆ៖** បានអាន បានចាំខ្លះៗ មិនអត់ទេ។

**ស៖** បាទអរគុណ។ ហើយតាមសមត្ថភាពដែលលោកអាចដឹងនិងចងចាំ តើលោកអាចបញ្ជាក់បានដែរទេថា កំណត់ហេតុដែលស្ដាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវសមស្រប ស៊ីចង្វាក់គ្នាទៅនឹងចម្លើយ ដែលលោកបានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុន កាលពីឆ្នាំ២០០៨ នៅភូមិ -- នៅទីលំនៅដ្ឋានរបស់លោកនោះដែរឬទេ?

**ឆ៖** បាទ ចាំ។ ហើយអង្កាល់នោះបានឃើញ លបឃើញ កាលខ្ញុំ--

[១១:១១:០៨]

**ស៖** អត់ទាន់សួរទេ យើងចង់ដឹងថាតើខ្លឹមសារដែលលោកអាននឹងកំណត់ហេតុដើម្បីរំឭកការចងចាំនោះ វាស្របទៅនឹងអ្វីដែលលោកបានឆ្លើយកាលពីពេលមុនដែរទេ នូវឯកសារដែលលោកបានអានពីមុននេះ?

**ឆ៖** ដូចបានអានទៅដូចបានគ្នា ដំណើរការត្រូវទាំងអស់។

**ស៖** បាទអរគុណ។ ហើយនៅក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ ស្ទួន នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី អ៊ុំ ស៊ន់ នេះមុនភាគីដទៃទៀតនៃរឿងក្ដី។ សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី ខ្ញុំឈ្មោះ វាំងសង់ដេវីល ខ្ញុំនឹងសួរសំណួរលោកនៅព្រឹកនេះនិងរសៀលនេះ

ពាក់ព័ន្ធទៅនឹងហេតុការណ៍ដែលបានកើតឡើងនៅវត្តខ្សាច់។ ប្រសិនបើលោកមិនយល់សំណួរ សូមលោកប្រាប់ខ្ញុំ ខ្ញុំនឹងសួរឡើងវិញ។ សូមលោកកុំឆ្លើយប្រឌិត សូមលោកឆ្លើយនូវអ្វីដែលលោកដឹងបានទៅបានហើយ បើលោកមិនដឹងឆ្លើយថាមិនដឹង។ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ តើគេចាត់តាំងឲ្យលោកទៅធ្វើការនៅក្នុងកងអ្វីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** បាទ ខ្ញុំនៅជាកងចល័តក្នុងភូមិក្នុងសហគមន៍ទេ ខ្ញុំអត់មានបានធ្វើការជាប់ជួនជាមួយទេ ខ្ញុំជាប្រជាជនកសិករ ខាងរត់ខាងសេដ្ឋកិច្ចអារឿងបញ្ហាសេដ្ឋកិច្ចទេ។

**ស៖** កងចល័តរបស់លោកហ្នឹងស្ថិតនៅក្នុងភូមិអី ឃុំអី ស្រុកអី?

**ឆ៖** នៅក្នុងភូមិយាង ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប។

**ស៖** សូមអរគុណ។ លោកបាននិយាយថា ស្រុកជីក្រែង។ នៅឆ្នាំ៧៥ លោកមានអាយុប៉ុន្មាន? ឥឡូវនេះលោកអាយុ៦៤ឆ្នាំ ចុះនៅពេលដែលលោកចាប់ផ្ដើមធ្វើការនៅក្នុងកងចល័តនោះ លោកមានអាយុប្រហែលប៉ុន្មានដែរ?

**ឆ៖** ប្រហែលជាអាយុខ្ញុំ ២៨ឆ្នាំ។

**ស៖** លោកដឹងថាស្រុកជីក្រែងនេះស្ថិតនៅក្នុងតំបន់អីទេ?

[១១:១៤:៥៣]

**ឆ៖** មិនដឹងដែរ ខ្ញុំមិនដឹងថានៅតំបន់អី ដឹងតែស្រុកជីក្រែង ខេត្តសៀមរាបប៉ុណ្ណឹងឯង។ ភូមិយាង ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប បាទ។

**ស៖** សូមអរគុណ។ ពេលដែលលោករស់នៅយាងនោះ លោកសម្រាកនៅកន្លែងណាក្នុងកងចល័តរបស់លោកហ្នឹង?

**ឆ៖** ក្នុងសហករណ៍ទេ មិនមែនចល័តនៅក្នុងសង្កាត់ ឬឃុំទេ។ នៅក្នុងសហករណ៍ខ្ញុំ កាលនោះ ខ្ញុំមានចូលជួរចូលអីគេ អត់ទេ។ នៅក្នុងប្រជាជនយើងធម្មតា នៅក្នុងសហករណ៍មូលដ្ឋាន ភូមិយាង បាទ។

**ស៖** លោកធ្លាប់សម្រាកនៅវត្តខ្សាច់ ក្នុងភូមិយាងហ្នឹងទេ?

**ប្រធានអង្គជំនុំ៖**

កុំអានទាន់ឆ្លើយតប។ បាទ កុំអាលៗ!

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** ព្រោះក្នុងដែលខ្ញុំរស់នៅនោះ វាភូមិអែបវត្តហ្នឹងឯង អែបវត្តខ្សាច់នោះដែរ។ ចម្ងាយប្រហែលជា១៥០ម៉ែត្រដល់វត្ត បាទ កន្លែងតំបន់វត្តខ្សាច់។ ប៉ុន្តែគេហៅសរុបរួម គេហៅភូមិយាង ឃុំសង្វើយ ស្រុកជីក្រែង ខេត្តសៀមរាប។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** វត្តខ្សាច់នេះ គេប្រើសម្រាប់ជាកន្លែងអ្វីដែរនៅចន្លោះឆ្នាំ៧៥ ទៅដល់ ៧៩ នោះ? ហើយនៅពេលនោះគឺមានព្រះសង្ឃ ហើយនិងមានការគោរពពិធីបុណ្យសាសនាអីនៅក្នុងវត្តទេ?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** អត់មានទេៗលោក អត់មានទេ ព្រោះវិហារអីហ្នឹងគេវ៉ៃបែកបាក់អស់រលីងហើយ។ គេយកវិហារធ្វើជាកន្លែងមូលដ្ឋានចិញ្ចឹមសត្វ ឬគេធ្វើកន្លែងបោកស្រូវ ប៉ុណ្ណោះឯង។ អត់មាននេះទេ មានតួតែវត្តមែន ប៉ុន្តែព្រះវិហារអីវ៉ៃបាក់ខ្ទេចខ្ទីអស់ហើយ កាលឆ្នាំនោះឯង។ បាក់ខ្ទេចខ្ទីអស់ហើយវត្តនោះ វត្តខ្សាច់ហ្នឹង។ កាលឆ្នាំនោះឯង វារំលាយវត្តចោលអស់ វ៉ៃបំបែកបំបាក់ព្រះវិហារអស់រលីង។ នៅសល់តែតួកុដកញ្ចិបកញ្ចុបរុករាក់ ដែលវាវ៉ៃបំបែកខ្ទេចខ្ទី ខ្ទេចខ្ទាំអស់ នៅសល់តែកម្ទេចកម្ទី។

[១១:១៨:៣៥]

**ស៖** សូមអរគុណ។ ខ្ញុំនឹងត្រឡប់មកនិយាយអំពីរឿងនេះនៅពេលក្រោយទៀត ក៏ប៉ុន្តែខ្ញុំសូមឱ្យលោកឆ្លើយខ្លីៗទៅនឹងសំណួររបស់ខ្ញុំ។ ក្នុងសហករណ៍របស់លោក លោកស្គាល់ឈ្មោះ ស៊ាន ស៊ីង់ ទេ?

**ឆ៖** ស៊ាន ស៊ីង់? ខ្ញុំស្គាល់ឈ្មោះ ស៊ាន ស៊ីង់ ដែលបានទៅលបមើលដែលគេកំពុងតែធ្វើឃាត។ កាលនោះ ភ័យញ័រចំប្រប់នាំគ្នារត់មក--

**ប្រធានអង្គជំនុំ៖**

កុំអាលឆ្លើយតប ចាំគេសួរណ៎ះ! គេគ្រាន់តែសួរថាស្គាល់ ឬក៏អត់បានហើយ។ នេះសំណួរអំមិញគ្រាន់តែស្គាល់ ស៊ាន ស៊ីង់ ទេ។ ស្គាល់ ឬមិនស្គាល់ ស៊ាន ស៊ីង់ បានហើយណ៎ះ?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមលោកកុំទាន់ឆ្លើយ។ ខ្ញុំនឹងសួរអំពីការសម្លាប់នេះនៅពេលក្រោយ។

**ស៖** តើ ស៊ាន ស៊ីង់ នេះធ្វើការនៅក្នុងកងតែមួយជាមួយលោកមែនទេ ហើយនៅឆ្នាំ៧៥ហ្នឹងគាត់មានអាយុប្រហែលប៉ុន្មានដែរ?

ធ៖ អាយុវាក្មេងជាងខ្ញុំទេ ប្អូនខ្ញុំទេ ស៊ាន់ ស៊ង់ នេះ។ វាដូចថាខ្ញុំវារាងជំទង់ -- កំលោះហើយ វាជំទង់ទេ ស៊ាន ស៊ង់ ហ្នឹង កាលនោះ បាទ។

[១១:២០:១៥]

ស៖ លោកថាលោកមានអាយុ២៨ឆ្នាំ តាមរយៈការបកប្រែ។ អ៊ីចឹងពេលហ្នឹង គឺមានន័យថា លោកធំណាស់ហើយ ព្រោះថាលោកអាយុ២៨ឆ្នាំទៅហើយ?

ធ៖ បាទ ប៉ុណ្ណោះឯង ធំវាធំជាង ស៊ាន ស៊ង់ បងស៊ាន ស៊ង់។

ស៖ ទោះបីជាមានអាយុខុសគ្នាក៏ដោយ ក៏ប៉ុន្តែលោក ហើយនិង ស៊ាន ស៊ង់ ពេលហ្នឹងជាមិត្តភក្តិនឹងគ្នាមែនទេ?

ធ៖ បាទៗជាមិត្តភក្តិដើរលេងជុំគ្នា ធ្វើការជុំគ្នា។

ស៖ ខ្ញុំមានសំណួរបន្តទៅទៀត គឺមិនមែនជាសំណួរពាក់ព័ន្ធនឹងវត្តទេ ក៏ប៉ុន្តែគឺពាក់ព័ន្ធនឹងវត្តមានជនជាតិវៀតណាមនៅក្នុងតំបន់របស់លោក។ នៅក្នុងភូមិរបស់លោកនោះ ក្រោយខែមេសា ៧៥ មានប្រជាជនថ្មីមករស់នៅទេ?

ធ៖ ឆ្នាំនោះ ខ្ញុំដូចជា -- អ៊ូ! មានៗប្រជាជនថ្មីនៅនោះ មាន ប្រជាជនហ្នឹងក៏មាននៅខ្លះ ដូចតាឃុត ចាន់ថា ទាំងប្តីប្រពន្ធគាត់។

ស៖ យើងនឹងត្រឡប់មកនិយាយអំពីឈ្មោះទាំងអស់នេះនៅពេលក្រោយ។ ឥឡូវនេះ ខ្ញុំចង់ដឹងថាតើអ្នកមករស់នៅក្នុងឃុំសង្វើយហ្នឹងមាននរណាជាជនជាតិវៀតណាមទេ?

ធ៖ មានៗជនជាតិវៀតណាមនៅ បាទនៅមួយគ្រួសារ តាឃុត ហើយនិងយាយម៉ា និងចៅគាត់មួយ ចាន់ថា (ស្រី) យកទៅសម្លាប់ចោលនៅវត្តខ្សាច់ទាំងអស់នឹងឯង វះយកប្រមាត់ដោតចូលជញ្ជាំងលោក។

[១១:២៣:០៧]

ស៖ លោកឆ្លើយលឿនជាងសំណួររបស់ខ្ញុំទៅទៀត។ ក្រៅពីគ្រួសារហ្នឹង តើមានអ្នកណាខ្លះទៀតជាជនជាតិវៀតណាមដែលលោកស្គាល់នៅក្នុងភូមិយាង ឬក៏នៅភូមិផ្សេងទៀតនៅក្នុងឃុំសង្វើយនោះ?

ធ៖ ខ្ញុំអត់មានស្គាល់អ្នកណាទេ ស្គាល់តែប៉ុណ្ណោះឯង ស្គាល់តែពីរគ្រួសារប៉ុណ្ណោះឯង។

ស៖ លោកនិយាយអំពីគ្រួសារ តាឃុត និងយាយម៉ា និងនាងចាន់ថា ម៉េចបានជាលោកដឹងថា

គ្រួសារគាត់ហ្នឹង ជាគ្រួសារជនជាតិវៀតណាម?

**ឆ៖** ដែលមិនដឹងណ៎ា ព្រោះអ្នកស្រុកអ្នកភូមិគេចាស់ទុំនៅកន្លែងនោះគេដឹងគេហៅថាគាត់នោះវៀតណាម។ ដឹងថាគាត់វៀតណាមហ្នឹងឯង ដែលមិនដឹងហ្អា គេនិយាយទូទៅក្នុងភូមិក្នុងឃុំ គេដឹងទូទៅទាំងអស់ រស់នៅយូរឆ្នាំទៅហើយ តាំងពីសង្គមចាស់ម្ល៉េះ។

**ស៖** ដូច្នេះគ្រួសារនេះមិនស្ថិតនៅក្នុងចំណោមអ្នកដែលគេជម្លៀសមកនៅក្នុងភូមិទេ គឺគាត់នៅក្នុងភូមិហ្នឹងតាំងពីមុនឆ្នាំ៧៥ទៅទៀត មែនទេ?

[១១:២៤:៤៨]

**ឆ៖** បាទៗ នៅមុនឆ្នាំ៧៥ ទៀត គាត់នៅយូរហើយ ហើយម្ល៉ោះហើយនៅតែគេចាប់គាត់យកទៅធ្វើឃាតអស់ ទាំងអស់ហ្នឹង។ ខ្ញុំស្រណោះគាត់ណាស់ និយាយត្រង់ គាត់នៅស្រុកខ្មែរយូរណាស់តាំងពីសង្គមចាស់មក។ ម្ល៉ោះហើយខ្ញុំនឹកស្រណោះ មិនគួរណាទៅចាប់គាត់វៃចោលដាក់--

**ប្រធានអង្គជំនុំ៖**

បាទ ហើយសាក្សី។ ឆ្លើយ ប្រាប់ឲ្យស្ដាប់សំណួរឲ្យបាន។ ឆ្លើយឲ្យសមស្រប ឆ្លើយតបនឹងសំណួរបានហើយ ភាពចំបាច់ឆ្លើយតបនឹងសំណួរដែលសួរ! មិនខ្វះសំណួរ ដែលឆ្លើយនឹង -- ឲ្យលោកឆ្លើយទេ នៅក្នុងការសួរមួយថ្ងៃ។ ថ្ងៃនេះ ហើយនិងស្អែកប្រហែលជាមួយព្រឹកទៀត នឹងសួរដេញដោលលោក។ កុំបារម្ភថាលោកអត់មានពាក្យនិយាយ ក្រែងលោលោករកហត់នឹងការឆ្លើយតប។ អ៊ីចឹងក៏ឲ្យប្រយ័ត្នប្រយែងបន្តិចក្នុងការប្រើ -- ឆ្លើយតប និងស្ដាប់សំណួរឲ្យបាន ហើយឆ្លើយតបនឹងភាពចាំបាច់ពេញលេញទៅនឹងសំណួរបានហើយ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** សូមអរគុណអម្បាញ់មិញនេះ លោកនិយាយថាអ្នកណាក៏ដឹងថា គ្រួសារគាត់ជាគ្រួសារវៀតណាមដែរ។ ដូច្នេះ តើ យាយកុត -- តើតាឃុត និង យាយម៉ា និយាយភាសាខ្មែររដីនៗៗដូចជនជាតិវៀតណាមអ៊ីចឹងមែនទេ?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** និយាយច្បាស់ដែរ។ គាត់និយាយច្បាស់ខ្មែរ ច្បាស់ណាស់។ គាត់នៅយូរហើយ គាត់និយាយខ្មែរច្បាស់។ តាំងពីខ្ញុំនៅពីតូចដឹងក្ដីមក ខ្ញុំស្គាល់គាត់ គាត់មិនដែលធ្វើទុក្ខបុកម្នេញប្រជាពលរដ្ឋបងប្អូនណាទេ អ្នកនៅស្រុកភូមិនោះ បាទ។ គាត់ជាមនុស្សអ្នកស្លូតត្រង់មួយ។ ខ្ញុំធ្លាប់ដឹង ធ្លាប់ឃើញ

គាត់នៅនោះយូរឆ្នាំហើយ។

[១១:២៧:១៦]

**ស៖** លោកបានទាក់ទងគាត់តាំងពីតូចៗ យ៉ាងម៉េចបើលោករស់នៅក្នុងភូមិឆ្ងាយពីគាត់នោះ ខ្ញុំដូចជាមិនសូវយល់ សូមលោកបញ្ជាក់ម្តងទៀតទៅមើល?

**ឆ៖** ភូមិខ្សាច់ គាត់នៅភូមិខ្សាច់ ប៉ុន្តែខ្ញុំហ្នឹង អារឿងភូមិនោះគេដាក់ឈ្មោះថាភូមិយាងទេ ប៉ុនគេបញ្ចូនទៅភូមិយាង ភូមិខ្សាច់នេះ។ ខ្លះគេហៅភូមិយាងទៅ ខ្លះគេហៅភូមិខ្សាច់ទៅ នៅជៀតវត្តនោះឯង។ ហើយមានវត្តលោកយួនមួយនៅឯវត្តខ្សាច់នោះដែរ។ សព្វថ្ងៃបាត់អស់ហើយវត្តនោះ។ លោកមិនដឹងទៅណាអស់ហើយ បាត់មិនឃើញទេ ឃើញតែទួលតួវិហារប៉ុណ្ណោះ ព្រោះខ្ញុំទៅនៅខាងឃុំបឹងមាលានោះវាយូរឆ្នាំដែរ បាទ។

**ស៖** លោកនិយាយអំពីវិហារវៀតណាម។ បើមានវិហារវៀតណាម មានន័យថាមានជនជាតិវៀតណាមច្រើននៅទីនោះ ហើយនាំគ្នាទៅវិហារវៀតណាមនោះមុនឆ្នាំ៧៥ មែនទេ?

**ឆ៖** បាទៗៗ។ នៅយូរគ្រាន់ហើយ វៀតណាមនៅយូរក្រៃលគ្រាន់ដែរ ប៉ុនគេទៅស្រុកទៅស្រែគេអស់ហើយ កាលសម័យនោះណា។ ឥឡូវដែលខ្ញុំដឹងក្រោយទៀតនេះ ឃើញនៅសល់តែ តាឃុត និង យាយម៉ា ហ្នឹងឯង និងចៅគាត់ម្នាក់ស្រីនោះ ចាន់ថា នោះ។ ខ្ញុំឃើញនៅតែប៉ុណ្ណោះ បានខ្ញុំថា និយាយប៉ុនណា -- ខ្ញុំថាឃើញប៉ុនណា ខ្ញុំថាប៉ុណ្ណោះ។

**ស៖** តើមានរឿងអ្វីកើតឡើងចំពោះគ្រួសារវៀតណាមជាច្រើននេះ? ក្រោយឆ្នាំ៧៥ លោកធ្លាប់ឮគេនិយាយថាគ្រួសារវៀតណាមទាំងអស់នោះ ត្រូវបានគេបង្ខំឲ្យចាកចេញពីកម្ពុជាទេ?

**ឆ៖** បាទ ឮតែគេថា។ ខ្ញុំបាទឮតែគេថានេះ ប៉ុនវាមិនដឹងជាចេញទៅអស់ មិនដឹងម៉េច។ នៅសល់ៗតែ តាឃុត និង យាយម៉ា និង ចាន់ថា តែប៉ុណ្ណោះ។ ដែលគេចេញទៅស្លាត់ៗ ខ្ញុំមិនដឹងដែរ។

**ស៖** ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ៧៧ ឬ៧៨ តើលោកដឹងថាមានមេភូមិ មេឃុំស្រាវជ្រាវស្វែងរកអ្នកណាជាជនជាតិវៀតណាមទេ?

**ឆ៖** កាលណោះ ខ្ញុំចល័តបាត់ ខ្ញុំមិនសូវដឹងទេ អាល័យគេប្រើទៅកាប់ដី កាប់អី ទន្ទ្រានខែត្រគេឲ្យធ្វើដីកំប៉ុសក៏មិនដឹង។ គេស៊ើបសួរពីណាគេ គិតថាធ្វើការងារបំពេញ ខ្លាចគេវាយចោលក្នុងសហគមន៍ដែរ។ ព្រោះអ្នកណាធ្វើខុសអីបន្តិចបន្តួចអត់បានទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ បាទ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន មុននឹងសម្រាក ខ្ញុំមានសំណើមួយទាក់ទងទៅនឹងសាក្សីរូបនេះ និងត្រូវពិនិត្យមើល ថាតើអាចនឹងបង្គាប់ទៅ វេសស៊ូ ឲ្យផ្តល់ឲ្យភាគីនូវ១ច្បាប់ចម្លងនៃអត្តសញ្ញាណប័ណ្ណ ឬក៏ឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់គាត់។ មូលហេតុដែលខ្ញុំសួរគឺ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់គឺគាត់បញ្ជាក់ថា គាត់កើតនៅថ្ងៃទី០៩ ខែមករា ឆ្នាំ១៩៥៨។ ប៉ុន្តែក្រោយមកនៅពេលដែលយើងសួរសាក្សីរូបនេះ អំពីអាយុរបស់គាត់ ហើយនិងលទ្ធភាពក្នុងការគណនាអាយុគាត់នេះ យើងចោទជាបញ្ហា។ គាត់និយាយថាគាត់អាយុ៦៤ឆ្នាំ នៅពេលនេះ ដែលអាចនឹងធ្វើឲ្យគាត់អាចនឹងកើតនៅឆ្នាំ១៩៥១ មិនមែន ១៩៥៨ទេ។ ហើយៗនៅឆ្នាំ១៩៧៥ គាត់អាយុ២៨ ដែលអាចគឺថាគាត់អាចកើតនៅក្នុងឆ្នាំ១៩៤៧។ បាទ យើងពិនិត្យឃើញច្បាស់ហើយថា អ្នកស៊ើបអង្កេតបានកត់ត្រាជាក់លាក់ គឺថាថ្ងៃទី០៩ មករា ឆ្នាំ១៩៥៨។ ដូច្នេះ គឺថាសូមតុលាការបង្គាប់ឲ្យយកអត្តសញ្ញាណ។

[១១:៣២:៣៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកសាក្សីតើមានអត្តសញ្ញាណប័ណ្ណមកជាមួយទេ?

**លោក អ៊ុំ ស៊ិន៖**

មាន ខ្ញុំយកមកបានជាប់នឹងខ្លួន។ អត្តសញ្ញាណប័ណ្ណខ្ញុំមាន។ ភ្លេចភ្លាំងផង ខ្ញុំក៏ភ្លេចភ្លាំងហ្នឹងផង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យើងនឹងស្នើសុំឲ្យលោកផ្តល់បន្ទាប់ពីសម្រាក ដូច្នេះ សូមលោករក្សាទុកតាមខ្លួន និងមានអ្នកស្នើសុំពីលោក។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោកមេធាវី វ៉ិចទ័រ កូប៉េ យើងមានដំណោះស្រាយហើយ អ៊ីចឹងអាចដោះស្រាយបញ្ហាហ្នឹងបានហើយ។

បាទ ឥឡូវនេះអង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សេចក្តីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយ មុននឹងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ក្រឡាបញ្ជីយ៉ាងម៉េចទៅខាង -- ដូចជាបាត់ -- អូខេ។

បាទប្រគល់ភារៈ ប្រគល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី មុននេះយើងបាននិយាយអំពីវិហារវៀតណាមនៅក្នុងតំបន់របស់លោក ហើយមានគ្រួសារវៀតណាមជាច្រើននៅទីនោះមុនឆ្នាំ៧៥។ លោកបានឆ្លើយថា លោកមិនដឹងថាគ្រួសារទាំងអស់នេះ បានចាកចេញទៅ ឬក៏យ៉ាងណាទេ។ តើលោកអាចបញ្ជាក់បានទេថា ចាប់ពីពេលណា

ដែលលោកលែងឃើញគ្រួសារវៀតណាមទាំងអស់នោះ ក្រៅពីគ្រួសាររបស់ ចាន់ថា និងឪពុកម្ដាយនោះ?

**លោក អ៊ុំ ស៊ិន់ ៖**

**ឆ៖** ចាប់តាំងពីឆ្នាំ១៩៧៥ ឬ ៧៦ៗ -- ៧៥-៧៦ នេះឯង។

**ស៖** នៅពេលដែលលែងឃើញគ្រួសារវៀតណាមទាំងអស់នេះ តើគេអាចបែងចែករវាងគ្រួសារវៀតណាម និងគ្រួសារខ្មែរយ៉ាងម៉េចបាននៅពេលនោះ?

**ឆ៖** ភាសាវៀតណាម ភាសាខ្មែរ ជនជាតិវៀតណាម ខ្ញុំឃើញតែប៉ុន្មានគ្រួសារប៉ុណ្ណោះឯងទេ តែផុតពីនោះខ្ញុំមិនដឹងទេ។ គេចាកចេញទៅខាងណាក៏ខ្ញុំមិនដឹង។

[១៣:៣៣:៥៥]

**ស៖** យើងអាចនិយាយបានថា មុនឆ្នាំ៧៥ ជនជាតិវៀតណាមទាំងអស់នេះ មានប្រពៃណីវប្បធម៌ខុសពីយើងមែនទេ?

**ឆ៖** ទេ ប្រពៃណីវាដូចតែខ្មែរយើងអ៊ីចុះដែរ ព្រោះវៀតណាមនៅកន្លែងនោះ វាយូរយារណាស់មកហើយ។ បាទ ខ្ញុំដឹងតែប៉ុណ្ណោះ។

**ស៖** មុនពេលសម្រាក លោកបាននិយាយថា ពេលដែលលោកធ្វើការនៅក្នុងកងរបស់លោក លោកមិនដឹងថាមានអ្វីកើតឡើងនៅតាមភូមិនោះទេ។ លោកមិនដឹងថា តើមានការបញ្ជាឲ្យមេភូមិស្រាវជ្រាវរកវៀតណាមឬក៏អត់ទេ។ ដូច្នេះ ខ្ញុំសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញឈ្មោះរបស់ សាក្សីមួយរូបនៅក្នុងកំណត់ហេតុ E3/7685 គឺសាក្សី 2-TCW-846។ ខ្ញុំគ្រាន់តែបង្ហាញឈ្មោះសាក្សីរូបនេះជូនលោក សូមលោកកុំប្រាប់ឈ្មោះឲ្យគេដឹង ហើយលោកគ្រាន់តែប្រាប់ថា ស្គាល់ ឬមិនស្គាល់ទៅបានហើយ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតប្រគល់ទំព័រទី១នៃឯកសារ E3/7685 ទៅឲ្យសាក្សីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ប៉ុន្តែសួរទៅលោកសាក្សី តើលោកចេះអានអក្សរទេ?

**លោក អ៊ុំ ស៊ិន់៖**

**ឆ៖** ចេះអានតិចៗ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ អង្គជំនុំជម្រះអនុញ្ញាត ហើយលោក អរុណ ជួយអានឲ្យគាត់ស្ដាប់ខ្សឹបៗទៅបានហើយ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សីសូមកុំប្រាប់ឈ្មោះសាក្សី ដែលលោកកំពុងតែមើលហ្នឹង។ លោកអាចប្រាប់បានទេថា លោកស្គាល់គាត់ ឬក៏គាត់រស់នៅក្នុងភូមិយាងដែរ។

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** ស្គាល់ ខ្ញុំបាទស្គាល់។

**ស៖** លោកស្គាល់គាត់ហ្នឹងតាំងពីរបបកម្ពុជាប្រជាធិបតេយ្យមែនទេ?

**ឆ៖** បាទ ស្គាល់តាំងពីរបបប្រជាធិបតេយ្យហ្នឹងឯង។ ស្គាល់។

[១៣:៣៧:១៦]

**ស៖** ខ្ញុំសូមអាននូវសម្រង់នៃចម្លើយរបស់គាត់ គឺឯកសារ E3/7685 ទំព័រ២ ជាភាសាបារាំង ២ ជាភាសាអង់គ្លេស និង២ ជាភាសាខ្មែរ។ ពេលនោះ គេសួរគាត់ដូចតទៅ៖ "អ្នកដែលត្រូវគេសម្លាប់ទាំងនោះ លោកដឹងថាជាជនជាតិអ្វីទេ? គេឆ្លើយថា៖ ខ្ញុំឮគេថា អ្នកទាំងនោះជាជនជាតិវៀតណាម ពេលប្រមូលមនុស្សនោះ ប្រធានភូមិមានបញ្ជីស្ថិតិ ហើយគេប្រាប់ថាគេយកទៅឲ្យរៀនសូត្រ។" សូមបញ្ចប់ការដកស្រង់។ ហើយនៅទំព័របន្ទាប់មកទៀត គឺទំព័រទី៣ ជាភាសាបារាំង និងទំព័រ៤ ជាភាសាអង់គ្លេស, ទំព័រ៤ ជាភាសាខ្មែរ គេសួរថា៖ "មេភូមិដែលមានស្ថិតិជនជាតិវៀតណាមហ្នឹង តើមានបញ្ជាពីថ្នាក់លើឲ្យធ្វើយ៉ាងណាទេ? សាក្សីរូបនោះគាត់ឆ្លើយថា៖ បាទ មានការបញ្ជាពីថ្នាក់លើមក។" សូមបញ្ចប់ការដកស្រង់។ ខ្ញុំចង់សួរលោកថា តើលោកមានស្ថិតិជនជាតិវៀតណាមដែរឬទេ ពីព្រោះថាលោកសាក្សីរូបនោះ គាត់ថាមានបញ្ជីជនជាតិវៀតណាម។ ដូច្នេះ ខ្ញុំចង់ដឹងថាលោកធ្លាប់ឮថាគេមានធ្វើបញ្ជីស្ថិតិជនជាតិវៀតណាមដែរឬទេនៅសម័យនោះ?

**ឆ៖** ខ្ញុំមិនដឹងទេ។ ខ្ញុំមិនដឹង គាត់ដឹង ខ្ញុំឆ្លើយថាអត់ដឹង។

**ស៖** មុនចូលទៅនិយាយអំពីអ្វីដែលបានកើតឡើងនៅក្នុងវត្តខ្សាច់ ខ្ញុំចង់សួរលោកថា នៅចន្លោះឆ្នាំ៧៥ និងឆ្នាំ៧៨ នៅក្នុងភូមិយាង នៅក្នុងសហករណ៍របស់លោក ឬក៏នៅក្នុងឃុំ តើលោកធ្លាប់ចូលរួមក្នុងកិច្ចប្រជុំណាមួយជាមួយនឹងអាជ្ញាធរមូលដ្ឋានដែរឬទេ?

ឆ៖ អត់ទេ អត់បានចូលរួមទេ ព្រោះខ្ញុំអាល័យតែទៅរកអារឿងសេដ្ឋកិច្ចឲ្យគេ ក្នុងសហករណ៍។ ព្រោះកាលនោះគេប្រើទៅខាងរកត្រីសាច់ទេ ខ្ញុំទៅបាត់ៗនៅទន្លេ ព្រោះគេប្រជុំឯណាឯណី ខ្ញុំអត់ដឹង។

សៈ ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីវត្តខ្សាច់។ នៅឆ្នាំ១៩៧៨ តើវត្តនេះមានរបងព័ទ្ធជុំវិញទេ លោកអាចរៀបរាប់របងនេះបានទេ បើសិនបើមាននោះ?

ឆ៖ មាន ក្នុងវត្តខ្សាច់របងជុំវិញ ជុំវិញវត្ត មាន។

សៈ របងនោះ ជារបងស៊ីម៉ងត៍ ឬក៏ធ្វើពីវត្ថុធាតុផ្សេងទៀត?

ឆ៖ របងវត្តដែលគេធ្វើជុំវិញវត្តនោះ របងក្រាក់ទេ របងក្រាក់ឈើទេ។ ក្រាក់ឈើ ខ្លឹមឈើទេ។

[១៣:៤១:២៦]

សៈ យើងអាចមើលធ្លុះទៅខាងក្នុងទេ ពីខាងក្រៅទៅ យើងមើលឃើញធ្លុះតាមរបងហ្នឹង ឃើញដល់ខាងក្នុងទេ? ហើយមានកន្លែងណាមួយដែលរបងនេះធ្វើពីស៊ីម៉ងត៍ទេ?

ឆ៖ ទើបតែសម័យក្រោយទេដែលគេធ្វើស៊ីម៉ងត៍។ អង្កាល់នោះ ពីជំនាន់នោះ ធ្វើតែឈើទាំងអស់ហ្នឹងឯង របងក្រាក់នោះ ឈើក្រាក់។ ដល់សព្វថ្ងៃ របងគេស៊ីម៉ងត៍។

សៈ អ៊ីចឹង អ្នកដែលនៅខាងក្រៅនោះ អាចមើលឃើញវត្ត ឬក៏ព្រះវិហារនៅខាងក្នុងទេ?

ឆ៖ អាចមើលឃើញ ព្រោះអត់មានជញ្ជាំងជិតទេ របងមើលទៅចន្លោះប្រហោង មើលឃើញច្បាស់ ឃើញដល់វិហារ ជុំវិញវិហារទៀតនោះ។

សៈ អម្បាញ់មិញនេះ លោកថា អគារខ្លះត្រូវបានកម្ទេចចោល ជាពិសេសព្រះពុទ្ធរូបហ្នឹងក៏ត្រូវបានគេកម្ទេចចោលដែរ ហើយនៅសល់តែកុដិលោកតែប៉ុណ្ណោះ។ នៅក្នុងវត្តនោះមានហោត្រៃទេ?

ឆ៖ ក្នុងវត្តនោះ មានហោត្រៃ។ មាន មានហោត្រៃ។ មានបន្ទប់គេ គេដាក់ក្នុងនោះឯង។

សៈ តើហោត្រៃដែលគេដាក់គម្ពីត្រៃបិដកនោះ មានទំហំប៉ុន្មានដែរ លោកអាចបញ្ជាក់បានទេ បណ្ដោយប៉ុន្មាន? ទទឹងប៉ុន្មានដែរ?

ឆ៖ បណ្ដោយវាប្លួនជ្រុងទ្រវែង ប្រហែលជាទទឹង ទទឹងវាប្រហែល៧ម៉ែត្រ។ បណ្ដោយប្រហែលជា១០ម៉ែត្រ។ កម្ពស់ទៅលើប៉ុន្មាន ៣ម៉ែត្រៗ ជិតទៅ ៤ម៉ែត្រងណោះ។

សៈ ហោត្រៃមានប៉ុន្មានជាន់ដែរ តែមួយជាន់ផ្ទាល់ដីទេ ឬក៏មានច្រើនជាន់ទៅលើទៀត?

ផ៖ មានតែមួយជាន់ទេ ធ្វើផ្ទាល់នឹងដីតែម្តង មានតែមួយជាន់ទេ។

[១៣:៤៥:០៥]

ស៖ បើយើងឈរទៅក្រៅរបង យើងមើលឃើញហោត្រៃទេ? ជាពិសេសបើយើងមើលពីខាងជើង ហើយនិងខាងកើត យើងអាចមើលឃើញហោត្រៃហ្នឹងទេ?

ផ៖ មើលឃើញ អាចមើលឃើញពីត្បូងក៏មើលឃើញ ពីកើតក៏មើលឃើញ ពីជើងក៏មើលឃើញ បើពីខាងលិចមើលមិនឃើញទេ កំបាំងនឹងសាលាឆាន់ និងកុដិ។

ស៖ លោកបាននិយាយជាច្រើនលើកច្រើនសាថា មនុស្សមួយចំនួនត្រូវបានគេសម្លាប់នៅវត្តខ្សាច់ ជាពិសេសគឺគ្រួសាររបស់ ចាន់ថា និងឪពុកម្តាយរបស់នាងដែលជាជនជាតិវៀតណាមនោះត្រូវបានគេសម្លាប់នៅវត្តនោះ។ ឥឡូវនេះ ខ្ញុំចង់សួរលោកឲ្យជម្រាបជូនអង្គជំនុំជម្រះអំពីអ្វីដែលលោកបានឃើញពាក់ព័ន្ធនឹងការសម្លាប់មនុស្សទាំងអស់នេះ។ ហើយការសម្លាប់មនុស្សហ្នឹងកើតឡើងនៅពេលណាដែរ?

ផ៖ កើតនៅពេលណា កាលណោះពេលម៉ោង១ប្រហែលជាប្រាំមួយ ប្រាំពីរ មើលគ្នាស្ទង់ៗឃើញ។ គេសម្លាប់តាំងពីម៉ោងប្រាំពីររហូតដល់ម៉ោងរយ:មួយដណ្តប់បានអស់ មួយដណ្តប់យប់។

ស៖ លោកដឹងទេថា ក្រៅពីគ្រួសារ ចាន់ថា អ្នកដែលគេសម្លាប់នៅវត្តខ្សាច់ហ្នឹងសុទ្ធតែជាជនជាតិវៀតណាមមែនទេ?

ផ៖ បាទ ជនជាតិវៀតណាម វាសម្លាប់សុទ្ធតែជនជាតិវៀតណាម ដែលគេសម្លាប់ហ្នឹង។

ស៖ ម៉េចបានជាលោកដឹងថាអ្នកទាំងអស់ហ្នឹងសុទ្ធតែជាជនជាតិវៀតណាម?

ផ៖ ខ្ញុំដឹង ខ្ញុំស្គាល់ អារឿងនិយាយរាងប៉ែឡាំៗ ខ្ញុំស្គាល់វៀតណាម។ វាមិនដូចខ្មែរសុទ្ធណា។

ស៖ ពេលដែលលោកសង្កេតឃើញ ឬក៏មើលឃើញគេសម្លាប់មនុស្សហ្នឹង លោកមានស្តាប់ឮជនជាតិវៀតណាមហ្នឹងនិយាយទេ?

ផ៖ ឮតែស្នូរស្រែក និយាយ ស្រែកដែលគេវ៉ៃ ដែលគេវាយ ឮស្នូរស្រែក។ អើតមើលទៅមានឃើញអី វាយស្រែក។ ខ្ញុំបានឮ បានអើតឃើញដែរ។

[១៣:៤៩:១៦]

ស៖ លោកដឹងថា ជនជាតិវៀតណាមទាំងអស់ហ្នឹងមកពីណាទេ? ខ្ញុំចង់ដឹងថា គេនាំពីសហករណ៍ណា ពីភូមិណា ពីឃុំណាទៅកាន់វត្តខ្សាច់នោះ?

**ឆ៖** ខ្ញុំមិនដឹងដែរអារឿងត្រង់នោះ មិនដឹងទេ អត់ដឹង។ ស្រាប់តែទៅឃើញដាក់ក្នុងហោត្រៃនេះឯងក៏និយាយ ង៉ូងង៉ាំងៗ វៀតណាម។ គេដាក់ឃុំក្នុងហោត្រៃ។

**ស៖** ពាក់ព័ន្ធទៅនឹងរយៈកាលពិតប្រាកដនេះ ហេតុការណ៍ទាំងអស់នេះ តើលោកចាំទេថាគេប្រមូលជនជាតិវៀតណាមទាំងអស់នេះយកទៅដាក់នៅវត្តខ្សាច់ហ្នឹងក្នុងឆ្នាំណាដែរ?

**ឆ៖** ក្នុងឆ្នាំ៧៥-៧៦ នោះឯង។ ៧៥-៧៦នោះឯង ក្នុងឆ្នាំនោះឯង។

**ស៖** ខ្ញុំសូមរំឭកនូវចម្លើយរបស់លោកដែលលោកបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេតកាលពីប៉ុន្មានឆ្នាំមុននេះគឺឯកសារ E3/7778 គឺនៅចម្លើយទី២ នៃកំណត់ហេតុ។ លោកបានឆ្លើយដូចតទៅ៖ "ថ្ងៃមួយប្រហែលជានៅក្នុងឆ្នាំ១៩៧៨ ខ្ញុំបានឮសូរសំឡេងមនុស្សស្រែក ហើយខ្ញុំបានទៅលបមើលជាមួយឈ្មោះ ស៊ង់។ ខ្ញុំបានឃើញខ្មែរក្រហមវាយសម្លាប់មនុស្សនៅខាងត្បូងវត្ត ជ្រុងខាងកើតនៅខាងក្រៅរបង។" ដូច្នេះពេលនោះ ពេលដែលសហចៅក្រមស៊ើបអង្កេតសួរលោកៗថាប្រហែលជានៅឆ្នាំ៧៨ ឥឡូវលោកថា៧៥-៧៦ អ៊ីចឹងតើលោកនឹកឃើញឡើងវិញហើយឬនៅ ប្រហែលជានៅឆ្នាំណា?

**ឆ៖** បន្ទាប់ វាក្នុងកាលរយៈ៧៦, ៧៧, ៧៨ នោះឯង វាតៗគ្នាជាប់នឹងឆ្នាំនោះឯង។ រដឹន វាមួយសា ពីរសា បីសានោះ កន្លែងនោះ មិនមែនតែម្តងទេ ពីរដងនៅកន្លែងនោះឯង។ ហើយច្បាស់ប៉ុណ្ណោះហើយ មិនដឹងថាយ៉ាងម៉េចទៀត។

[១៣:៥២:១២]

**ស៖** មិនជាបញ្ហាអ្វីទេ ខ្ញុំគ្រាន់តែសួរឲ្យលោកនឹកឃើញអំពីពេលវេលាពិតប្រាកដ ដែលលោកបានឃើញការសម្លាប់មនុស្ស។ ប្រហែលជាយើងអាចនិយាយបានម៉្យាងទៀតថា បើយើងគិតទៅថាប្រហែលជាប៉ុន្មានខែមុនពេលវៀតណាមវាយចូលនៅក្នុងឆ្នាំ៧៩ ហ្នឹងដែលលោកបានឃើញការសម្លាប់ជនជាតិវៀតណាមនៅវត្តខ្សាច់នេះ?

**ឆ៖** ពីឆ្នាំ៧៧ និង៧៨ ហ្នឹងឯង ជាប់ៗគ្នាហ្នឹងឯង។

**ស៖** ខ្ញុំសូមអាននូវសម្រង់មួយទៀត ដែលជាចម្លើយរបស់សាក្សីមកពីភូមិយាង គឺឯកសារ E3/7686 ទំព័រជាភាសាបារាំង 00332891 ទៅដល់ 92, ជាភាសាអង់គ្លេសគឺ 00275406 ទៅដល់ 07, ជាភាសាខ្មែរគឺ 00221620 ទៅដល់ 21។ លោកសាក្សីគឺសាក្សីរូបនោះគាត់ឈ្មោះថា ឡូញ ឃុន គឺមកពីភូមិយាង គាត់ថាការសម្លាប់មនុស្សនៅភូមិខ្សាច់ហ្នឹង គឺខែសីហា ឆ្នាំ១៩៧៨ ហើយនៅក្នុងកំណត់ហេតុនេះគាត់និយាយអំពីការសម្លាប់ប្តីគាត់ឈ្មោះជុំ ហើយនិងម្តាយក្មេករបស់គាត់ឈ្មោះ ញ៉ាវ

និងបងថ្លៃរបស់គាត់ឈ្មោះគា បងថ្លៃស្រីឈ្មោះហុង និងប្តីរបស់គាត់ឈ្មោះថៃ ហើយនិងកូនបីនាក់ទៀត ដែលជាកូនរបស់ហុង។ មានក្មេងខ្លះអាយុត្រឹមតែមួយខែ មួយឆ្នាំ ឬក៏បីឆ្នាំ។ គាត់និយាយថាគេនាំទៅសម្លាប់ចោលហ្នឹង ដោយសារតែម្តាយក្មេកហ្នឹងគឺ -- ឪពុកម្តាយក្មេកវៀតណាម ជាវៀតណាម។ តើលោកស្គាល់ឈ្មោះ ឡូញ ឃុន ទេ ហើយនិងគ្រួសាររបស់គាត់ដែលខ្ញុំបានផ្តល់ឈ្មោះអម្បាញ់មិញហ្នឹងទេ?

**ឆ៖** បាទ ស្គាល់។ ខ្ញុំបាទស្គាល់ៗ ឡូញ ឃុន។

**ស៖** សាក្សីរូបនោះបាននិយាយថា កាលសម្លាប់ហ្នឹងគឺកើតឡើងតែប៉ុន្មានខែមុនពេលកងទ័ពវៀតណាមវាចូលកម្ពុជាតែប៉ុណ្ណោះ។ លោកៗថាឆ្នាំ៧៧, ៧៨។ សាក្សីរូបនោះគាត់ថា នៅខែសីហា ឆ្នាំ៧៨ គឺគ្រាន់តែបីបួនខែមុនពេលកងទ័ពវៀតណាមវាយចូលតែប៉ុណ្ណោះ។ លោកមាននឹកឃើញអ្វីខ្លះឡើងវិញទេ?

**ឆ៖** មាននឹកឃើញ វេបន្តបន្ទាប់គ្នា។ គេយកទៅសម្លាប់ចោលក្នុងកន្លែងនោះ វាពីរដង វគ្គមុន វគ្គទី១ វគ្គទី២ បាទ។

[១៣:៥៦:៣៣]

**ស៖** តើលោកដឹងទេថា សមាជិកក្រុមគ្រួសារដែលជាជនជាតិវៀតណាមនោះ ដូចជាឈ្មោះម្តាយក្មេកឈ្មោះញ៉ាវ ប្អូនប្រុសឈ្មោះគា ប្អូនស្រីឈ្មោះហុង ឈ្មោះថៃ។ លោកដឹងថាអ្នកទាំងអស់ហ្នឹងត្រូវបានគេសម្លាប់នៅវត្តខ្សាច់ដែរឬទេ?

**ឆ៖** ព្រោះវគ្គនោះវគ្គមុន ខ្ញុំអត់បានដឹងទេ ប៉ុន្តែស្គាល់ឈ្មោះអ្នកទាំងនោះ។

**ស៖** ខ្ញុំមិនសួរអ្វីច្រើនទេ ក៏ប៉ុន្តែសាក្សីរូបនោះ គាត់ថានៅខែសីហា ឆ្នាំ៧៨ ដែលគេសម្លាប់មនុស្សនៅវត្តខ្សាច់ហ្នឹង។ តើគ្រួសាររបស់ ឡូញ ឃុន មានសាច់ញាតិ មានជាប់សាច់ឈាមអីជាមួយនឹងគ្រួសាររបស់ ចាន់ថា គឺ តាឃុត និង យាយម៉ា ហ្នឹងទេ?

**ឆ៖** ទេ រឿងត្រង់នោះខ្ញុំអត់ដឹងដែរ មិនដឹងជាជាប់សាច់ញាតិរបៀបម៉េច ខ្ញុំមិនដឹងដែរ។ ខ្ញុំអត់ដឹងទេ អារឿងសាច់ញាតិ។ ប៉ុនខ្ញុំស្គាល់ៗ ខ្ញុំបាទស្គាល់។ មិនបានជាសួរនាំថាសាច់ញាតិជាប់ពូជពង្សសាវតារ ក៏ខ្ញុំមិនបានដឹង ប៉ុន្តែខ្ញុំស្គាល់មនុស្ស បាទ។

**ស៖** លោកបាននិយាយជាហូរហែអំពីការសម្លាប់ ចាន់ថា និងឪពុកម្តាយរបស់គាត់។ លោកដឹងទេថា គេនាំ ចាន់ថា ទៅវត្តខ្សាច់ហ្នឹងយ៉ាងម៉េច? គេមានប្រាប់មូលហេតុថា ហេតុអីបានជាត្រូវទៅ

នោះ? គេមានប្រាប់ ពេលដែលគេនាំយក ចាន់ថា ទៅនោះ?

**ឆ៖** គេមិនបានប្រាប់ទេ គេ។ គ្រាន់តែឮអ្នកស្រុកគេនិយាយ ប្រជាជនគេនិយាយ។ គេថាយកទៅរៀនសូត្រ តែមិនបានរៀនសូត្រ ទៅបាត់ ដល់បាត់មួយថ្ងៃពីរថ្ងៃ មួយយប់ពីរយប់ គេដឹងថា អូ៎! ចប់រឿងបាត់ទៅហើយ។ ស្រាប់តែឃើញអ្នកក្រោយទៀតដែលគេសម្លាប់ ដែលរស់នៅសល់នៅលើគោកនោះ ដែលបញ្ចូលអន្លង់វាមិនអស់។

**ស៖** លោកមានបានឃើញសាកសពរបស់ ចាន់ថា នៅក្រៅវណ្ដៅទេ? ឬក៏លោកបានឃើញការសម្លាប់ ចាន់ថា នេះផ្ទាល់នឹងភ្នែកទេ?

[១៣:៥៩:៥៦]

**ឆ៖** ខ្ញុំមិនបានទៅមើល ចូលទៅមើលកៀកបៀតទេ តែខ្ញុំមើលតែពីចម្ងាយប្រហែល៣០ម៉ែត្រប៉ុណ្ណោះអីទេឃើញ។ អូ៎! ភ័យខ្លាំង ខ្ញុំនាំគ្នារត់មកផ្ទះវិញ។

**ស៖** អ្វីដែលខ្ញុំចង់ដឹងនោះ គឺថាតើលោកឃើញ ចាន់ថា និងយាយតារបស់ ចាន់ថា ហ្នឹងត្រូវបានគេនាំយកទៅវត្តខ្សាច់ហើយ សម្លាប់នៅទីនោះទេ?

**ឆ៖** ឃើញគេសម្លាប់ហើយ មែនថាមិនឃើញអី ឃើញហើយ។ ភ័យខ្លាំងហើយបានខ្ញុំរត់មកផ្ទះវិញ។ ខ្ញុំឃើញហើយ។ ភ័យខ្លាំងពេករត់មកផ្ទះវិញ ពេលនោះ អង្កាល់នោះ។

**ស៖** ពេលលោកឃើញសាកសពហ្នឹង លោកមានឃើញអ្វីដែលគួរឲ្យកត់សម្គាល់ ដែលធ្វើឲ្យលោកមានការរន្ធត់អីទេ មានស្នាមនៅកន្លែងណាដែលមើលទៅគួរឲ្យភ័យរន្ធត់ទេនៅលើខ្លួនរបស់សាកសពហ្នឹង?

**ឆ៖** និយាយពីឃើញនោះ វាភ័យភិតនោះ ភ័យពីភ័យហើយ អស់ព្រលឹងហើយ។ មិនហ៊ាននៅជិតទេ ខំបោះពួយឲ្យបានទៅដល់ទិសដៅឯកន្លែងផ្ទះវិញប៉ុណ្ណោះឯង។ វាញ័រចំប្រប់អស់ហើយ ភ័យនោះ និយាយពីភ័យនោះ រកអ្វីមកប្រៀបផ្ទឹមមិនបានទេ។ ក្រោយឃើញហេតុការណ៍មិនប្រក្រតីអារឿងកន្លែងនោះវ៉ៃខ្លាំងហ្នឹង ក៏នាំគេចខ្លួនមកផ្ទះវិញតែប៉ុណ្ណោះហើយ។

**ស៖** ខ្ញុំនឹងត្រឡប់មកនិយាយអំពីរឿងនេះនៅពេលក្រោយ។ មុននេះលោកនិយាយថា លោកឮសំឡេងស្រែកយំចេញមកពីវត្ត ធ្វើឲ្យលោកចង់ដឹងថាមានរឿងអ្វីកើតឡើងនៅក្នុងវត្តនោះ។ ពេលគេនាំមនុស្សទាំងអស់នោះទៅដល់វត្តហ្នឹង អ្នកទាំងអស់ហ្នឹងនៅវត្តហ្នឹងប៉ុន្មានថ្ងៃ ឬក៏គ្រាន់តែទៅដល់ភ្លាមតែមួយថ្ងៃហ្នឹង គេសម្លាប់ចោលតែម្ដង ឬក៏គេទុកប៉ុន្មានថ្ងៃសិន?

**ឆ៖** អត់ទេ ក្នុងដែលគេយកទៅនោះ យកទៅពីល្ងាចអាថ្ងៃរៀបលិចហើយ គេយកទៅដល់កន្លែងវត្ត ហើយអត់ទាន់សម្លាប់ទេ។ ស្រាប់តែដល់ខ្ញុំត្រឡប់មកផ្ទះវិញ ឃើញ ឮសូរស្រែកហើយ បានខ្ញុំទៅលបមើល ទៅលបស្តាប់។ ដល់ទៅលបៗទៅ ឃើញមែន កំពុងតែវ៉ៃ សម្លាប់។ ខ្ញុំក៏ភ័យនៅមិនបានទេ ក៏នាំ អាស៊ង់ រត់មកផ្ទះវិញ – ស៊ាន ស៊ង់ ហ្នឹង។

[១៤:០៣:៤១]

**ស៖** មុនពេលលោកឃើញគេសម្លាប់មនុស្ស លោកឆ្លើយថាគេនាំទៅហ្នឹងពេលល្ងាច ហើយគេឃុំក្នុងហោត្រៃ។ តើមានអ្នកណាដែលគេនាំមកដល់វត្តហើយរត់គេចចេញពីវត្ត ដែលគេ កន្លែងដែលគេឃុំឃាំងហ្នឹងទេ?

**ឆ៖** ឃើញហេតុការណ៍មិនស្រួលហ្នឹងហើយ ខ្ញុំរត់មកវិញ គេចខ្លួនមកវិញមក។ ស្រាប់តែដល់ព្រលប់យប់ឮសូរមាត់ស្រែកហ្នឹងឯង នៅមិនបានហ្នឹងឯង បានខ្ញុំទៅលួចមើល ទៅលបមើល។ ឮស្រែកយ៉ូយៗ ភីសភូសៗ ខ្ញុំក៏លូនៗទៅលបមើល។ ទៅដល់ឃើញមែន ឮមែន វ៉ៃមែន។ ឮសូរសម្រែកស្រែកហ្នឹងឯង បានខ្ញុំទៅលបមើលហ្នឹង។ កុំឲ្យតែឮសូរស្រែក ក៏មិនដឹងថាគេវាយមនុស្សរបៀបណា។ ដល់ឮសូរស្រែកហ្នឹង បានខ្ញុំទៅលបមើល។

**ស៖** បាទ អ៊ីចឹងមានអ្នកដែលត្រូវគេវាយហ្នឹង ខ្លះនោះ អាចរត់រួចទេ មានអ្នកណាអាចមានជីវិតរួចផុតពីការសម្លាប់នៅវត្តហ្នឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាសនឹងសំណួរនេះ លោកប្រធាន។ នេះជា គឺសុំឲ្យសាក្សីឆ្លើយស្មាន ពីព្រោះគាត់មិនដឹងពីអ្វីថាតើថា អ្នកដែលគេឃុំឃាំងហ្នឹងមានលទ្ធភាពរត់គេចខ្លួនឬអត់ទេ។ ដូច្នេះខ្ញុំសូមជំទាស់។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំនឹងរៀបសំណួរឡើងវិញលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី ពេលដែលលោកៗលបមើលនុ៎ះ លោកឃើញមានអ្នកយាមដែលនាំមនុស្សយកទៅសម្លាប់នោះហ្នឹងមានកាន់កាំភ្លើងទេ?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** ទេ អ្នកដែលគេនាំទៅសុទ្ធតែមានកាំភ្លើងគេ តែដែលសម្លាប់នោះ ដែលនេះ វាយនឹងដំបង ទេ គល់ឫស្សី គល់ល្ងៀង។ អ្នកដែលគេនាំទៅនោះ គឺកាំភ្លើងគេហ្នឹងឯង គេនាំទៅ។ តែដល់សម្លាប់នោះ សម្លាប់នឹងដំបងឫស្សី និងគល់ល្ងៀងទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីពេលដែលលោកបានឃើញការសម្លាប់មនុស្ស លោកថា លោកបានទៅមើលជាមួយនឹងមិត្តភក្តិរបស់លោកម្នាក់ទៀត គឺឈ្មោះ ស៊ាន ស៊ង់។ ពេលលោកទៅហ្នឹង ទៅដល់ជាមួយគាត់ ហើយត្រឡប់មកវិញក៏ត្រឡប់មកវិញជាមួយគាត់ក្នុងពេលតែមួយមែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! កុំអាលៗទាន់ឆ្លើយតបសាក្សី!

[១៤:០៧:២០]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន សាក្សីមានលទ្ធភាពក្នុងរយៈពេល២៥នាទីនេះ គឺគាត់ឆ្លើយទៅគឺផ្ទុយនឹងព័ត៌មានខ្លួនគាត់ហើយ គាត់មិនបានឃើញការសម្លាប់ ប៉ុន្តែឥឡូវនេះ គាត់ឆ្លើយថាបានឃើញការសម្លាប់។ គាត់ឃើញមនុស្សនៅក្នុងហោត្រៃ។ ឥឡូវនេះ គឺថាធ្វើឲ្យគាត់មានការសន្និដ្ឋានថាមនុស្សនៅក្នុងហោត្រៃនោះគឺស្រែក។ ដូច្នេះ គឺថាហាក់ដូចជាសហព្រះរាជអាជ្ញាបង្ហាញថា មានប្រហោងគាត់មើលទៅឃើញពីអ្វីដែលសហព្រះរាជអាជ្ញាចង់បាន ឲ្យសាក្សីឆ្លើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសង្ខេប។ បាទ បើសិនជាលោកចង់សង្ខេបភស្តុតាងអ៊ីចឹងគឺថាសហព្រះរាជអាជ្ញាមិនអាចនឹងសួរបានទេ។

**ប្រធានអង្គជំនុំ៖**

បាទ តាំងសំណួរបន្តទៀតចុះ! ហើយលោកមេធាវី វ៉ិចទ័រ កូប៉េ ឱកាសលោកនឹងមាន។ អ៊ីចឹងហើយបានជានីតិវិធីតុលាការ ទុកលទ្ធភាពជូនទៅខាងមេធាវីការពារក្តីសួរនៅពេលក្រោយភាគីម្ខាងទៀតសួរ។ ខាងសហព្រះអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសួរបញ្ជាក់គ្នា ផ្ទៀងផ្ទាត់ចំណុចដែលខ្វះចន្លោះ ឬក៏ចំណុចដែលមានប្រយោជន៍សម្រាប់ការពារក្តី។ សូម

អញ្ជើញ! ហើយមុននឹងផ្តល់វេទិកាទៅ សុំ អង្គជំនុំជម្រះបាន -- ក្រឡាបញ្ជីអង្គជំនុំជម្រះបានទទួលនូវអត្តសញ្ញាណប័ណ្ណរបស់សាក្សីរូបនេះ ហើយបានថតចម្លងរួចហើយ ហើយសូមក្រឡាបញ្ជីឆ្លៀតពេលចែកចាយជូនទៅភាគី និងចៅក្រម នូវឯកសារថតចម្លង ហើយនិងពេលចប់នៅម៉ោងនេះ រៀបចំប្រគល់នូវឯកសារដើមជូនទៅលោកសាក្សីវិញផង។

បាទ សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាការជំទាស់របស់មេធាវីហ្នឹង គឺកំពុងតែព្យាយាមជះឥទ្ធិពលទៅលើសាក្សីហើយ។ លោកសាក្សីខ្ញុំសួរម្តងទៀត។ ពេលដែលលោកទៅដល់កន្លែងសម្លាប់ ទៅកន្លែងដែលលបមើលសម្លាប់ គេសម្លាប់មនុស្សហ្នឹង លោកទៅដល់កន្លែងហ្នឹង ហើយនិងលោកចាកចេញពីកន្លែងហ្នឹងវិញ គឺក្នុងពេលតែមួយជាមួយនឹងមិត្តរបស់លោក ស៊ាន ស៊ង់ ហ្នឹងមែនទេ?

[១៤:០៩:៥៣]

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** អ៊ីចេះណា៎ ជាដំបូងដែលគេ មុនដែលយកទៅសម្លាប់ចោល គេមិនដឹកយកមកដាក់ហោត្រៃ។ ដាក់ហោត្រៃពីថ្ងៃល្ងាចរសៀលម៉ោងបួនៗ អើម៉ោងបួននោះឯង។ ស្រាប់តែដល់ពេលយប់នោះវេលាយប់នោះឯង ល្ងាចនោះឯង ស្រាប់តែឮស្នូរស្រែក បានជាខ្ញុំទៅលបមើលនោះ ព្រោះចាប់ពីល្ងាចពីថ្ងៃម៉ោងបួន។ ក្នុងយប់នោះ ល្ងាចនោះ ឮស្នូរស្រែក បានខ្ញុំទៅលបឃើញ បើមិនឮស្នូរស្រែក ខ្ញុំមិនបានទៅលបឃើញទេ ព្រោះឮស្នូរស្រែកហើយក៏ ស៊ាន ស៊ង់ នេះក៏ទៅជាមួយខ្ញុំដែរ ពីមុខពីក្រោយ ភ័យអន្ទាក់អន្ទុប ដល់ឮស្នូរវ៉ៃទូងៗ – ទូង! អូយ! ទូង! អូយ! នេះឯង វាភ័យខ្លាំងនាំគ្នារត់មកផ្ទះវិញតែប៉ុណ្ណោះ ឯង។ ស្រាប់តែព្រឹកឡើងទៅទៀត ដល់ទៅមើលទ្វារដែលដាក់ក្នុងហោត្រៃនោះ វាចំហទ្រុងអស់មនុស្សទៅបាត់។ វាអស់ពីកន្លែងហោត្រៃ អស់រលីង។ ដល់ទៅមើលខ្មោចនោះ ដាក់ក្នុងអន្លង់នោះមិនទាំងជិតផងនៅលើគោកខ្លះ មិនដឹងខ្ញុំនិយាយថាម៉េចទៀតទេ ខ្ញុំវាច្បាស់នឹងភ្នែកខ្ញុំប៉ុណ្ណោះទៅហើយនិយាយថាម៉េច! ខ្ញុំឃើញប៉ុនណា ខ្ញុំថាប៉ុណ្ណោះ។

**ស៖** សូមអរគុណលោកសាក្សី។ សូមលោកស្តាប់សំណួរខ្ញុំឲ្យច្បាស់មុននឹងលោកឆ្លើយ។ ខ្ញុំនឹងសួរសំណួរលោកជាលំដាប់ៗ។ ពេលដែលលោកទៅដល់កន្លែងលបមើលហ្នឹង លោកបានឃើញគេសម្លាប់មនុស្សរួចទៅហើយមែនទេ មិនមែនលោកទៅដល់ឃើញគេទើបតែសម្លាប់ទេ គឺគេចាប់ផ្តើម

សម្លាប់ហើយៗមែនទេ ពេលដែលលោកទៅដល់នោះ?

**ឆ៖** បាទ ស្តាប់ខ្ញុំឲ្យទាន់ណា។ កាលពីល្ងាច កាលពីថ្ងៃល្ងាច ឃើញគេដឹកយកទៅដល់។ ក្នុងរាត្រីពេលនោះឯង មិនយប់ទៅវិញ។ ដល់យប់ម៉ោងប្រាំមួយ ម៉ោងប្រាំពីរនេះឯង ឮសួរគេវៃតែម្តង គេបញ្ចេញវៃ។ គេដឹកពីថ្ងៃម៉ោងបួន យកទៅដាក់ក្នុងហោត្រៃ។ ស្រាប់តែគេបិទជិត យប់នោះឯងគេត្រូវការបញ្ចេញមកវៃចោល។ ខ្ញុំឮសួរស្រែក ម្ល៉ោះហើយខ្ញុំរត់ពីផ្ទះខ្ញុំ ខ្ញុំទៅលបមើលឃើញ។ មែន ច្បាស់មែន។ ដល់ព្រឹកឡើង ខ្ញុំទៅមើលទៀត ទ្វារដែលដាក់ពីល្ងាចនោះ វាចំហអស់រលីងហើយ វៃអស់ទៅបាត់ហើយ។

[១៤:១២:៥៥]

**ស៖** អម្បាញ់មិញនេះ លោកថាលោកបានលបមើលមួយសន្ទុះ ក្រោយមកលោករត់ទៅផ្ទះវិញ គឺរត់ទៅកងដែលលោកសម្រាកហ្នឹងវិញ។ ពេលដែលលោកចាកចេញហ្នឹង ពេលដែលលោករត់ចេញហ្នឹងគេនៅតែបន្តសម្លាប់មនុស្សទៀត ឬក៏ឈប់ហើយ? លោកថា គេឈប់សម្លាប់មនុស្សហ្នឹង គឺប្រហែលនៅម៉ោងដប់យប់។ អ៊ីចឹងខ្ញុំចង់ដឹងថា ពេលដែលលោករត់ត្រឡប់ទៅផ្ទះវិញហ្នឹងប្រហែលជាម៉ោងប៉ុន្មានដែរ?

**ឆ៖** ខ្ញុំ តាមខ្ញុំដឹង វាប្រាកដណាស់ហើយ វាច្បាស់ណាស់ហើយ ចាប់ពីល្ងាច ពីថ្ងៃម៉ោងបួនហើយយប់នោះ ដល់យប់វៃរហូតដល់ម៉ោងដប់បានអស់មនុស្សនោះ។ ខ្ញុំក៏រត់ទៅផ្ទះតែម្តង ក៏នាំគ្នារត់ទៅផ្ទះ គេចខ្លួនកុំឲ្យគេឃើញ ទៅភ័យរណ្ដំ ញ័រតតុបហ្នឹងឯង។

**ស៖** លោកអាចគិតឲ្យបានច្បាស់បន្តិចទៅមើល ខ្ញុំដឹងថាពេលនោះ លោកមិនមាននាឡិកាទេ ក៏ប៉ុន្តែលោកអាចប៉ាន់ស្មានទៅមើល៍ ថាលោកលបមើលហ្នឹងប្រហែលជាប៉ុន្មានម៉ោងដែរ?

**ឆ៖** មិនបានជាមាននាឡិកាហ្នឹងផ្ទៀងទេ កាលនោះ ខ្ញុំវាគ្មាននាឡិកាពាក់ទេ ប៉ុន្តែខ្ញុំស្មានមើលមិនខុសទេ កាលនោះ។ មើលគ្នាស្គាល់នៅឡើយតើ វៃពីភ្លឺមើលគ្នាច្បាស់រហូតទៅទាល់ម៉ោងដប់ឯណោះ បានអស់មនុស្ស ខ្ញុំក៏រត់ទៅវិញ រត់ទៅផ្ទះវិញ។ មិនដឹងនិយាយថាម៉េចទៀត ដឹងច្បាស់ប៉ុណ្ណោះហើយ។

[១៤:១៥:១៤]

**ស៖** បាទ ល្អហើយ អ្វីដែលខ្ញុំសួរលោកឲ្យប្រាប់ ហើយឲ្យនិយាយការពិត នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ លោកនិយាយថា លោកបានស្ថិតនៅកន្លែងនោះប្រហែលជាមួយម៉ោង ហើយឆ្លើយតបទៅ

នឹងការចងចាំរបស់លោកទេ ឬក៏លោកនៅឃ្ងរជាងនោះ?

**ឆ៖** ខ្ញុំថាវាមិនប្រាកដទេ តាមអ៊ីចឹងទៅវាភ្លេចភ្លាំងខ្លះ មិនដឹងជាម៉ោងប៉ុន្មាន ប៉ុន្មានម៉ោង ប៉ុន្មាននាទី ក៏ខ្ញុំមិនបានជាចាប់អារម្មណ៍ នឹកឃើញថាដែលអស់រលីងហើយ ក៏ខ្ញុំដាក់មេធាយរត់តែប៉ុណ្ណោះ ភ័យខ្លាំង កំពុងឃើញដែលគេប្រហារជីវិតអ៊ីចឹងនោះ និយាយពីភ័យញ័រចំប្រប់ដូចកង្កែបប្រឡាក់អំបិលទៅហើយ រត់មកឱ្យតែរួច ឲ្យតែផុត ខ្លាចតែគេដឹង គេឃើញ គេវ៉ៃទាំងអាអ្នកឃើញទៅទៀត។ សម័យនោះណា ខ្ញុំហ្នឹង វាម៉េច ខ្ញុំខ្លាចគេដែរ។

**ស៖** តើលោកអាចធ្វើដូចម្តេចទើបអាចចូលទៅជិតកន្លែងគេសម្លាប់នោះបាន ដែលអ្នកឃាតករនោះមិនអាចក្រឡេកមើលឃើញលោក នៅពេលដែលលោកនៅចម្ងាយតែ១០ម៉ែត្រនោះ តើលាក់ខ្លួនយ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំមិនប្រាកដថាខ្ញុំយល់ច្រឡំទេ ប៉ុន្តែខ្ញុំមើលឃើញថាគាត់ប្រហែលជានៅ៣០ម៉ែត្រពីកន្លែងនោះ។ ប្រហែលជាខ្ញុំមិនយល់សំណួរសហព្រះរាជអាជ្ញា ខ្ញុំមិនឮពីសាក្សីគាត់ថា ១០ម៉ែត្រទេ។ ដូច្នេះ ខ្ញុំសូមជំទាស់ទៅនឹងសំណួរដោយសហព្រះរាជអាជ្ញា ប្រសិនបើគាត់បញ្ជាក់ពីនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

មេធាវីមិនយល់ពីអ្វីខ្ញុំនិយាយទេ ដូចថា និយាយថាប្រហែលបួន-ដប់ម៉ែត្រ។ បួនដប់ម៉ែត្រនោះមានន័យថា ៣០ម៉ែត្រ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** ឥឡូវលោកសាក្សី តើប្រសិនបើក្នុងករណីដែលលោកនៅ១០ម៉ែត្រ ឬក៏ជាង១០ម៉ែត្រ តើអ្នកសម្លាប់ហ្នឹងមិនឃើញលោកហ្នឹង លោកពួនយ៉ាងម៉េច?

[១៤:១៧:៤៧]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! លោកតំណាងសហព្រះរាជអាជ្ញារងអន្តរជាតិ រៀបចំសំណួរឡើងវិញ គឺ

សាក្សីបានឆ្លើយរួចហើយ គឺខ្លួននៅចម្ងាយពីកន្លែងដែលគេសម្លាប់ហ្នឹង៣០ម៉ែត្រ។ អានេះព្រឹកមិញ គឺឆ្លើយច្បាស់ហើយ ហើយ១០ម៉ែត្រ និង៣០ម៉ែត្រ វាខុសគ្នាឆ្ងាយណាស់។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមនិយាយឲ្យជាក់លាក់។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំនិយាយថា ប្រហែលជាអាចនឹងមានន័យថា ៣០ម៉ែត្រ។ សំណួរគឺមិនផ្អែកទៅលើចម្ងាយទេ គឺផ្អែកទៅលើថាតើសាក្សី ហើយនិងមិត្តរបស់គាត់ស្ថិតនៅជិតកន្លែងនោះដែលឃាតករមិនអាចមើលគាត់ឃើញ។ តើគាត់ពួនយ៉ាងម៉េច ឬក៏គាត់លាក់ខ្លួនយ៉ាងម៉េចបាទ?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** បាទ កាលនោះដែលខ្ញុំទៅលបមើលនោះ ខ្ញុំពួនណា ខ្ញុំលបមើលនៅកៀនគល់ត្នោត។ អាមួយដើមអំពិល អាមួយដើមត្នោត កៀនវត្តលោកឃ្មួន អាទួលវត្តលោកឃ្មួននោះ ចម្ងាយប្រហែល៣០ម៉ែត្រទេ។ ស៊ង់ ក៏មួយចំហៀងទៅ ខ្ញុំក៏មួយចំហៀងទៅ លោភ័យចំប្រប់ ហើយឲ្យខ្ញុំប្រកែកថាម៉េចទៀត និយាយថាម៉េចទៀត វាប៉ុណ្ណោះឯង។ ឃើញច្បាស់ហ្នឹងភ្នែកហើយ សុទ្ធតែពួន ក្បាលលូនណាទៅលបមើលគេ មិនមែនដើរណ៎ា ង៉ោះៗទៅនេះឯណា សុទ្ធតែលប ពាក្យលបលូន ដូចយើងក្បាលយុទ្ធសាស្ត្រអីចេះឯង។ វាច្បាស់ប៉ុនខ្ញុំ បានខ្ញុំនិយាយ។

[១៤:១៩:៥៣]

**ស៖** តើមានរណ្តៅតាមបាតជាប្រឡាយនៅស្របនឹងរបងវត្តទេ ដែលលោកអាចប្រើជាវិធីដើម្បីចូលឲ្យជិតទៅកន្លែងគេសម្លាប់នោះឬទេ?

**ឆ៖** ខ្ញុំមិនបានចូលទៅកិបទេ ខ្ញុំនៅចម្ងាយប្រហែលជា៣០ម៉ែត្រ ប៉ុន្តែតាមរបងប្រឡាយមួយតាមរបងនោះ គឺប្រឡាយជ្រៅដែរ ហើយមានអណ្តូងទៀត មានអណ្តូងវាប្រហែលជា៥ម៉ែត្របួនជ្រុងចំកណ្តាលប្រឡាយនោះ វើដាក់នោះឯងផង។

**ស៖** ដូច្នេះ ទាក់ទងទៅនឹងអ្វីដែលកើតឡើងនៅវត្តខ្សាច់នោះ តើលោកអាចជម្រាបតុលាការបានទេ តើការសម្លាប់ហ្នឹងនៅកន្លែងណា? តើប្រឡាយហ្នឹងវាស្ថិតនៅកន្លែងណា? វានៅចំពាក់កណ្តាលឬក៏នៅកន្លែងខាងខ្លោងទ្វារ? តើនៅចម្ងាយប៉ុនណាពីកន្លែងសម្លាប់នោះ ហើយនិងនៅទិសខាងណា?

**ឆ៖** បាទ នៅទិសខាងកើត។ ខាងកើតរបងវត្ត។ ខាងកើតរបងវត្ត ដូចជារបងអែបកិប

ប្រឡាយក៏អែបកិបគ្នា ៣ម៉ែត្រពីគ្នា ពីរបង ប្រឡាយនោះ។ បាទ។

**ស៖** ដូច្នេះ ពីកន្លែងដែលលោកពួននោះ ដែលថានៅក្រោយដើមត្នោតនោះ តើលោកអាចមើលឃើញច្បាស់ពីកន្លែងសម្លាប់មនុស្សទេ? តើលោកអាចមើលឃើញអ្នកសម្លាប់មនុស្ស ហើយនិងជនរងគ្រោះដែលគេសម្លាប់នោះទេ? ហើយកន្លែងនោះ គេមានអុចភ្លើងអីបំភ្លឺដែរឬទេ?

**ឆ៖** មាន ពន្លឺភ្លើងមាន ម៉ាំងសុង គេ។ ម៉ាំងសុង កាលនោះ ប្រើម៉ាំងសុង។ មានពន្លឺភ្លើង ហើយចម្ងាយប្រហែលជា៣០ម៉ែត្រ ខ្ញុំមើលច្បាស់ណាស់។ ខ្ញុំមើលឃើញច្បាស់នឹងភ្នែក ហើយខ្ញុំភ័យពេលនោះ ខ្ញុំរន្ធត់ខ្លាំង ខ្ញុំក៏នាំគ្នា ម៉ាសន្នុះអ៊ីចឹងទៅ ខ្ញុំក៏នាំគ្នារត់មកផ្ទះវិញ។ ដកខ្លួន លូនក្រាប វារតាមដុបតាមព្រៃ រត់មកផ្ទះវិញ។

**ស៖** ហើយតើលោកអាចស្តាប់ឮដែរឬទេ ពីកន្លែងដែលលោកពួននោះ តើឃាតករនោះ គេនិយាយពាក្យអ្វីខ្លះ? តើស្តាប់ឮសម្រែកយំ ឬក៏សម្រែករបស់ជនរងគ្រោះទេ?

[១៤:២៣:២៥]

**ឆ៖** បាទ ឮសូរស្រែក ឮសូរយំនោះឯង បានជាខ្ញុំទៅលបមើល។ បើមិនឮសូរសម្រែក ខ្ញុំក៏មិនដឹងថាគេធ្វើឃាត។ ឮសូរសម្រែកហើយ បានខ្ញុំផ្អើលពីផ្ទះខ្ញុំ បានរត់លូន ពួន លប ក្បាលលូនលបមើលអ្នកដែលឃាតនោះ វាដែលសម្លាប់នោះ។ បានឃើញ។

**ស៖** តើឃាតករនោះបានសួរទៅជនរងគ្រោះទេ មុននឹងគេសម្លាប់ ឬក៏គេនិយាយអ្វីទៅជនរងគ្រោះទេ?

**ឆ៖** គេសួរតែមុនដំបូងទេ។ គេសួរ ដែលឮសម្រែកដែលសួរ សំឡេងដែលសួរ " ណ៎ា អាយួនក្បាលត្រី អាយួន--" អត់មានថា វៀតណាមទេ ថា យួន តែម្តង។ បានគេថា ឮសូរតែឈ្មោះអ៊ីចុះឯង ក៏គេដាក់ គេនាំបណ្តើរម្តងមួយមក គេដាក់ភូស។ អ្នកវ៉ៃផ្សេង អ្នកគេបណ្តើរមកផ្សេង។ ខ្ញុំឃើញច្បាស់ហើយ ចម្ងាយ៣០ម៉ែត្រណ៎ា។ អស់លោកមិនមែនឆ្ងាយប៉ុន្មាន មើលច្បាស់ណាស់។ ព្រោះវាមិនទាន់យប់ងងឹតឯណា។

**ស៖** តើឃាតករហ្នឹងគ្រាន់តែនិយាយថា អ្នកឯងយួន ឬក៏តែប៉ុណ្ណឹង ឬក៏គេសួរសំណួរ ឬក៏ប្រើពាក្យអ្វីទៀតទេតាមដែលលោកស្តាប់ឮ?

**ឆ៖** គ្មានសួរអីច្រើនទេ គេសួរតែប៉ុន្មានម៉ាត់តែប៉ុណ្ណោះឯង ក៏គេដាក់។ ឮតែ ភីសភូស អូយ! – ភីសភូស អូយ! ហើយក៏ញាក់ដូចកង្កែប អាញាក់ភ័យ លបមើលគេហ្នឹង។ ដំអក់ចាំតែមើលទាល់តែ

គេវៃរួចទៅ ដោះខ្លួនប្រូច ទៅផ្ទះប៉ុណ្ណោះឯង។

**ស៖** ដោយហេតុតែលោកភ័យញ័រ ដោយសារលោកមានការភ័យខ្លាច ហើយលោកអាចនៅប្រឹងមានកម្លាំងពួនមើលតទៅទៀត បាទ ហើយក៏មិនសម្រេចចិត្តដើរចេញទេ លុះត្រាតែមើលចប់សព្វគ្រប់បានចាកចេញពីកន្លែងនោះ។ តើអ៊ីចឹងទេ?

**ឆ៖** ទាល់តែគេស្ងាត់វៃ មើលទៅស្ងាត់ហើយ ក៏ក្បាលលូនដកខ្លួនរត់មកផ្ទះវិញ មកកន្លែងការដ្ឋានវិញ កន្លែងសហគមន៍វិញ សហករណ៍។ រត់មកកន្លែងសហករណ៍វិញ។ ញ័ររណ្ដំ មកដល់ដេកមិនលក់វាល់ៗព្រឹក ដេកមិនលក់ទេ វាភ័យ វានឹកឃើញភ័យ ព្រោះស្លុតចិត្ត រន្ធត់ខ្លាំង។

**ស៖** តើលោកនៅចងចាំថាបានឃើញថា មនុស្សទាំងអស់ដែលគេយកទៅកន្លែងសម្លាប់នោះគេសម្លាប់ទាំងអស់ ឬក៏អាចឃើញម្នាក់ ឬក៏ពីរបីនាក់ក្នុងចំណោមទាំអស់នោះត្រូវបានគេបំបែកចេញពីក្រុមនោះ ហើយគេទុកឲ្យរស់ជីវិតដែរឬទេ?

[១៤:២៧:២០]

**ឆ៖** បាទ មិនឃើញទេស្រាប់តែបាត់អស់ ទ្រឹងស្ងាត់តែប៉ុណ្ណោះឯង ឃើញមានរំដោះទៅឯណាទេ បញ្ចេញយកទៅណាទេ អត់ឃើញ មិនដឹងអារឿងទាំងនោះ។ ស្រាប់តែដល់ព្រឹកឡើងដើរទៅយកការណ៍ទៀត ដើរទៅស៊ើបមើលទៀត។ ទៅមើលអស់រលីង គ្មាននៅសល់ម្នាក់ទេ។ ទ្វារហោត្រៃក៏ចំហផ្អុងទាំងអស់ បើកចោល។ កាលមុនពេញ មើលណែន ខ្លះឃុំទៅ ខ្លះបក់ដៃតាមបង្អួច មិនដឹងនិយាយថាម៉េច ឮស្រែករំពងពីក្នុងហោត្រៃ។ ស្រាប់តែដល់យប់បន្តិច ឮសូរស្រែកអឺ បានទៅលបមើលឃើញ។ នេះអ៊ីចេះណ៎ា អស់លោក។

**ប្រធានអង្គជំនុំ៖**

សាក្សីចាំស្ដាប់សំណួរឲ្យបាន យើងបានរំឭកច្រើនហើយ ថាលោកឆ្លើយចាំបាច់តបទៅនឹងសំណួរបានហើយ ជៀសវាងនិយាយប្រាជ្ញព្រោកដដែលៗហ្នឹងវាខាតពេល ហើយឃើញលោកវាហត់។ យើងបានប្រាប់ហើយព្រឹកមិញថា លោកត្រៀមខ្លួនសម្រាប់ឆ្លើយតបទៅនឹងសំណួរដ៏ច្រើនលើសលុបនៅទីនេះក្នុងរយៈពេលដែលលោកផ្ដល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះនេះទៅ។

[១៤:២៨:៤៦]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** នៅពេលដែលលោកទៅមើលកន្លែងគេសម្លាប់មនុស្សនោះៗ តើលោកបានឮជនជាតិរង

គ្រោះណាម្នាក់និយាយប្រាប់អ្នកសម្លាប់នោះ ថាខ្លួនជាចិនទេ មិនមែនជាវៀតណាម មិនមែនជាយួនទេ? តើលោកបានឮអីចឹងទេ?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** ខ្ញុំមិនបានឮដឹងទេ ឮគេថាអីចុះទេ អត់ទេ ខ្ញុំមិនឮទេ ខ្ញុំដែលៗខ្ញុំដឹងគឺខ្ញុំ ឮសួរថា "យួនៗ" ប៉ុណ្ណោះឯង តែចំពោះចិនឯណា ក៏ខ្ញុំមិនឮនិយាយ។

**ស៖** ផ្អែកតាមអ្វីដែលលោកបានដឹង បន្ទាប់ពីការសម្លាប់នៅយប់នោះ នៅវត្តខ្សាច់នោះ តើនៅក្នុងភូមិ នៅក្នុងឃុំរបស់លោកជីក្រែងនោះ តើនៅមានប្រជាជនជនជាតិវៀតណាម ឬក៏អ្នកជនជាតិវៀតណាមនៅទីនោះ ក៏បាត់ទាំងអស់ពីកន្លែងភូមិឃុំនោះ?

**ឆ៖** បាទ វាបាត់អត់ឃើញមានមកវិញទេ ម្នាក់ៗទេ គឺបាត់ទាំងអស់នោះឯង។ ស្លាប់ សម្លាប់ចោលទាំងអស់នោះឯង អត់មានរូបណាមួយរស់បានមកវិញទេ។ ឈ្មោះដែលខ្ញុំបាទបានស្គាល់នៅក្នុងស្រុក នៅភូមិនោះ ដែលអ្នកគេចាប់យកទៅសម្លាប់នោះ វាអត់ឃើញមានមកវិញ។ វាស្លាប់អស់នៅអន្លង់នោះឯងទាំងអស់។

**ស៖** តើមានន័យថាកុមារ ទារកក៏គេសម្លាប់ដែរ។ តើលោកបានឃើញកុមារតូចៗហើយនិងទារកក៏គេសម្លាប់ផងដែរ ហើយក្នុងករណីដែលលោកបានឃើញ តើគេសម្លាប់ទារក និងកុមារតូចៗដោយរបៀបណា?

**ឆ៖** បាទ ខ្ញុំបាទឃើញ ខ្ញុំបាទរាយការណ៍។ គឺកូនង៉ាក្មេងតូចគេចាប់ជើងទាំងពីរបាន គេវ៉ៃនឹងគេបោកនឹងដើមដូង។ គេវ៉ៃផាំង គេបោះព្រួសទៅលើ ដែលខ្មោចដែលសម្លាប់រួចហើយ។ ខ្ញុំបានឃើញបោកនឹងគល់ដូង ចាប់ជើងពីរបោកគល់ដូង។

[១៤:៣១:៥៩]

**ស៖** ចុះកុមាររាងធំបន្តិច តើគេសម្លាប់ដោយប្រើដំបងឫស្សី ឬក៏គេសម្លាប់អ្នកទាំងអស់នោះគឺចាប់ជើងបោកទៅនឹង -- បោកក្បាលទៅនឹងគល់ដូង?

**ឆ៖** កុមារដែលរាងទ្រើស គេវ៉ៃនឹងដំបងទេ។ បើកូនង៉ារដែរនៅទើបតែចេះដើរតេះតោះ តិបតុបៗនោះ គេចាប់បោក គេចាប់ជើងបោកនឹងគល់ដូង។ តែដែលកុមារនៅតូចៗអាយុប្រាំឆ្នាំ ប្រាំមួយឆ្នាំគឺវ៉ៃនឹងដំបង ប្រាំមួយឆ្នាំ ប្រាំពីរឆ្នាំនេះឯង។ គេវ៉ៃនឹងដំបងគល់ឫស្សី។

**ស៖** តើលោកធ្លាប់បានឮនៅក្នុងភូមិនោះថាមានយោធា ឬក៏កម្មាភិបាលខ្មែរក្រហម ឬក៏សមា-

ជិកកងចល័តនិយាយថា កុមារទាំងអស់នោះ ហើយនិងទារកទាំងអស់នោះ គឺសុទ្ធតែជាកុមារ ជាទារក ដែលអាចនឹងបង្កការគំរាមកំហែងដល់អាជ្ញាធររបស់ពួកគេទេ?

**ឆ៖** បាទ រឿងត្រង់នោះ ខ្ញុំមិនដឹងដែរ។ ខ្ញុំមិនដឹងដែរ រឿងត្រង់នោះ ខ្ញុំមិនដឹងដែរ។

**ស៖** នៅពេលសម័យនោះដែលលោកបានឃើញនោះ ថាតើប្រធានភូមិៗនោះឈ្មោះអ្វី? បាទ តើលោកចាំឈ្មោះគាត់ទេ?

**ឆ៖** កាលពីសម័យនោះ ខ្ញុំស្គាល់ឈ្មោះប្រធានភូមិដែរ។ ប្រធានភូមិឈ្មោះ ដឹងៗៗ – កណ្ដឹងៗ បាទ។ ស្លាប់បាត់ហើយ កណ្ដឹង នោះសព្វថ្ងៃនោះ។

[១៤:៣៤:២៥]

**ស៖** តើមានកម្មាភិបាលម្នាក់ឈ្មោះ សាយ ឬ សយ នៅក្នុងភូមិយាង ក្នុងឃុំដដែលនោះទេ? មានឈ្មោះប្រធានភូមិមួយទៀតនុំងទេ?

**ឆ៖** កាលពីសម័យនោះមានឈ្មោះ សយ មួយអនុប្រធាន, ឈ្មោះ ដឹង គេប្រធាន។ មាន ប្រធាន អនុប្រធានសមាជិកគេកាលសម័យនោះ ប៉ុន្តែស្លាប់អស់ហើយអ្នកទាំងនោះសព្វថ្ងៃនេះ។ ស្លាប់ អស់ហើយ។

**ស៖** តើលោកធ្លាប់ឮពី ដឹង ឬក៏ សយ និយាយពីអ្វីទាក់ទងទៅនឹងការណែនាំដែលពួកគេបាន ទទួលក្នុងការប្រមូលជនជាតិវៀតណាម ដើម្បីយកទៅដាក់វត្តខ្សាច់នោះដែរទេ?

**ឆ៖** គេ -- ខ្ញុំ -- ព្រោះគេប្រធានភូមិ ខ្ញុំមិនសូវដឹងច្បាស់ដែរ ប៉ុន្តែឮអ្នកស្រុកគេនិយាយថាគេ និយាយថារអ៊ីដូចគ្នាហ្នឹងឯង។ រត់មិតទាំងអស់គ្នាហ្នឹងឯង អ្នកនៅស្រុកភូមិ គេដឹងគ្រប់តែគ្នាហ្នឹងឯង។ តែចំណែកខ្ញុំ វាអាល័យតែគេប្រើទៅណេះទៅណោះផង ក៏មិនសូវបានអារឿងតាមដានអារឿងអ៊ីចុះ ដែរ។ ហើយម្យ៉ាងទៀត ដឹងតែរឿងទៅវ៉ៃ វ៉ៃមែនហ្នឹង ឃើញយកទៅសម្លាប់ ឃើញ បាទ។

**ស៖** លោកបានរៀបរាប់ពីរបៀបដែលគេសម្លាប់មនុស្ស ហើយលោកនិយាយច្បាស់អំពីដំបង ឫស្សី ដើម្បីគេប្រើសម្លាប់ជនរងគ្រោះចាស់ៗ ហើយនិងកុមារធំៗ ដែលគេវ៉ៃនឹងដំបង។ ហើយថាតើ លោកបានឃើញហេតុការណ៍ដែលថាគេវះពោះអ្នករងគ្រោះណាមួយដើម្បីយកប្រមាត់ដែរឬទេ?

**ឆ៖** បាទ ពួកចៅយាយម៉ា នោះគេពុះយកប្រមាត់ –ចាន់ថា គេពុះយកប្រមាត់– ស្រីក្រមុំ នោះ។ គេពុះយកប្រមាត់មែនហ្នឹងឯង។ ឃើញប្រមាត់ដាក់ពាក់ព្យួរនៅនឹងជញ្ជាំងផាងដួង មួយចង្កោម។ ប្រមាត់ច្រើនណ៎ា ឃើញយក យកទៅពុះនោះ ប្រមាត់ច្រើនណាស់ មិនដឹងជាប៉ុន្មាននាក់ទៅ បានជា

មួយចង្កោមហ្នឹង។ យកតែស្រីក្រមុំៗទេ ប្រមាត់ហ្នឹង។

**ស៖** ហើយនៅពេលល្ងាចនៃការសម្លាប់នោះ តើខ្លួនលោកផ្ទាល់បានឃើញអ្នកណាម្នាក់វះយកប្រមាត់ចេញពីជនរងគ្រោះ គេវះពោះ ឬក៏វះដូចម្ដេច? ឬក៏គាត់ -- ឬក៏លោកបានឃើញប្រមាត់ហ្នឹងពេលព្រឹកឡើងដែលទៅមើលកន្លែងហ្នឹងឡើងវិញ ឬក៏បានឃើញគេវះកាលពីយប់នោះដែរ?

**ឆ៖** ខ្ញុំឃើញតែប្រមាត់អាដែលគេពាក់ចោលនៅជញ្ជាំង។ តែដែលគេកំពុងវះ ខ្ញុំអត់បានឃើញទេ។ គេវះស្ងាត់ៗតែគ្នាគេទេ។ វះនោះ វះមិនមែនតែម្នាក់ទេ វះច្រើនណាស់ ប្រមាត់ឡើងមួយត្រណោតមួយចង្កោម ដោតដែកលួសទៀត។ ពាក់នឹងជញ្ជាំងហ្នឹង។

[១៤:៣៩:១៧]

**ស៖** ខ្ញុំសួរលោកថា តើលោកបានឃើញប្រមាត់ដែលគេចងព្យួរនោះ នៅពេលល្ងាចបន្ទាប់ពីការសម្លាប់ហ្នឹង ពេលដែលលោកឃើញគេចងព្យួរនឹងជញ្ជាំងផាងដូងនៅថ្ងៃបន្ទាប់ ព្រឹកថ្ងៃបន្ទាប់ដែលលោកបានត្រឡប់ទៅមើលកន្លែងកើតហេតុនោះម្ដងទៀត?

**ឆ៖** បាទបានឃើញ ដែលត្រឡប់ក្រោយគេ ដែលគេសំលេះរួចហើយ ខ្ញុំថ្ងៃក្រោយនោះ ខ្ញុំដើរទៅទៀត បានឃើញប្រមាត់នោះ។

**ស៖** តើលោកបានដឹងថា ហេតុអីបានជាគេ ឃាតករនោះវះយកប្រមាត់ ហើយយកមកចងព្យួរ តើលោកដឹងថាមូលហេតុអីបានគេយកទេ? តើអ្វីជានិមិត្តរូបនៃការវះយកប្រមាត់ហ្នឹង គឺគេយកមកដើម្បីអី? គោលដៅនោះ គោលបំណងអី?

**ឆ៖** ខ្ញុំមិនដឹងដែរ មិនដឹងជាគេប្រើការរបៀបណា ខ្ញុំអត់ដឹងទេ។ តែចំពោះដែលខ្ញុំឃើញ គឺខ្ញុំឃើញ ប៉ុន្តែដែលគេយកមកប្រើការអ្វី ខ្ញុំអត់ដឹងទេ។

[១៤:៤០:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:០១ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សីខ្ញុំមិនមានពេលវែងទៀតទេ ហើយខ្ញុំមានសំណួរមួយចំនួនទាក់ទងទៅនឹងកន្លែងសម្លាប់មនុស្ស ហើយលោកនិយាយថាលោកបានឃើញគេសម្លាប់ជនជាតិវៀតណាម។ តើលោកអាចជម្រាបតុលាការ តើឃាតករប៉ុន្មាននាក់នៅកន្លែងសម្លាប់មនុស្សនោះដែលរាប់ទាំងអ្នកដែលជូនជនរងគ្រោះទៅផងដែរ ហើយរួមទាំងអ្នកដែលសម្លាប់ផ្ទាល់នោះផង តើមានគ្នាប៉ុន្មាននាក់?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** បាទ ខ្ញុំបាទឃើញគ្នាគេចំនួនបីនាក់ ពីរនាក់អ្នកបណ្តើរ ម្នាក់អ្នកចាំវ៉ៃ។ ពីរនាក់បណ្តើរម្នាក់អ្នកចាំវ៉ៃ។

**ស៖** អ៊ីចឹងគឺថាមានតែមនុស្សបីនាក់ជាសរុបទេ។ អ៊ីចឹង គឺថាម្តងៗ គឺថាមានក្រុមប៉ុន្មាននាក់ដែលថា ឬក៏មានតែមួយក្រុមគ្នាបីនាក់ ឬក៏ថាមានអ្នកបណ្តើរពីរនាក់យកទៅឲ្យអ្នកសម្លាប់នៅកន្លែងនោះមានគ្នាម្នាក់ ឬក៏យ៉ាងម៉េច? សូមលោករៀបរាប់ឲ្យពិស្តារបន្តិច។

**ឆ៖** បាទ ដែលខ្ញុំបានឃើញៗបណ្តើរ អ្នកដែលបណ្តើរនោះ ចងក្រពាត់ស្លាបសេក គេដើរបណ្តើរឆ្វេងស្តាំ តែអ្នកវ៉ៃ គេនៅចាំវ៉ៃអាត្រង់កន្លែងមាត់ទ្វារដែលគេបៀតអន្លង់នោះ គេចាំវ៉ៃត្រង់នោះឯង គេចាំវ៉ៃតែម្នាក់នោះឯង។ អាអ្នកបណ្តើរគេយកទៅដល់ភ្លាមគេភ្ជួសទៅ ក៏មានអីទៀត ក៏គេទៅវិញទៅ

គេយកមួយទៀតមក បណ្តើរមកទៀត ក៏បាំងទៀត អាអ្នកបណ្តើរផ្សេង អាអ្នកវ៉ៃផ្សេងកាលនោះ ខ្ញុំឃើញច្បាស់ហើយ។

[១៥:០៣:៥២]

**ស៖** ដូច្នេះនៅពេលម្តងៗ គឺឃាតករតែម្នាក់ទេ ដែលសម្លាប់ជនរងគ្រោះ ឬក៏គេផ្លាស់វេនគ្នាដែរឬទេ?

**ឆ៖** បាទ គេផ្លាស់គ្នាៗ អ្នកដែលសម្លាប់នោះគេផ្លាស់គ្នាម្តងម្នាក់ក្នុងបីនាក់នោះ។ អ្នកទាំងបីនោះគេផ្លាស់ប្តូរគ្នា។

**ស៖** ផ្អែកលើអ្វីដែលលោកបានឃើញ តើអ្នកទាំងនោះជាយោធា ឬក៏ជាពួកឈ្លប?

**ឆ៖** ពួកនោះគឺពួកមិនមែនអ្នកយោធាទេ ពួកនោះពួកឈ្លបគេនៅកាន់ក្តាប់នៅហ្នឹងកន្លែងនោះឯង។ ខ្ញុំស្គាល់ទាំងមនុស្សអ្នកវ៉ៃទៅទៀត។ មនុស្សនោះឈ្មោះ ឃត, មនុស្សមួយទៀត ម្នាក់ទៀតនោះឈ្មោះ មុយ ប៉ុន្តែស្លាប់អស់ហើយ បច្ចុប្បន្ននេះស្លាប់អស់ហើយ។

**ស៖** ការបកប្រែភាសាបារាំងមិនសូវច្បាស់ទេ។ ហើយគាត់ ពួកនោះមិនមែនជាយោធាទេ គឺថាជាឈ្លប គឺថា មាន ឃត ហើយនិងមាន មុយ អ៊ីចឹងទេ? សូមលោកបញ្ជាក់ម្តងទៀត។ ក្នុងករណីដែលអ្នកទាំងអស់នោះ យោធាមកពីតំបន់ ឬក៏ពួកគេជាឈ្លប? ខ្ញុំគិតថា -- លោកបានប្រាប់ថា អ្នកដែលបណ្តើរជនជាតិវៀតណាមនោះ គឺមានកាន់អាវុធ។ តើលោកអាចដឹងដែរឬទេ ថាតើពួកឃាតករហ្នឹងស្ថិតនៅក្នុងកង ឬក៏ក្រុមណាដែរ ជាកងយោធានោះ?

**ឆ៖** បាទ នៅក្នុងកន្លែងវត្តនោះ នៅតាមកងយោធាគេផង ច្រឡូកច្រឡំគ្នាហ្នឹងឯង កន្លែងនោះច្រឡូកច្រឡំគ្នា កងឈ្លបផង កងយោធាផង។

[១៥:០៦:៥០]

**ស៖** ហើយពួកឃាតករនោះ តើពួកគេជាយោធា ឬក៏ជាកងឈ្លប ឬក៏អ្នកទាំងអស់នោះ ស្ថិតនៅក្នុងក្រុមដាច់ពីគ្នា ឬក៏នៅក្រុមតែមួយជាមួយគ្នា?

**ឆ៖** បាទ នៅកង ក្រុមតែមួយជាមួយគ្នាហ្នឹងឯង នៅជាមួយគ្នានោះឯង។

**ស៖** តើពួកយោធានោះ ឬក៏ពួកឃាតករនោះ អាយុពួកគាត់នោះ ប្រហែលប៉ុន្មានដែរតាមដែលលោកសង្កេតមើល ស្មានរបស់លោកនោះ?

**ឆ៖** តាមសង្កេតមើលទៅ មិត្តមុយនោះ មិត្តឃត នោះអាយុប្រហែលជា បើដល់មកពេល

ឥឡូវនេះ ប្រហែលចូល ៦០ហើយ ៥០-៦០ -- ៥០លើស ៦៨, ៦៩ ហើយ តាមខ្ញុំស្មានមើល មិនខុសទេ។ ប៉ុន្តែស្លាប់អស់ហើយ ពួកអ្នកឃាតករ អ្នកទាំងនោះ ស្លាប់អស់ហើយ។

**ស៖** តើ យត និង មុយ ជាឈ្មោះពីរនាក់ដែលលោកបញ្ជាក់ប្រាប់តុលាការ តើពួកគាត់ស្ថិតនៅក្នុងកងមួយ ឈ្លបរបស់ឃុំ ឬក៏របស់ស្រុក?

**ឆ៖** ខ្ញុំដូចជាមិនចាំផង មិនដឹងជាខាងស្រុក មិនដឹងជាខាងឃុំ។ អារឿងទាំងនោះ ខ្ញុំអត់ដឹងដែរ។ កន្លែងចំណុចណាដែលខ្ញុំមិនដឹង គឺខ្ញុំឆ្លើយថាមិនដឹង មិនច្បាស់ ខ្ញុំក៏មិនហ៊ានឆ្លើយដែរ។

[១៥:០៩:១៥]

**ស៖** មិនអីទេ។ ឥឡូវនេះ ពាក់ព័ន្ធទៅនឹងចំនួនជនរងគ្រោះ។ ខ្ញុំ បាទ ធ្វើឲ្យមានការបែងចែក គឺថា ចំនួនមនុស្សដែលត្រូវបានគេសម្លាប់នៅកន្លែងមួយ ហើយនិងចំនួនជនរងគ្រោះរួមដែលស្ថិតនៅក្នុងហោត្រៃនោះ។ អ៊ីចឹងខ្ញុំសួរសំណួរទី១ នៅក្នុងពេលដែលលោកបានទៅមើលការសម្លាប់នោះ តើមានមនុស្សប៉ុន្មាននាក់ដែលគេយកទៅសម្លាប់កន្លែងនោះ តើមានប្រហែលប៉ុន្មាននាក់ដែលជិតនឹងវត្ត នៅជិតរបងវត្តនោះណា?

**ឆ៖** បាទៗ ខ្ញុំបាទឃើញក្រែល ច្រើន ប៉ុន្តែខ្ញុំមិនបានជារាប់ដឹងចំនួនថាប៉ុនណាមែនទែនទេ តែនៅក្នុងហោត្រៃនោះ ឃើញណែន ពេញទាំងអស់។ ក្នុងហោត្រៃនោះ ចំនួនវាប្រហែល រយៈប្រហែលជា២៥នាក់ ប៉ុណ្ណោះឯង តាមមើលទៅ។ ខ្ញុំស្មានមើល ប្រហែលជា២៥នាក់។

**ស៖** ដូច្នេះ ខ្ញុំមានការភ័ន្តច្រឡំបន្តិចនៅត្រង់នេះ។ អ៊ីចឹងអ្នកទាំង២០នាក់នេះ ដែលលោកបានឃើញគេយកទៅសម្លាប់នោះ ឬក៏២៥នាក់ជាមនុស្សដែលស្ថិតនៅក្នុងហោត្រៃទាំងអស់ហ្នឹង?

**ឆ៖** បាទ ខ្ញុំប៉ាន់ស្មានក្នុងហោត្រៃនោះទេណា ចំនួន២៥នាក់នេះ តែក្រៅពីនោះទៀតនោះ ខ្ញុំមិនដឹងចំនួនប៉ុន្មានទេ ព្រោះវាវគ្គមួយ វគ្គពីរ។ បាទ ខ្ញុំមិនដឹងទេ ទៅមុខទៀតខ្ញុំមិនដឹងទេ ខ្ញុំដឹងតែមួយកន្លែងតែម្តង។

[១៥:១១:២០]

**ស៖** ខ្ញុំនឹងត្រឡប់មកវគ្គទី២ នៅពេលក្រោយទៀត។ នៅពេល ស៊ាន ស៊ង់ គាត់ធ្វើសក្ខីកម្មនៅនេះ គាត់បាននិយាយអំពីចំនួនមនុស្សពី៥០ ទៅ ៦០នាក់ ដែលត្រូវបានគេយកទៅសម្លាប់ ហើយគាត់និយាយពីចំនួនប្រហែលជា៧០នាក់ និង១០០នាក់ អាហ្នឹងនៅក្នុងការបញ្ជាក់ពីមុនរបស់គាត់។ អ៊ីចឹងនៅពេលដែលលោកបានឃើញហេតុការណ៍ហ្នឹងដូចគ្នាជាមួយនឹងគាត់នោះ តើមានអ្វីដែលអាចពន្យល់បាន

អំពីភាពខុសគ្នា អំពីការនិយាយអំពីចំនួនមនុស្សដែលលោកបានឃើញនេះ?

**ឆ៖** កាលណោះ ខ្ញុំឃើញ តាមដែលខ្ញុំមិនបានរាប់ចំនួន តាមស្មានថាប្រហែលជារយៈ២៥នាក់ទេ តែអាដល់លើកក្រោយទៀត គេដឹកយកមកសម្លាប់ទៀត ប៉ុន្តែក្នុងអន្លង់ស្រះតែមួយដដែល។ ស្រះវាមានពីរ អាមួយវាស្រះអណ្តូង អាមួយស្រះធំ ដែលគេដឹកយកមកក្រោយទៀត ខ្ញុំមិនបានបៀតបត់ទេ ខ្ញុំមិនបានឃើញទេ ប៉ុន្តែគេយកមកសម្លាប់នៅហ្នឹងទាំងអស់ហ្នឹងឯង ព្រោះវាឡើងពេញស្រះនោះ វាកប់ទាំងមិនជិតផង នៅលើគោក មាត់ស្រះក៏មាន វាហៀរដល់មាត់ស្រះក៏មាន។ តាមចំនួនរយៈនោះច្រើនណាស់ ចូលរយដូចគេនិយាយអ៊ីចឹង មិនមែនទេ។ ប៉ុន្តែអាដែលខ្ញុំឃើញជាក់ស្តែងហ្នឹងភ្នែក អាដែលព្យួរស្រែកនោះ ខ្ញុំឃើញនៅក្នុងហោត្រៃ ចំនួនប្រហែលជា២៥នាក់ទេ។ នោះបានទៅលបមើល។

**ស៖** លោកនិយាយអំពីស្រះ តើស្រះហ្នឹងស្ថិតនៅបរិវេណវត្តខ្សាច់ ឬក៏នៅក្រៅបរិវេណវត្តខ្សាច់នោះ?

**ឆ៖** បាទ នៅក្រៅបរិវេណវត្តខ្សាច់។ អណ្តូងក៏នៅក្រៅបរិវេណវត្តខ្សាច់ដែរ ប៉ុន្តែកៀនរបងកៀនរបងវត្ត។

[១៥:១៤:០២]

**ស៖** លោកបាននិយាយអំពីហេតុការណ៍ពីរ ដូច្នេះ តើហេតុការណ៍មួយនៃការសម្លាប់ដែលលោកបានឃើញ គឺជាលើកដំបូងវគ្គទី១ ដែលការសម្លាប់នោះកើតឡើងដំបូង ឬក៏ តើហេតុការណ៍ផ្សេងទៀត ដែលលោកនិយាយថាអាចនឹងមានមនុស្សដល់រយនាក់ត្រូវបានគេសម្លាប់នៅកន្លែងហ្នឹងដែរ ក្រោយហ្នឹង ឬក៏មុនហ្នឹង? តើហេតុការណ៍ណាមួយកើតមុន តាមអ្វីដែលលោកអាចចាំបាននោះ?

**ឆ៖** តាមដែលខ្ញុំដឹង មិនបានឃើញ មិនបានឃើញគេវ៉ៃទេណា ប៉ុន្តែឃើញខ្មោចដែលគេដាក់ក្នុងស្រះ ដែលគេវ៉ៃវគ្គមុននោះ ឃើញដែរ។ នោះមិនបានលបមើលគេទេ អាដែលឃើញៗថ្ងៃទេ តែដល់វគ្គក្រោយនេះ ន៎ែ! វ៉ៃមីចាន់ថា និងតាឃុត នោះអានោះ ខ្ញុំឃើញនឹងភ្នែក លបមើលឃើញខ្លួនឯង ពីរនាក់ អាស៊ង់ នោះឯង។ ពីរនាក់ ស៊ង់ ស៊ាន នោះឯង -- ស៊ាន ស៊ង់។

**ស៖** បាទ ឥឡូវនេះ ខ្ញុំត្រឡប់មកហេតុការណ៍ទី២ ដែលលោកបានឃើញ លោកនិយាយថាក្រោយមកនោះ លោកបានទៅកន្លែងសម្លាប់មនុស្ស បន្ទាប់ពីយប់ដែលសម្លាប់។ ហេតុអ្វីក៏លោកទៅមើលកន្លែងនោះឡើងវិញម្តងទៀត តើមានលោកមានគោលបំណងអ្វី ហើយតើគេអនុញ្ញាតឲ្យទៅ ឬក៏ទៅដូចរបៀបម៉េច? ដោយរបៀបណា?

**ឆ៖** បាទ ពួកខ្ញុំចូលទៅកន្លែងនោះ ព្រោះវានៅកន្លែងមិនមែនជិតមន្ទីរគេទេ ខ្ញុំនៅក្រៅរបងទេ។ ខ្ញុំដើរ ហេតុផល ដើរលេងទៅ ស៊ើបមើល ដល់ទៅមើលឃើញមែន អស់ចេញពីហោត្រៃរលីង។ ខ្ញុំស្មានតែវ៉ៃអ្នកពីណាទៀត អត់ដឹងថា -- ដឹងថាវ៉ៃអ្នកដែលនៅក្នុងហោត្រៃនេះឯង ដែលដឹកពីថ្ងៃអ៊ីចឹងទៅ ពីភ្លឺអ៊ីចេះទៅ យប់ឡើងគេវ៉ៃ។ ព្រឹកឡើងទៅឃើញទៀត ឃើញទាំងខ្មោចនៅតាមមាត់អន្លង់ មាត់ស្រះមាត់អណ្ដូងនោះឯង។ មិនទាំងកប់ជិតផង នៅលើគោក។

[១៥:១៧:០១]

**ស៖** ហើយនៅថ្ងៃបន្ទាប់ ហើយតើលោកបានឃើញពួកយោធានៅក្នុងបរិវេណវត្តដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានឃើញ ឃើញគេអង្គុយនៅក្នុងមន្ទីរគេ ក្នុងវត្តនោះ។ ខោខ្មៅអាវខ្មៅ ឃើញគេចុះទាំងអស់ ប៉ុន្តែខ្ញុំមិនហ៊ានចូលទៅកន្លែងបរិវេណគេ។ បានដើរតែក្រវែលរបងវត្តពីក្រៅ។

**ស៖** អ៊ីចឹង លោកបានឃើញប្រមាត់ដែលគេហាលនៅរបង បាទ ឬក៏នៅលើដើមឈើ។ តើលោកបានឃើញអ្វីខ្លះទៀតនៅកន្លែងដែលគេសម្លាប់មនុស្សនោះ? តើមានស្លាកស្នាមនៃការសម្លាប់ហ្នឹងនៅសេសសល់ដែរឬទេពេលដែលលោកទៅថ្ងៃបន្ទាប់?

**ឆ៖** បាទ ឃើញមាន។ គេដាក់ព្យួរប្រមាត់មនុស្សនោះ គេដាក់ព្យួរនឹងជញ្ជាំងផាងដូងគេ នៅមន្ទីរគេនោះ បាទ។ ខ្ញុំបានឃើញ ឃើញទាំងដំបង ឃើញទាំងគល់ឫស្សី គល់ល្ងៀង ដំបងទៀត នៅនោះឯង។

**ស៖** តើលោកបានឃើញសាកសពដែរទេ? ឬស្រះ ឬក៏រណ្ដៅនោះ គេលុបជិតដែរឬទេ?

**ឆ៖** បាទ គេលុបអត់ជិតទេ។ លុបអត់ជិតទេ ឃើញជើង ឃើញដៃ នៅកណ្ដាលវាល។

**ស៖** តើលោកអាចស្គាល់សាកសពរបស់ ចាន់ថា ទេ នៅពេលដែលលោកទៅនោះ? ឬក៏ខ្ញុំមិនយល់ច្បាស់ពីអ្វីដែលលោកបញ្ជាក់ពីខាងដើមនោះ?

[១៥:១៩:៣០]

**ឆ៖** បាទ អារឿងត្រង់នោះ ដែលគេវ៉ៃដាក់អន្លង់ទៅហើយ ខ្ញុំមិនបានទៅអើតនៅអន្លង់ទេ។ ខ្ញុំគ្រាន់តែដើរក្រវែងខាងៗពីចម្ងាយ ខ្ញុំមិនបាននេះ ព្រោះខ្មោចវាច្រើន។

**ស៖** អ៊ីចឹង ខ្ញុំត្រឡប់ទៅចំណុចមួយដែលយើងទុកពីមុន។ គឺថា លោកនិយាយថាប្រហែលជាមនុស្ស១០០នាក់ត្រូវបានគេសម្លាប់។ តើលោកមានអ្វីជាសំអាង ដែលថាអ្នកទាំងអស់នេះត្រូវបានគេសម្លាប់? ថាតើអ្នកទាំងអស់ហ្នឹងជាជនជាតិវៀតណាមដែរឬទេ? ក្នុងករណីដែលថាអ្នកនោះជាជនជាតិ

វៀតណាម តើលោកសំអាងលើអ្វីដែលលោកអាចបញ្ជាក់ថាជាជនជាតិវៀតណាម ជាជនរងគ្រោះនៅពេលនោះ?

**ឆ៖** បាទ ព្រោះខ្ញុំស្គាល់ តាឃុត និងយាយម៉ា និង ចាន់ថា នោះច្បាស់។

**ស៖** បាទ ខ្ញុំត្រឡប់មកសួរសំណួរដែលខ្ញុំបានសួរបានច្បាស់លាស់ ហើយមានការសម្លាប់ពីរលើកនៅវត្តខ្សាច់ ហើយលោកនិយាយថាគឺថាលោកបានឃើញគឺថាបានឃើញជនរងគ្រោះ ២៥នាក់ដែលបានសម្លាប់នៅពេលដែលលោកទៅមើល ហើយមានការសម្លាប់មុនហ្នឹងដែលមានការសម្លាប់មួយផ្សេងទៀត ហើយលោកបានបញ្ជាក់ថា មានស្រះ ហើយនិងអណ្តូង។ លោកនិយាយថា ប្រហែលមានសាកសព១០០ ដែលត្រូវបានគេទម្លាក់ចូលទៅក្នុងស្រះ ហើយនៅក្នុងអណ្តូង។ ដូច្នេះ អ្នកទាំងអស់នេះដែលត្រូវបានគេសម្លាប់ ហើយទម្លាក់ទៅក្នុងស្រះ ឬក៏ក្នុងអណ្តូងនោះ តើអ្នកទាំងនោះជាជនជាតិវៀត-ណាម ឬក៏ជាអ្នកណា?

**ឆ៖** មើលមិនច្បាស់ទេ ត្រង់ទីនោះនោះ មិនដឹងជាជនជាតិវៀតណាមទាំងអស់ មិនដឹងជាជនជាតិខ្មែរផង ជនជាតិអ៊ីស្លាមផង មិនដឹងដែរ លោកច្រឡូកច្រឡំគ្នាច្រើនណាស់ បាទ។ មិនប៉ានចូលទៅជិតគេផង។

**ស៖** កាលពីខាងដើម ខ្ញុំបានយោងទៅរកសាក្សីម្នាក់ដែលថានិយាយពីជនជាតិវៀតណាមដែលមានដើមកំណើតជាតិវៀតណាម ជាសាច់ថ្លៃរបស់គាត់ត្រូវបានគេយកសម្លាប់នៅវត្តខ្សាច់ ហើយលោកនិយាយថាហេតុការណ៍នេះ ជាផ្នែកនៃការសម្លាប់លើកទី១ គឺជាការសម្លាប់ជាក្រុមនៅវត្តខ្សាច់នោះ។ តើខ្ញុំយល់ត្រឹមត្រូវតាមសម្តីនោះទេ? សមាជិកក្រុមគ្រួសារ ឡុង ឃុន ដែលស្ថិតនៅក្នុងក្រុមគ្រួសារចាន់ថា នោះដែរ។

**ឆ៖** វាជាប់ខ្សែបណ្តាញជាប់ ចាន់ថា នោះដែរ ឡុញ ឃុន –ឈ្មោះ ឡុញ ឃុន– វាជាប់រឿងសែស្រឡាយវៀតណាមនៅនោះដែរ មួយខ្សែគ្នាគេនោះឯង សែស្រឡាយគេ។

[១៥:២៣:៥៣]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្ទាឯល៖**

បាទ ខ្ញុំបញ្ចប់ត្រឹមនេះ។ សូមអរគុណលោកសាក្សីដែលបានឆ្លើយនូវសំណួររបស់ខ្ញុំ។

សូមអរគុណលោកប្រធាន បាទ ខ្ញុំបញ្ចប់ការតាំងសំណួររបស់ខ្ញុំនៅត្រឹមនេះបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍។ ខ្ញុំតំណាងឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ។ ខ្ញុំមានសំណួរខ្លីៗមួយចំនួនដើម្បីសួរលោកនៅរសៀលនេះ។ អម្បាញ់មិញនេះ លោកឆ្លើយថា មនុស្សពីរប្រភេទជាអ្នកសម្លាប់ ចាន់ថា មានអ្នកដែលមកពីកងទ័ពដែលយាមនៅវត្តហើយនិងឈ្លប។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

[១៥:២៥:០៣]

**ឆ៖** បាទ ត្រឹមត្រូវ ខ្ញុំឯកភាព ត្រឹមត្រូវ។

**ស៖** តើកងយោធាហ្នឹង នៅប្រចាំការនៅក្នុងវត្តខ្សាច់ហ្នឹងមែនទេ?

**ឆ៖** បាទ គេនៅប្រចាំការនៅវត្តហ្នឹង នៅវត្តខ្សាច់នុ៎ងឯង។

**ស៖** លោកចាំទេ កងយោធានុ៎ងមកប្រចាំការនៅក្នុងភូមិខ្សាច់ហ្នឹង នៅពេលណាដែរ?

**ឆ៖** បាទ ដែលខ្ញុំតាមក្តាប់ជាប់ដែលចងចាំ នៅ វាឆ្នាំចាប់តាំងពី ៧៥ៗ រហូតដល់ ៧៦, ៧៧ ៧៨, ៧៩ បាទ។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ កុំអាលទាន់ឆ្លើយ។ អត់មានការសំឡេងៗជាភាសាខ្មែរ អត់ឮផង។

បាទ អញ្ជើញៗតាំងសំណួរសាជាថ្មី សំណួរចុងក្រោយអម្បាញ់មិញ លោកស្រីមេធាវី។ អត់មានការ -- បាត់សំឡេងជាភាសាខ្មែរ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** សំណួរខ្ញុំចុងក្រោយអម្បាញ់មិញនេះ ខ្ញុំសួរថាតើកងយោធាចូលមកប្រចាំការនៅភូមិខ្សាច់ហ្នឹង ពីពេលណាមក?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** បាទ ចាប់តាំងពីឆ្នាំ៧៥, ៧៦, ៧៧, ៧៨, ៧៩។ ពីឆ្នាំ៧៥ ទៅ ចុងឆ្នាំចិត -- ដើមឆ្នាំ៧៥ អ៎! ចុងឆ្នាំ៧៥។

**ស៖** កងយោធានៅប្រចាំការជាអចិន្ត្រៃយ៍នៅក្នុងភូមិហ្នឹងមែនទេ? លោកនៅចាំទេ?

**ឆ៖** បាទ នៅប្រចាំភូមិ ប្រចាំនៅវត្តនុំងឯង យូរហើយ។

**ស៖** លោកដឹងថា កងយោធាហ្នឹងមកពីណាទេ មកពីថ្នាក់ស្រុក ថ្នាក់តំបន់ ឬថ្នាក់ភូមិភាគ លោកមានទទួលបានព័ត៌មាននេះទេ?

**ឆ៖** ខ្ញុំមិនសូវដឹងដែរ រឿងចំណុចភូមិភាគនិងថ្នាក់ស្រុក មិនដឹងដែរ។ មិនដឹងគេមកពីខាងភូមិភាគ មិនដឹងជាមកខាងស្រុក ឬខាងសង្កាត់ ព្រោះនៅកន្លែងនោះ ខ្ញុំចំណាំបានឈ្មោះអ្នកដែលឈរជើងនៅកន្លែងនោះ មិត្តរី មិត្តសឿន មិត្តលន់ មេធំ បាទ។

[១៥:២៨:៥០]

**ស៖** ពួកគេមានទំនួលខុសត្រូវអ្វីខ្លះ?

**ឆ៖** គេក្តាប់រួមៗ ក្នុងមួយចង្កោមឃុំសង្កាត់ស្រុងហ្នឹង គេក្តាប់រួមនោះឯង។ មួយក្រុមគ្នាគេនោះ គេក្តាប់រួម។

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកនិយាយអំពី ឃត ហើយនិង មុយ ហើយលោកនៅចាំថា ពួកគេបានចូលរួមនៅក្នុងការសម្លាប់មនុស្ស។ តើ ឃត និង មុយ ជាសមាជិកកងយោធា ឬក៏ជាកងឈ្លប?

**ឆ៖** បាទ ជាកងឈ្លបទេ។ ឃត និង មុយ នេះ ជាកងឈ្លបទេ ប្រចាំឃុំនោះឯង។ តែចំពោះគេក្តាប់រួមមេធំគេដែលនៅកន្លែងនោះ មានស្គាល់ឈ្មោះ មិត្តសឿន មួយ មិត្តរី មួយ មិត្តលន់ មួយ។ មិត្តសឿន នេះខេត្តនៅកំពង់ចាម ខាងខេត្តកំពង់ចាម។ មិត្តរី ខ្ញុំអត់ដឹងថានៅខេត្តណាទេ ស្រុកណាទេ ប៉ុន្តែស្គាល់ឈ្មោះ។

**ស៖** ខ្ញុំយល់ត្រឹមត្រូវទេថា លោកស្គាល់ ឃត និង មុយ ដែលជាមនុស្សក្នុងចំណោមអ្នកដែលសម្លាប់ជនជាតិវៀតណាម។ នេះជាចម្លើយដែលលោកបានឆ្លើយអម្បាញ់មិញហ្នឹងមែនទេ?

**ឆ៖** បាទ ខ្ញុំបាទឆ្លើយត្រូវហើយ ដូចពាក្យលោកមានប្រសាសន៍។

**ស៖** ក្រោយមក លោកធ្លាប់ឃើញ ឃត និង មុយ នៅក្នុងភូមិទៀតទេ? គឺក្រោយពីមានការ

សម្លាប់មនុស្សហើយនោះ គឺមុនខែមករា ឆ្នាំ៧៩?

**ឆ៖** ក្រោយមកបានឃើញតែមួយភ្លែតទេ គេកាប់ជ្រូកនៅកំពង់ក្ដី នៅឃុំកំពង់ក្ដី។ ឃើញផុតពីនោះទៅបាត់ មិនដឹង -- ស្លាប់បាត់ទៅហើយ គេយកទៅសម្លាប់ចោលឯណាបាត់ហើយ។ បាត់ឈ្មោះ បាត់សំឡេង។

[១៥:៣១:៥៦]

**ស៖** ក្រោយពីមានការសម្លាប់មនុស្សហើយ លោកមានឮការនិយាយអ្វីពាក់ព័ន្ធទៅនឹងការចូលរួមពាក់ព័ន្ធរបស់ មុត និង ឃុយ *(តាមការបកប្រែ)* ក្នុងការសម្លាប់មនុស្សទេ? ខ្ញុំចង់បានន័យថាក្រោយមកនោះ លោកមានឮអ្នកណានិយាយថាពីរនាក់ហ្នឹងបានចូលរួមក្នុងការសម្លាប់មនុស្សទេ?

**ឆ៖** ទេ ដូចមិនឮពីណា មិនមានឈ្មោះ មុយ ឈ្មោះ ហួត អីទេ។ មានពីណា មានដែលឮខ្ញុំដឹង ដឹងថាឃើញ ដឹងតែឈ្មោះពីរនាក់នោះហើយ។ ម្នាក់ទៀត ខ្ញុំអត់ស្គាល់ទេ មិនដឹងអ្នកស្រុកណាទេ។

**ស៖** ដើម្បីឲ្យច្បាស់ តើនៅយប់នោះលោកស្គាល់អ្នកណាខ្លះទៀតក្រៅពី ឃត និង មុយ ហ្នឹង ដែលជាអ្នកសម្លាប់ជនជាតិវៀតណាមនោះ?

**ឆ៖** ខ្ញុំអត់ដឹងទេ អត់មានទេ ឃើញតែប៉ុណ្ណោះឯង។ ឃើញតែដែលខ្ញុំចាំប៉ុណ្ណោះឯង តែ ឃត និង មុយ ហ្នឹងឯង។ ប៉ុន្តែក្នុងទីវត្តអារាមនោះ ដែលគេក្ដាប់មេធំៗគេមានបីនាក់នោះឯង ដូចខ្ញុំរាយ-ការណ៍ប្រាប់៖ មិត្តសឿន មួយ, មិត្តរី មួយ, មិត្តលន់ មួយ តែប៉ុណ្ណោះឯង។

**ស៖** ចុះហេតុការណ៍មួយទៀត ដែលលោកបានរៀបរាប់មុននេះជូនសហព្រះរាជអាជ្ញា គឺការសម្លាប់មនុស្សជាង១០០នាក់នៅជិតត្រពាំង។ តើលោកដឹងថា ឃាតករដែលសម្លាប់មនុស្សនោះជាអ្នកណាទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ខ្ញុំអត់ដឹង បៀតត្រពាំងឯណា ខ្ញុំអត់ដឹងទេ។ ខ្ញុំដឹងតែកន្លែងស្រះកៀនរបងវត្តខ្សាច់ ហើយនិងរោងកៀនរបងវត្តខ្សាច់តែប៉ុណ្ណោះឯង បើកៀនស្រះ អំ! កៀននេះណានោះ ខ្ញុំអត់ដឹងទេ។ កៀនត្រពាំងឯណានោះ ខ្ញុំអត់ដឹងទេ។

**ស៖** គឺស្រះហ្នឹងហើយ លោកដឹងទេថា អ្នកណាជាអ្នកសម្លាប់មនុស្សនៅជិតស្រះនោះ?

**ឆ៖** ខ្ញុំបាទអត់ដឹងទេ។

[១៥:៣៤:៤៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ដំបូងនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី បាទ ខ្ញុំនឹងសួរខ្លីទេថ្ងៃនេះ។ តាមពិតទៅខ្ញុំមានសំណួរមួយដែលត្រូវសួរទៅលោកជាចាំបាច់នេះ ដោយសារថា ខ្ញុំអត់ជឿពាក្យពេចន៍ដែលលោកនិយាយទេ អ៊ីចឹងឯង តាមពិតទៅគឺថាលោកមិនដែលបានឃើញការសម្លាប់ណាមួយដោយផ្ទាល់ភ្នែកទេ ចន្លោះពី ៧៥ ទៅ ៧៩។ ហើយលោកក៏មិនដែលឃើញការសម្លាប់ណាមួយនៅជិតវត្តៗខ្សាច់។ តាមពិតទៅគឺថាស្ថានភាពគឺវាអ៊ីចេះទេ ដូចសាក្សីម្នាក់បានរៀបរាប់មកហើយ--

**ប្រធានអង្គជំនុំ៖**

លោកមេធាវី មិនគប្បីប្រើប្រាស់នូវការសន្និដ្ឋានផ្ទាល់ខ្លួនដឹងរបស់លោក វាយតម្លៃទៅលើការផ្តល់សក្ខីកម្មរបស់សាក្សីបំណងឲ្យសាក្សីបាត់បង់នូវជំនឿទុកចិត្តរបស់ខ្លួននៅក្នុងការឆ្លើយតបទេ។ អង្គហេតុ -- អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោកគឺសួរពាក់ព័ន្ធនឹងអង្គហេតុ មិនមែនឲ្យលោកធ្វើសេចក្តីសន្និដ្ឋានលើសក្ខីកម្មរបស់សាក្សីរូបនេះទេ។ ដំណាក់កាលនៃផ្តល់សេចក្តីសន្និដ្ឋាន ដូចជាមិនទាន់ដល់ពេលទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនថ្វីទេលោកប្រធាន ប៉ុន្តែខ្ញុំគួរត្រូវបានអនុញ្ញាតឲ្យសួរដែលថាតាមពិតទៅគាត់មិនដែលបានឃើញការសម្លាប់ណាមួយ មិនដែលឃើញសាកសពនៅក្នុងវត្ត--

**ប្រធានអង្គជំនុំ៖**

នោះជាការសន្និដ្ឋានរបស់លោកទេ ភាគីដទៃទៀត គឺគេបានសួរដេញដោលរួចហើយ លោកកុំយកសេចក្ដីសន្និដ្ឋានមកធ្វើពាក់កណ្ដាលទីនាពេលនេះ វាយតម្លៃទៅលើការផ្ដល់សក្ខីកម្មរបស់សាក្សីណាមួយឲ្យសោះ ទី១។ ទី២ ក៏លោកមិនគប្បីប្រើប្រាស់នូវវិធីសាស្ត្រ ឬក៏យុទ្ធសាស្ត្រនៅក្នុងការធ្វើឲ្យសាក្សីណាមួយដែលត្រូវផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះអស់ជំនឿទុកចិត្តរបស់ខ្លួន នៅក្នុងដំណាក់កាលក្នុងអំឡុងពេលនៃការសួរដេញដោលដែរ។ បើសិនជាលោកសួរដេញដោលទៅ រិះរកថាមូលហេតុអ្វីដែលជានាំឲ្យជាភស្តុតាងឲ្យលោកជឿជាក់ថាសក្ខីកម្មហ្នឹងមិនពិតនោះគឺជា លោកដែលត្រូវវាយតម្លៃធ្វើសេចក្ដីសន្និដ្ឋានចុងបញ្ចប់នៃកិច្ចពិភាក្សាដេញដោលនៅក្នុងសំណុំរឿង ០០២/០២តែប៉ុណ្ណោះ។

[១៥:៣៧:៥២]

**លោក វ៉ិចទ័រ កូប៉េ៖**

ដូច្នេះលោកប្រធាន គឺខ្ញុំមិនត្រូវឲ្យសួរថាតើសាក្សីកំពុងតែនិយាយកុហក ឬក៏មិនកុហកនោះទេឬ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើដូច្នេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ មិនថ្វីទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយសូមផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោកខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរជាច្រើន ខុសពីលោក កូប៉េ ដែលអត់មានសំណួរដែលត្រូវសួរទៅកាន់សាក្សីរូបនេះ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរមួយចំនួនធំទៅកាន់លោក។ ជាដំបូងខ្ញុំសូមឲ្យលោកស្ដាប់សំណួរខ្ញុំឲ្យបានច្បាស់ ខ្ញុំនឹងសួរសំណួរខ្លីៗច្បាស់ៗ ហើយខ្ញុំសូមឲ្យលោកឆ្លើយដោយខ្លីៗនិងច្បាស់ៗទៅនឹងសំណួររបស់ខ្ញុំ។ សំណួរទី១ គឺពាក់ព័ន្ធទៅនឹងខ្សែជិវិតរបស់លោក លោកបានឆ្លើយថាក្នុងអំឡុងរបប

កម្ពុជាប្រជាធិបតេយ្យលោកស្ថិតនៅក្នុងកងចល័ត។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** បាទ គឺខ្ញុំនៅកងចល័តមែននៅក្នុងសហគមន៍ សហករណ៍ខ្ញុំ តាមភូមិ។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាលោកធ្វើអ្វីខ្លះនៅក្នុងកងចល័ត?

**ឆ៖** បាទ គេឲ្យកាប់ដី កាប់ទន្រ្ទានខែត្រ កាប់ឈើស្មៅអីធ្វើជី រែកអាចម៌គោ ហើយក៏ខ្វះសេដ្ឋកិច្ចទៅរកត្រីដាក់ក្នុងសហករណ៍ ទៅរកគ្រឿងម្ហូប គេមិនដែលឲ្យទំនេរទេ កាលនោះ។ គេប្រើខ្ញុំនៅតែទន្លេទេ ក្នុងសហករណ៍។

**ស៖** ការងារហ្នឹងគឺលោកធ្វើនៅក្នុងអំឡុងពេញមួយរបបកម្ពុជាប្រជាធិបតេយ្យតែម្តង គឺពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩ មែនទេ គឺលោកធ្វើការដដែលៗហ្នឹងរហូតមែនទេ?

**ឆ៖** គេឲ្យយាម បើយប់ឡើងគេឲ្យយាម គេចាត់តាំងឲ្យយាមផ្លាស់វេនគ្នា តាមភូមិ តាមឃុំនោះ កាលនោះ ពីអង្កាល់នោះ សម័យនោះ គេឲ្យយាមកាមគេ។

[១៥:៤១:២២]

**ស៖** លោកយាមហ្នឹងក្នុងឋានៈជាអី? ហើយយាមនៅកន្លែងណា?

សូមអភ័យទោសលោកសាក្សី សូមលោករង់ចាំមីក្រូឃើញភ្លើងក្រហមសិន ចាំលោកនិយាយ បើមិនអ៊ីចឹងទេ យើងស្តាប់អត់ឮទេ។

**ឆ៖** យាមអត់មានកាំភ្លើងមានអីកាន់ទេ អត់មានគ្រឿងអាវុធអីទេ មានតែកាំបិត ផ្គាក់ ពូថៅយើងនេះឯង យាមនោះ។ របប វាមិនទាន់មានកាំភ្លើងឯណា អត់ទេ។ បាទ ខ្ញុំរាយការណ៍ប្រាប់អស់ហើយ។

**ស៖** សំណួរដែលខ្ញុំសួរអម្បាញ់មិញនេះ គឺថាលោកយាមហ្នឹងក្នុងឋានៈជាអី លោកជាឈ្លប ឬក៏យ៉ាងម៉េច? ម៉េចបានជាលោកយាម?

**ឆ៖** បាទ ជាប្រជាជននេះឯង គេចាត់តាំងឲ្យទៅយាមផ្លាស់វេនគ្នាទៅ គេឲ្យយាម ឲ្យតែមានមនុស្សប្រុសគេឲ្យយាមហើយ នៅក្នុងភូមិ។

**ស៖** ខ្ញុំអត់ទទួលបានការបកប្រែជាភាសាបារាំងទេ សូមលោកឆ្លើយម្តងទៀត។

**ឆ៖** គេដាក់វេនគ្នាយាមតាមយប់ យប់ៗគេដាក់វេនគ្នា យាមទៅ ម្នាក់ពីរម៉ោង ម្នាក់មួយម៉ោងកន្លះម្នាក់ទៅ។ យប់ឡើងយាម ថ្ងៃឡើងរែកដី កាប់ដី ធ្វើជីកំប៉ុស ក្នុងសហករណ៍។ បើមិនអ៊ីចុះទេ គេ

អត់ឲ្យបាយហូបទេ អង្កាល់នោះនោះ ហូបតែបបរដើមចេកត្រកួននោះណា៎ ដល់ម៉ោងគេវាយជួង ម៉ឺងៗ កាន់ចានមួយ ម្នាក់ទៅក៏តម្រង់មួយវែកម្នាក់ៗ ឆ្អែតក៏ដោយមិនឆ្អែតក៏ដោយតែប៉ុណ្ណោះឯងចប់។

[១៥:៤៣:៣២]

**ស៖** លោកសាក្សី ខ្ញុំសូមប្រាប់លោកម្តងទៀត ខ្ញុំព្យាយាមសួរសំណួរខ្លីៗ ច្បាស់ៗ ហើយសុំឲ្យលោកឆ្លើយខ្លីៗ ច្បាស់ៗ ទៅនឹងសំណួររបស់ខ្ញុំ។ លោកឆ្លើយច្រើនណាស់ ខ្ញុំអត់សួរទេ។ អ៊ីចឹងសូមលោកឆ្លើយឲ្យត្រូវនឹងសំណួររបស់ខ្ញុំ។ គេឲ្យលោកយាមនេះ អ្នកណាជាអ្នកចាត់តាំងលោកឲ្យយាម? ជាអ្នកនៅក្នុងកងយោធា ឬក៏កងឈ្លបដែលចាត់តាំងឲ្យលោកយាមនេះ?

**ឆ៖** បាទ មេភូមិ កងឈ្លប មេភូមិគេ មេ១០ខ្នងគេនោះ។ គេចាត់តាំងប្រជាជននៅតាមភូមិនោះ វេន ផ្លាស់វេនគ្នាយាមទៅ រាល់តែយប់អ៊ីចុះឯង។

**ស៖** លោកយាមនៅកន្លែងណានៅក្នុងភូមិនោះ?

**ឆ៖** បាទ យាមតាមភូមិ តាមផ្លូវក្នុងភូមិ មិនមែនយាមនៅវត្តទេណា។ វត្តនោះកន្លែងមន្ទីរគេនៅ អ្នកណាប៊ានដើរចូល។ យប់បើប៊ានដើរចូលងាប់នោះឯង គេបាញ់ងាប់នោះឯង ព្រោះគេមានកាំភ្លើង។ ថ្ងៃប្រជាជនដើរចូលបានតើនៅក្នុងកន្លែងមន្ទីរគេនោះ ប៉ុន្តែទៅទាំងខ្លាចគេទេ អ្នកខ្លាច ខ្លាចអ្នកប៊ាន ចេះតែប៊ានទៅ។ កន្លែងការដ្ឋានគេនោះកុំចូលផ្តេសផ្តាសយប់ តែយប់ហើយ ប្រជាជនអត់ដើរបានទេ ដើរបានតែក្នុងភូមិ ក្នុងផ្ទះជុំវិញនោះឯង។

**ស៖** ចុះពេលយប់លោកទៅសម្រាកនៅឯណា? ខ្ញុំសូមសួរតាមរបៀបផ្សេងវិញ លោកយាមរហូតដល់ម៉ោងប៉ុន្មាន ក្នុងមួយថ្ងៃហ្នឹងលោកធ្វើការពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មាន?

**ឆ៖** ពេលដែលយាមផ្លាស់វេនគ្នាទៅ បើមានគ្នាប្រាំនាក់អ៊ីចឹង ផ្លាស់គ្នាពីរម៉ោងម្នាក់ទៅ ពីរម៉ោងម្នាក់ផ្លាស់វេនគ្នាទាល់ភ្លឺលែង បែកគ្នាមកផ្ទះរៀងខ្លួន។

[១៥:៤៦:៣៣]

**ស៖** លោកមិនបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំទេ ខ្ញុំចង់ដឹងថា លោកធ្វើការប្រចាំថ្ងៃហ្នឹងពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន? អម្បាញ់មិញនេះ លោកឆ្លើយពីការងាររបស់លោកនៅសហករណ៍ ទៅរកត្រី ទៅរកជីហ្នឹងទេ។ ខ្ញុំសួរថា ពេលដែលលោកយាមនេះ ខ្ញុំចង់ដឹងថាលោកធ្វើការពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មាន នៅពេលថ្ងៃ?

**ឆ៖** តែចំពោះថ្ងៃ អត់មានយាមទេ។ ថ្ងៃបែកគ្នា ចែកទៅរកការងាររៀងខ្លួន តែយប់ដាក់វេន

យាមបាទ។

**ស៖** ចាស ខ្ញុំយល់ គឺពេលថ្ងៃលោកទៅរកត្រី ឬក៏ធ្វើដី។ ដូច្នេះ ខ្ញុំចង់សួរលោកថា លោកធ្វើការទៅរកដី -- ទៅធ្វើដី ហើយនិងរកត្រី ពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មាន?

**ឆ៖** អូ៎! ជួនកាលអត់ទៀងទេ ជួនកាលពីព្រឹកទាល់ល្ងាច យប់បានមកដល់ ជួនកាលក៏មកពីភ្លឺទៅ វាអត់ទៀង បាទ។

**ស៖** ចុះពេលដែលលោកចូលទៅភូមិវិញ ឆាប់បំផុត ជាទូទៅ គឺម៉ោងប៉ុន្មាន? លោកថា ពេលខ្លះធ្វើការចប់យូរ -- លឿន ឬឆាប់។ អ៊ីចឹងខ្ញុំចង់ដឹងថា ពេលដែលលោកចូលទៅភូមិវិញហ្នឹង ឆាប់បំផុតគឺម៉ោងប៉ុន្មាន?

**ឆ៖** បំផុតគឺម៉ោងប្រាំហ្នឹងហើយ មិនខុសពីម៉ោងប្រាំទេ ម៉ោងប្រាំ ជួនកាលមុនម៉ោងប្រាំបន្តិចក៏មានដែរ ព្រោះអត់មានកំណត់។

[១៥:៤៩:00]

**ស៖** ពេលលោកត្រឡប់មកភូមិវិញហ្នឹង លោកចូលផ្ទះតែម្ដង ឬក៏ទៅណាទៀត?

**ឆ៖** បាទ ចូលផ្ទះតែម្ដង ក្រែងដល់ម៉ោងគេហៅហូបបបរទៅ ហ៊ានដើរផ្ដេសផ្ដាស អត់បបរហូប មិនបាច់និយាយត្រឹមបាយទេ បបរ – បបរដើមចេក បបរត្រកួន។

**ប្រធានអង្គជំនុំ៖**

សាក្សីឆ្លើយតបចាំបាច់ហ្នឹងសំណួរបានហើយ មិនទៅសួរដល់បបរត្រកួន បបរចេកឯណា!

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសួរលោកថាអ៊ីចេះ ក្រោយពីលោកត្រឡប់ចូលមកភូមិវិញនេះ លោកទៅផ្ទះតែម្ដង ឬក៏ទៅណាទៀត?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** បាទ ទៅផ្ទះតែម្ដង។

**ស៖** លោកបានឆ្លើយថាលោកមានពេលញ៉ាំអាហារ ដូច្នេះខ្ញុំចង់ដឹងថា ជាធម្មតាក្នុងសហករណ៍ពេលល្ងាចហ្នឹង លោកញ៉ាំបាយនៅម៉ោងប៉ុន្មាន?

**ឆ៖** បាទ ជួនកាលក៏ម៉ោងប្រាំ ជួនកាលក៏ម៉ោងប្រាំមួយ។ គេវាយជួងម៉ឺងៗទៅ តែហួសពេលបន្តិចក៏គេអត់ អត់មានបានហូបទេ។ អ្នកណាយឺតយ៉ាវបន្តិច ក៏អត់ហូប។

សះ លោកនិយាយអំពី ជួង។ អ៊ីចឹង មានន័យថា ពេលគេវាយជួង គឺត្រូវទៅញុំាទាំងអស់គ្នា អ៊ីចឹងមែនទេ?

ឆះ បាទៗៗ។

[១៥:៥១:១០]

សះ ពេលយប់លោកគេងនៅឯណា? ហើយកន្លែងគេងហ្នឹងមានចម្ងាយប៉ុន្មានម៉ែត្រពីវត្តខ្សាច់?

ឆះ តាមផ្ទះរៀងខ្លួនណេះណ៎ា។ សម្រាន្តនៅតាមផ្ទះរៀងខ្លួនហ្នឹងឯង ប៉ុនដល់ហូបបាយ ហូបបាយរួម កន្លែងសហករណ៍។

សះ ខ្ញុំសួរសំណួរដដែល កន្លែងដែលលោកគេងហ្នឹង មានចម្ងាយប៉ុន្មានពីវត្តខ្សាច់ ផ្ទះលោកហ្នឹងមានចម្ងាយប៉ុន្មានពីវត្តខ្សាច់?

ឆះ ផ្ទះខ្ញុំចម្ងាយប្រហែលជារយៈ៣០០ម៉ែត្រ ពីវត្តខ្សាច់មកផ្ទះខ្ញុំ។

សះ ចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩ហ្នឹង លោកនៅផ្ទះដដែលហ្នឹង តែមួយទេ មែនទេ?

ឆះ បាទ នៅផ្ទះតែមួយ។

សះ ចុះកន្លែងហូបបាយមានចម្ងាយប៉ុន្មានពីវត្ត?

ឆះ បាទ ឆ្ងាយ។ ឆ្ងាយជាងពីផ្ទះខ្ញុំទៅវត្ត ចម្ងាយ៣០០ម៉ែត្រ។ តែកន្លែងដែលក្នុងបាយរួមនោះ ចម្ងាយវារយៈកន្លះគីឡូឯណោះ – ៥០០ម៉ែត្រ។

[១៥:៥៣:១៦]

សះ ពេលលោកធ្វើការចប់ លោកទៅផ្ទះតែម្តង ឬក៏ទៅរោងបាយ?

ឆះ បាទ កាលនោះ តែធ្វើការចប់ទៅផ្ទះសិន។ ទៅផ្ទះសិន បើឮសូរជួង បានកាន់ចានមួយម្នាក់រត់ទៅកន្លែងរោងបាយ។ ខ្លាចមិនទាន់គេ។

សះ ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីមិត្តរបស់លោកឈ្មោះ ស៊ាន ស៊ង់។ លោកឆ្លើយថា លោកជាមិត្តភក្តិជិតស្និទ្ធនឹងគ្នា។ អ៊ីចឹង ខ្ញុំចង់ដឹងថាលោករស់នៅជិតគ្នាហ្នឹង ចម្ងាយប៉ុន្មានដែរ ផ្ទះលោកទៅផ្ទះគាត់មានចម្ងាយពីគ្នា?

ឆះ ពីផ្ទះវាមកផ្ទះខ្ញុំ ចម្ងាយប្រហែលជា រយៈប្រហែលជា១០០ម៉ែត្រ។ ដើរលេងតែជុំគ្នាហ្នឹងឯង ដើរធ្វើការជុំគ្នាហ្នឹងឯង ប៉ុន្តែវាប្អូនខ្ញុំទេ វានៅតូចជាងខ្ញុំ។

សះ ពេលដែលលោកឆ្លើយថាលោកធ្វើការជាមួយគាត់ហ្នឹង មានន័យថាគាត់ធ្វើដី ហើយនិង

ទៅរកត្រីអីដូចលោកដែរ មែនទេ?

**ឆ៖** អត់ទេ ស៊ាន ស៊ង់ អត់មានបានទៅរកត្រីជាមួយខ្ញុំទេ។ ខ្ញុំរកត្រីតែជាមួយឈ្មោះ ជឹង មួយ ឈ្មោះ មុត មួយ។ បើ ស៊ាន ស៊ង់ នោះមិនដែលទៅរកត្រីជាមួយខ្ញុំទេ។

**ស៖** អ៊ីចឹង ពេលដែលលោកនិយាយថាយើងធ្វើការជាមួយគ្នានេះ លោកមានន័យថាម៉េច? បើគាត់អត់ធ្វើដូចលោកផង?

**ឆ៖** ទេ កាលនោះដែលខ្ញុំបានទៅឃើញនោះវាដើរទៅជាមួយខ្ញុំហ្នឹងឯង វាទៅមើល លបមើលជាមួយខ្ញុំនោះឯង។

**ប្រធានអង្គជំនុំ៖**

ឆ្លើយនឹងសំណួរ! លោកមិនទាន់ឆ្លើយនឹងសំណួរផង ស្តាប់សំណួរសិន ឲ្យបានសិនណ៎ះ សឹមឆ្លើយ! រំឭកម្តងហើយ ម្តងទៀត!

[១៥:៥៥:០៣]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសួរឡើងវិញម្តងទៀត។ អម្បាញ់មិញនេះ ពេលដែលខ្ញុំនិយាយ ស៊ាន ស៊ង់ លោកថាលោកនិងគាត់ធ្វើការជាមួយគ្នា។ អ៊ីចឹង ខ្ញុំសួរថា បើលោកនិងគាត់មិនធ្វើជី និងទៅរកត្រីជាមួយគ្នាផងម៉េចបានជាលោកថាលោកធ្វើការជាមួយគាត់នោះ?

**លោក អ៊ុំ ស៊ន់៖**

**ឆ៖** ថ្ងៃមួយវាមកជុំខ្ញុំទៅ។ អត់មានរាល់តែថ្ងៃឯណា ជុំគ្នាឯណា អត់ទេ គេបំបែកគ្នាធ្វើការងារព្រោះសម័យនោះ អត់ដែលឲ្យនៅជុំគ្នារហូតទេ ថ្ងៃណេះនេះបានជុំគ្នា ថ្ងៃស្អែកខានស្អែក បែកគ្នាតែអ៊ីចុះឯង។ ធ្វើការមុខក្រសួងរៀងខ្លួន។

**ស៖** លោកដឹងថា ស៊ាន ស៊ង់ នេះធ្វើការនៅក្នុងកងណាទេ?

**ឆ៖** កងកុមារដូចគ្នាហ្នឹងឯង ក៏ប៉ុន្តែវាមុខក្រសួងគេខុសគ្នា បាទ មួយឃ្វាលគោ មួយកាប់ជី វាខុសគ្នា។

**ស៖** ដូច្នេះ តាមរយៈចម្លើយរបស់លោកហ្នឹង គាត់ហ្នឹងជាអ្នកឃ្វាលគោក្របី មែនទេ?

**ឆ៖** បាទ ស៊ាន ស៊ង់ នេះផ្នែកអ្នកឃ្វាលគោឃ្វាលក្របីទេ អង្កាល់នោះនោះ។ ខ្ញុំនេះគេបំបែកទៅខាងរកខាងសេដ្ឋកិច្ចសហករណ៍ឯនេះទេ ដោយឡែក ប៉ុន្តែដែលជុំគ្នា គឺជុំគ្នា មកហូបបាយជុំគ្នា។

[១៥:៥៨:១៨]

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅនិយាយអំពីការងារទី២របស់លោកគឺ ជាអ្នកយាម មានន័យថា លោកយាមផ្លូវ។ តើលោកយាមផ្លូវនៅក្នុងភូមិនេះពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន? ហើយគេរៀបចំចាត់ចែងយ៉ាងម៉េចចំពោះការយាមហ្នឹង?

**ឆ៖** បាទ គេដាក់យាមកាមតាមភូមិនេះ គេដាក់វេនគ្នា។ បើគ្នាមានប៉ុន្មាននាក់ ឧទាហរណ៍ថាគ្នាមាន១០នាក់ គេវេនគ្នាទៅ ពីរម៉ោងម្នាក់ទៅ ឬមួយម៉ោងកន្លះម្នាក់ទៅ តាមវគ្គៗមួយវគ្គៗវាទម្រាំបានភ្លឺ ភ្លឺឡើងបែកគ្នាធ្វើការ។

**ស៖** ចំណុចចុងក្រោយមុនពេលឈប់សម្រាកលោកបានឆ្លើយថា លោកនៅ ស៊ាន ស៊ង់ ហ្នឹងញឹកញាប់ណាស់។ ដូច្នេះ ខ្ញុំចង់ដឹងថាក្រោយឆ្នាំ៧៩នោះ លោកនៅតែមានទំនាក់ទំនងជាមួយ ស៊ាន ស៊ង់ ទៀតទេ? ហើយលោកជួបគាត់ញឹកញាប់ទេថ្មីៗនេះ?

**ឆ៖** បាទ សព្វថ្ងៃៗ ខ្ញុំមិនដែលបានជួបគ្នាទេ គេនៅឃ្លាំង គេនៅឆ្ងាយ ខ្ញុំបែកគ្នា សព្វថ្ងៃបច្ចុប្បន្ននេះ។ កាលមុននោះ ដើរលេងជុំគ្នានោះឯង រស់នៅជុំគ្នា។

[១៦:០០:១២]

**ស៖** កាលមុនហ្នឹងលោកនៅជុំគ្នាហ្នឹងពេលណាដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** កាលមុនជុំគ្នា ដល់ឥឡូវគេបែកផ្សេងហើយ គេនៅភូមិផ្សេងហើយ ធ្វើម៉េចជុំគ្នា។

**ស៖** លោកជួបគាត់ជាលើកចុងក្រោយនៅឆ្នាំណាដែរ?

**ឆ៖** ចុងក្រោយនោះ គឺមិនដែលបានជួបទៀត បែកគ្នាតាំងពីរំដោះហើយមក។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃសុក្រ ទី១១ ខែធ្នូ ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃសុក្រ ទី១១ ចុងសប្ដាហ៍នេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី អ៊ុំ ស៊ន់ បញ្ចប់ ហើយនិងចាប់ផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-848 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក អ៊ុំ ស៊ន់ ដំណើរការស្ដាប់សក្ខីកម្មសាក្សី សក្ខីកម្មរបស់លោកក្នុង

នាមជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យបន្តផ្តល់សក្ខីកម្មនៅថ្ងៃសុក្រ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក អ៊ុំ ស៊ន់ ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងសូមឲ្យអញ្ជើញគាត់មកចូលរួមសវនាការវិញនៅថ្ងៃសុក្រ ទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

[១៦:០២:១១]

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃសុក្រ ទី១១ ខែធ្នូ ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០២ នាទី)*